អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Aug-2012, 15:19
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី១០០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វ៉ីស៊ែល រីស៊ឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ឃីត រេយ៍ន័រ *(RAYNOR Keith)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស *(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត *(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក វ៉ែន ពៅ

លោក គឹម ម៉េងឃី

លោកស្រី បេនី យេ *(Beini YE)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ *(Ms.Emanuel JACOMY)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ហ្សាស្ដើ ប៉ៅ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី បេនី យេ | អង់គ្លេស |
| លោក គឹម វុន (TCW-338) | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី៖ លោក គីម វុន ហៅ ឆោម** (TCW-338)

សួរបន្តដោយលោក ឃីត រេយ៍ន័រ ផ្តើមពី៖ ........ ទំព័រ ៣

សួរដោយលោកស្រី បេនី យេ ផ្តើមពី៖ ........ ទំព័រ ៣៦

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖ ........ ទំព័រ ៥០

សួរដោយលោក គង់ សំអុន ផ្តើមពី៖ ........ ទំព័រ ៥៨

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី៖ ........ ទំព័រ ៧៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា សូមលោកស្រី សែ កុលវុឌ្ឍី ក្រឡាបញ្ជីសវនាការឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ សម្រាប់រយៈពេលពេញ១ថ្ងៃនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី ដែលមកផ្តល់សក្ខីកម្មបន្ទាប់ពីបញ្ចប់ សក្ខីកម្មរបស់សាក្សី គឹម វុន គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-28 មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណ។

[០៩:០២:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់លោក អៀង សារី។ អង្គជំនុំជម្រះសាលាដំបូង បានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមនៅក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលដំណើរការសវនាការពេញ១ថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត លីម ស៊ីវុតថា គ្រូពេទ្យទទួលពិនិត្យព្យាបាល និងថែទាំសុខភាពជនជាប់ចោទ

នៅមន្ទីរឃុំឃាំង នៃ អ.វ.ត.ក បានពិនិត្យសុខភាពរបស់លោក អៀង សារី នៅព្រឹកនេះ បានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈវិលមុខ និងហត់ខ្លាំងនៅពេលអង្គុយ ឬធ្វើចលនាបន្តិចបន្តួច ពិបាកទ្រាំនៅពេលអង្គុយ និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។

[០៩:០៣:៥៨]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះលោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ គាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយនិងស្មារតីសមស្រប អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការ ដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់អំឡុងពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

[០៩:០៥:០១]

បាទ ជាបន្ត មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា កាលពីម្សិលមិញអង្គជំនុំជម្រះបានទទួលសំណើសុំ របស់តំណាងសហព្រះរាជអាជ្ញា សុំបន្ថែមពេលវេលាសម្រាប់ខ្លួនមានឱកាសក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។ ដោយអង្គជំនុំជម្រះយល់ឃើញថា សំណើសុំ និងស្ថានភាពជាក់ស្តែង នៃសក្ខីកម្មរបស់សាក្សីរូបនេះមានសារៈសំខាន់ ដែលអង្គជំនុំជម្រះចង់ស្តាប់ ចង់បានទទួលព័ត៌មានជាច្រើនពីសាក្សីរូបនេះ ដែលគាត់បានដឹង បានឮ នៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងសំណួរដែលសួរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ព្រម និងផ្តល់ពេលវេលាពេញមួយព្រឹកនេះសម្រាប់ដល់សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអង្គជំនុំជម្រះមិនផ្តល់ពេលវេលាតាមស្នើសុំនោះឡើយ។ ប៉ុន្តែផ្តល់ពេលវេលាមួយចំនួនបន្ថែមសមស្រប

ដើម្បីឲ្យតំណាងសហព្រះរាជអាជ្ញា មានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះ។ ហើយសូម -- ដោយសារពេលវេលាដូច្នេះ សូមតំណាងសហព្រះរាជអាជ្ញាគួរតែត្រូវបានជ្រើសរើសនូវសំណួរសក្តានុពលទាំងឡាយ ដែលលោកយល់ថា សមស្របដើម្បីតាំងសំណួរចំពោះសាក្សី។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។

[០៩:០៦:៥៨]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងច្រើន។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានជ្រើសរើសនៅពេលនេះ អ្វីដែលសហព្រះរាជអាជ្ញាគិតថា វាជាឯកសារសំខាន់ៗ។ ដូច្នេះ ខ្ញុំនឹងបង្ហាញនូវខ្លឹមសារនៃការពិនិត្យដេញដោលសាក្សី ហើយខ្ញុំក៏បានពិភាក្សាកាលពីម្សិលមិញ នៅក្នុងថ្ងៃនេះជាមួយនឹងសហមេធាវីនាំមុខ ពាក់ព័ន្ធទៅនឹងការបែងចែកពេលវេលាសមស្រប សម្រាប់ដេញដោលសាក្សីរូបនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក គឹម វុន កាលពីម្សិលមិញ យើងបានពិភាក្សាគ្នាអំពីសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី ១៤ មេសា ឆ្នាំ១៩៧៦ ឯកសារ E3/262។ ចំពោះសំណួរដំបូងរបស់ខ្ញុំ ភាគី និងចៅក្រម គឺគាត់បានជ្រាបរួចមកហើយ គឺយើងបាន ពិនិត្យមើលទៅលើសេចក្តីប្រកាសថ្ងៃ១៤ មេសា ឆ្នាំ១៩៧៦។ ក៏ប៉ុន្តែយើងក៏ត្រូវពិនិត្យមើលឯកសារមួយទៀតផងដែរ ដើម្បីឲ្យយើងយល់ពីបរិបទនៃការតាំងសំណួររបស់ខ្ញុំ។

[០៩:០៨:១៣]

ឯកសារមួយទៀតនោះគឺ E3/380 ខ្មែរ 00357199, បារាំង 00485431 រហូតទៅដល់ 32, អង់គ្លេសគឺ 00365644។ លោក គឹម វុន ដូច្នេះគឺខ្ញុំមិនដឹងថា ឯកសារលោកមានរួចមកហើយនោះទេ ចំពោះឯកសារ E3/262 ហើយខ្ញុំសូមឲ្យលោកធ្វើការពិនិត្យឯកសារ ជាភាសាខ្មែរត្រង់លេខ 00622989។ សូមឲ្យលោកមើលទំព័រត្រង់លេខនេះ។ គឺមន្ត្រីតុលាការគួរតែ -- ខ្ញុំស្នើសុំឲ្យជួយឲ្យសាក្សីមើលពិនិត្យត្រង់ទំព័រ ERN អម្បាញ់មិញនេះផង គឺឯកសារ E3/262 លេខ ERN ជាភាសាខ្មែរគឺ 00622989 ខ្ញុំសូមបញ្ជាក់សាជាថ្មី។

[០៩:០៩:៣០]

លោក គឹម វុន ឯកសារនេះគឺពាក់ព័ន្ធនឹងសេចក្ដីប្រកាសព័ត៌មានដដែល គឺថ្ងៃ១៤ ខែមេសា ឆ្នាំ១៩៧៦។ នៅត្រង់ទំព័រនោះ លោកបានឃើញហើយ ដែលមានឈ្មោះបុគ្គលចំនួន១០រូប។ មុនពេលដែលយើងមើលចំណុចនេះ យើងឃើញក៏មានអត្ថបទផងដែរ ដែលថា គណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា គឺមានសមាជិកដូចខាងក្រោម៖

ទី១) នួន ជា, ទី២) ងួន កង ដែលជាអនុប្រធានទី១, ទី៣) ពៅ ស៊ូ អនុប្រធានទី២។ ហើយបន្ទាប់មកមានឈ្មោះសមាជិកនៅក្នុងហ្នឹងដែរ ដែលជាសមាជិករបស់សភាតំណាងប្រជាជនកម្ពុជា។

[០៩:១០:២៩]

នៅក្នុងកិច្ចសម្ភាសន៍មួយ ដែលថៅ -- ដែលអ្នកស៊ើបអង្កេតពីតុលាការនេះបានសម្ភាសលោក លោកបានលើកឡើងឈ្មោះបុគ្គល១៨រូប ហើយលោកក៏បានលើកឡើងអំពីឈ្មោះក្រសួងមួយចំនួនផងដែរ។ នៅពេលដែលលោករៀបរាប់ជូនអ្នកស៊ើបអង្កេតលោកបានបញ្ជាក់ថា លោកបានដឹងអំពីបុគ្គលទាំងអស់នេះ ហើយនិងក្រសួងមួយចំនួន។ ចំពោះលោក ជា ស៊ីម លោកថាគាត់ គឺជាអនុប្រធានរបស់ នួន ជា។

ខ្ញុំសូមសួរលោក តើហេតុអ្វីបានជាលោកគិតថា ជា ស៊ីម នោះគឺជាអនុប្រធានរបស់ នួន ជា? ហើយលោកផ្អែកទៅលើព័ត៌មានពីណាមក?

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំបាននិយាយពីខាងដើមថា ខ្ញុំជាសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា ខ្ញុំមិនមែនជាបក្ខជន។ ឯរឿងរចនាសម្ព័ន្ធរបស់អ្នកធំ ប្រហែលជាខ្ញុំដឹងតែកម្រិតណាទេ។ ដឹងជាក់លាក់មែនទែន ខ្ញុំតាមការស្ដាប់វិទ្យុផ្សាយអី គឺខ្ញុំចាប់អារម្មណ៍តិចតួចណាស់។ ព្រោះនៅសម័យនោះខ្ញុំផ្ដោតអារម្មណ៍ទៅលើការងារជាសំខាន់។ ព្រោះអ្នកកាសែតនៅសម័យនោះ គឺមិនមានបានទៅថតរូបថ្នាក់ដឹកនាំ មិនបានទៅថតរូបគណៈប្រតិភូបរទេសដែលមកកម្ពុជាទេ។

[០៩:១២:១៩]

ដូច្នេះខ្ញុំគ្រាន់តែយល់នៅពេលផ្សាយខ្លះ ខ្ញុំចាប់អារម្មណ៍ថា លោក នួន ជា គឺជាប្រធានសភា ហើយលោក ជា ស៊ីម ក៏អាចជាអនុប្រធានសភា។ នេះជាចំណាប់អារម្មណ៍ខ្ញុំនៅក្នុងសម័យនោះ គឺខ្ញុំចាប់អារម្មណ៍យ៉ាងនេះ ហើយខ្ញុំជឿជាក់ថា បញ្ហានេះពិតជាមែន។ ព្រោះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ការបែងចែកការងារ បើអ្នកណាធ្វើការអីគឺដឹងបញ្ហាហ្នឹង។ សូម្បីតែរចនាសម្ព័ន្ធថ្នាក់ដឹកនាំក្នុង

បក្ស នៅក្នុងរដ្ឋាភិបាលក៏គេ បើយើងមិនយកចិត្តទុកដាក់ស្តាប់ការផ្សព្វផ្សាយទេ គឺយើងអត់យល់ដែរ។ មិនដឹងថា អ្នកណាកាន់មុខងារអីទេ ព្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហាក់ដូចជាមានរឿងសម្ងាត់ច្រើនណាស់។ បើខ្ញុំធ្វើការងារអី គឺខ្ញុំត្រូវតែដឹងការងាររបស់ខ្លួនឯង។ បើខ្ញុំចុះទៅយកព័ត៌មាននៅមូលដ្ឋាន គឺដឹងតែពីរឿងដែលថ្នាក់ដឹកនាំថា ផ្តោតលើបញ្ហាអី គឺបញ្ហាកសិកម្ម បញ្ហាធ្វើទំនប់ទឹក ប្រឡាយទឹក ធ្វើអាងទឹក ធ្វើប្រព័ន្ធភ្លឺស្រែអីចឹង សិប្បកម្មអីជាដើមអីចឹងទៅ គឺខ្ញុំត្រូវយល់ពីបញ្ហាហ្នឹងឲ្យជ្រៅជ្រះ។ ឯរឿងរចនាសម្ព័ន្ធថ្នាក់ដឹកនាំសម័យនោះ ដូចខ្ញុំជាមិនសូវចាប់អារម្មណ៍ប៉ុន្មានទេ។ ប៉ុន្តែជាអារម្មណ៍ខ្ញុំ ខ្ញុំជឿថា លោក ជា ស៊ីម អាចអនុប្រធានសភា ហើយឯកសារនេះទៀត ខ្ញុំសម្គាល់គឺថាមិនមែនជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យទេ។

[០៩:១៤:០២]

ហេតុអីបានជាខ្ញុំថា មិនមែនជាឯកសារកម្ពុជាប្រជាធិបតេយ្យ ព្រោះបច្ចេកវិទ្យាសម័យទំនើបនេះ គឺអាចធ្វើហ្នឹងបាន។ ព្រោះសម័យនោះគេប្រើ *ទីប៉ូ* គឺអត់ៗ មានអក្សរហ្នឹង។ ហើយពាក្យមួយទៀតក្នុងរចនាសម្ព័ន្ធ ខ្ញុំពិនិត្យឃើញថា ជាធម្មតាថ្នាក់លើច្រើនប្រើពាក្យ “សមមិត្ត” ហើយក្នុងនេះប្រើពាក្យ “មិត្ត”។ អីចឹងខ្ញុំសង្ស័យថា មិនមែនជាឯកសារពិតរបស់កម្ពុជាប្រជាធិបតេយ្យទេ។ ប៉ុន្តែឯកសារមួយនេះជាឯកសារពិត។

**ស៖** សូមអធ្យាស្រ័យ ឯកសារដែលលោកកាន់ដៃស្តាំអម្បាញ់មិញនេះ ខ្ញុំមិនដឹងថាជាឯកសារអ្វីនោះទេ។ ដូច្នេះខ្ញុំសូមឲ្យមន្ត្រីតុលាការនេះជួយបញ្ជាក់ផងថា ឯកសារដែលគាត់លើកដៃស្តាំអម្បាញ់-មិញនេះ មានលេខ D លេខស្គាល់ D ហ្នឹងលេខប៉ុន្មានដែរ?

ខ្ញុំសូមត្រឡប់សួរអំពី នួន ជា និង ជា ស៊ីម សាជាថ្មីឡើងវិញ តើលោកធ្លាប់ឃើញពួកគាត់ទាំងពីរជួបប្រជុំគ្នា ឬក៏ចូលរួមជួបជាមួយគ្នាក្នុងព្រឹត្តិការណ៍ណាមួយដែរឬទេ?

**ឆ៖** អត់ដែលសោះ ប៉ុន្តែដោយឡែកលោក នួន ជា គឺខ្ញុំស្គាល់ច្បាស់។ ឯលោក ជា ស៊ីម នេះអត់ដែលស្គាល់ ប៉ុន្តែឮតាមមិត្តភក្តិនិយាយថាអីចឹង ខ្ញុំក៏ជឿជាក់ថា អាចជាអនុប្រធានសភា។ ព្រោះកិច្ចការអ្នកធំយើងដឹងអត់អស់ ប៉ុន្តែដោយឡែកលោក នួន ជា ខ្ញុំអះអាងថា ខ្ញុំស្គាល់ច្បាស់។

[០៩:១៦:៥១]

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះ លោកចំពោះការដឹងរបស់លោកពាក់ព័ន្ធទៅនឹង ជា ស៊ីម នេះគឺលោកបានដឹងតាមការដែលអ្នកផ្សេងជាអ្នកប្រាប់លោកតែប៉ុណ្ណោះ។ តើអីចឹង

ដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើលោកធ្លាប់ឃើញឯកសារណាមួយនៅក្នុងរោងពុម្ពនោះ ដែលសរសេរបញ្ជាក់យ៉ាងច្បាស់ថា ជា ស៊ីម គឺជាអនុប្រធានរបស់ នួន ជា?

**ឆ៖** ខ្ញុំមិនដែលបានឃើញឯកសារអ្វីទេ ព្រោះដូចខ្ញុំបានលើកពីខាងដើមហើយ រចនាសម្ព័ន្ធរបស់បក្ស ឬថ្នាក់ដឹកនាំជាន់ខ្ពស់ ខ្ញុំហាក់ដូចជាមិនសូវចាប់អារម្មណ៍ច្រើនទេ។ អ៊ីចឹងហើយបានការស្វែងយល់របស់ខ្ញុំ ក្រៅពីបុគ្គលដែលខ្ញុំធ្លាប់ធ្វើការងារដូចជា លោកស្រី យុន យ៉ាត ដូចជាលោក ខៀវ សំផន, លោក នួន ជា, លោក ប៉ុល ពត បើប៉ុន្មាននាក់ហ្នឹងខ្ញុំធ្លាប់ស្គាល់ច្បាស់។ ក្រៅពីនោះតាមក្រសួងផ្សេងៗ ក្នុងប្រព័ន្ធក្រសួងឃោសនាការក៏ខ្ញុំអាចស្គាល់មួយចំនួន ប៉ុន្តែក្រសួងផ្សេងទៀត ខ្ញុំមិនច្បាស់ដែរ។

[០៩:១៨:៣៥]

**ស៖** ខ្ញុំយល់ សូមអរគុណ។

**លោក ឃើត វេយ៍ន័រ៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញលោក គឹម វុន នូវឯកសារមួយគឺ E3/10។ ERN គឺខ្មែរលេខ 00063059, បារាំង 00491868, អង់គ្លេសគឺ 000450501 (ស៊ីក) 00--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីភាគីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:១៩:៤៦]

**សួរដោយលោក ឃើត វេយ៍ន័រ៖**

**ស៖** សូមអធ្យាស្រ័យលោក គឹម វុន ឯកសារនៅចំពោះមុខលោកនេះ គឺទំព័រខាងមុខនៃទស្សនាវដ្តីទង់បដិវត្ត លេខពិសេស ខែសីហា-កញ្ញា ឆ្នាំ១៩៧៦។ តើលោកអាចជួយបញ្ជាក់ដែរឬទេ តាមអ្វីដែលលោកដឹងទៅលើឯកសារទង់បដិវត្តនេះ? តើលោកមានបានស្គាល់ដឹងអ្វីខ្លះ? តើមានប្រធានបទឬក៏មានខ្លឹមសារអ្វីខ្លះ ដែលគេបានសរសេរនៅក្នុងលេខពិសេសនៃទង់ -- ទស្សនាវដ្តីទង់បដិវត្ត?

**ឆ៖** ខ្ញុំមើលច្បាប់ថតចម្លងនេះគឺ ជាទង់បដិវត្តពិត។ ប៉ុន្តែ ដូចខ្ញុំបានអះអាងអំពីការងាររបស់ខ្ញុំ ហើយគឺថា ការងាររោងពុម្ពនេះគឺខ្ញុំបានរំសាយ មិនបានចូលជ្រៅក្នុងការបោះពុម្ពនេះទេ។ ប៉ុន្តែខ្ញុំគ្រាន់តែអះអាងថា ឯកសារនេះជាឯកសារពិត។ ឯខ្លឹមសារយ៉ាងណាៗក្នុងលេខពិសេសនេះ ខ្ញុំមិនសូវបានដឹងទេ ហើយក៏មិនបានមើលដែរ។

[០៩:២១:១៥]

**ស៖** សូមឱ្យលោកជួយពន្យល់។ ក៏ប៉ុន្តែបើសិនបើលោកមិនអាចឆ្លើយបាន សូមប្រាប់ខ្ញុំ។ ពាក់ព័ន្ធទៅនឹងពេលវេលាដែលលោកធ្វើការទៅលើឯកសារ ដែលលោកធ្វើការលើឯកសារទង់ -- ទស្សនាវដ្ដីទង់បដិវត្ត។ តើលោកធ្វើការញ៉ើកញាប់លើឯកសារលេខ -- ទង់បដិវត្តលេខធម្មតានេះញ៉ើកញាប់ប៉ុនណា ហើយលេខពិសេសនេះចេញញ៉ើកញាប់ប៉ុនណាដែរ?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់ខាងដើម គឺថាខ្ញុំមិនច្បាស់ទេ ខ្ញុំមិនបានមើលទេ។ ប៉ុន្តែឯកសារនេះជាឯកសារពិត ជាទង់បដិវត្តពិត។

**ស៖** សូមអធ្យាស្រ័យ ខ្ញុំសូមឱ្យលោកមើលទំព័របន្ទាប់ បន្ទាប់ពីក្របខាងមុខនេះ។ លេខERN គឺ 00063062, បារាំង 00491871, អង់គ្លេស 00450504។ នៅទីនេះគឺយើងឃើញមានចំណុចដកស្រង់ចេញពីឯកសារនេះ ដែលក្នុងនេះគឺសរសេរថា “សេចក្ដីដកស្រង់បទឧទ្ទេសនាមរបស់សមមិត្តតំណាងបក្ស ក្នុងឱកាសពិធីបុណ្យរំឭកខួបទី១៦ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្ដកម្ពុជា”។ កាលបរិច្ឆេទនោះគឺ ៣០, ៩ ឆ្នាំ១៩៦០ ដែល ៣០ ខែឧសភា ឆ្នាំ១៩៧៦។ ក្នុងនេះគេសរសេរថា “ថ្ងៃនេះយើងមកជួបជុំគ្នា ដើម្បីធ្វើការរំឭកខួបឆ្នាំទី១៦ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្ដកម្ពុជាយើង”។

[០៩:២៣:២៥]

ពាក់ព័ន្ធទៅនឹងការរំឭកខួបនៃកំណើតបក្សកុម្មុយនីស្ដកម្ពុជា តើលោកអាចជម្រាបយើងបានដែរឬទេ អំពីខួបរំឭក -- ការរំឭកខួបនៃកំណើតបក្សនេះ?

**ឆ៖** តាមពិតទៅ បក្សនយោបាយមួយៗនៅក្នុងប្រទេសណាក៏ដោយ តែងតែមានគម្រប់ខួបរបស់គេ។ ខ្ញុំជឿថា បក្សកុម្មុយនីស្ដកម្ពុជាក៏អាចមានខួបរបស់ខ្លួនដែរ នៃការបង្កើត។ ខ្ញុំយល់អំពីខ្លឹមសារនេះតិចតួច នៅកាលបរិច្ឆេទ ថ្ងៃ៣០ ខែកញ្ញា ១៩៦០។ ដូច្នេះបើនិយាយជាប្រវត្តិពិតរបស់បក្សនេះ គឺមិនដូច្នោះទេ គឺនៅឆ្នាំវវាងទសវត្សរ៍៥០ ប៉ុន្តែមិនដឹង៥០ប៉ុន្មាន ខ្ញុំមិនចាំកាលបរិច្ឆេទ។ ប៉ុន្តែការ

ប្រកាសរបស់លោក ប៉ុល ពត នៅសម័យនោះ ប្រហែលជាចង់រំដោះខ្លួនចេញអំពីឥទ្ធិពលបក្សកុម្មុយ-នីស្តផ្សេងទៀត។ ព្រោះគាត់យល់ថា ការដាក់ឆ្នាំ១៩៦០ ខែកញ្ញានេះ គឺសមស្របជាង។ ព្រោះបក្សកុម្មុយនីស្តកម្ពុជាអាចមានគំនិត មានយុទ្ធសាស្ត្រ ឬក៏ថាមានមនោគមវិជ្ជាមួយឯករាជ្យ ហើយក៏មានមេដឹកនាំមួយដោយឡែកមិនពាក់ព័ន្ធនឹងបក្សដទៃ។ ព្រោះជាប្រវត្តិរបស់ខ្លួន បើនិយាយអតីតភាពគឺជាប់នឹងបក្សផ្សេងទៀតដែលគ្រប់គ្រងទាំងលាវ ទាំងខ្មែរ។ ដូច្នេះហើយចលនាដែលគេហៅកន្លងមក គេហៅ "ខ្មែរវៀតមិញៗ" ហ្នឹងគឺគាត់ចង់បំបាត់ចោលពាក្យហ្នឹង គឺថានៅឆ្នាំ១៩៦០ហ្នឹង ជាពេលវេលាមួយសមស្របកែអតីតភាពរបស់ខ្លួនឲ្យមានឯករាជ្យភាព។ នេះខ្ញុំយល់ថាអ៊ីចឹង។

[០៩:២៦:១១]

**ស៖** សូមខ្ញុំសូមចូលទៅដល់ប្រធានបទមួយទៀត ឯកសារនោះគឺលេខ -- កិច្ចសម្ភាសន៍របស់លោកមុនជាមួយនឹងអ្នកស៊ើបអង្កេតគឺឯកសារ E3/381 ខ្មែរ 00357206 រហូតទៅដល់លេខ 207, បារាំង 00429999, អង់គ្លេស 00365529, បារាំង គឺ 00402999។ នៅក្នុងនោះលោកលើកឡើងថា "ការបោសសម្អាតខ្មាំងផ្ទៃក្នុងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយទាំងក្នុងវិទ្យុ និងនៅក្នុងកិច្ចប្រជុំ។ ប្រសិនបើបងប្អូនណាមួយពាក់ព័ន្ធនោះ អង្គការលើកលែងទោសឲ្យ"។ តើលោកអាចជួយបញ្ជាក់ប្រាប់យើងខ្ញុំអំពីបញ្ហានេះដែរឬទេ ប្រសិនបើលោកមិនអាចបញ្ជាក់បន្ថែមទេក៏មិនអីដែរ។ សំណួរទី១ តើបុគ្គលនោះធ្វើអ្វីដែរ ដែលគេចាត់ទុកគាត់ជាខ្មាំងផ្ទៃក្នុងនោះ?

[០៩:២៨:០០]

**ឆ៖** កាលពីថ្ងៃម្សិល ដូចខ្ញុំបានលើកពីរឿង "ខ្មែរស" ម្តង។ កាលនៅក្នុងឆ្នាំ១៩៧៣ ដែលខ្ញុំនៅមូលដ្ឋានរំដោះ នៅក្នុងស្រុកស្ទឹងត្រង់ គឺពេលចលនាតស៊ូរបស់សម្តេចព្រះ នរោត្តម សីហនុ ឈានទៅកៀកនឹងភ្នំពេញ យន្តហោះក៏ទម្លាក់គ្រាប់បែកខ្លាំង ប្រជាជនក៏អត់ទីលំនៅ ភៀសខ្លួនមកតំបន់រំដោះ។ អ៊ីចឹងហើយសម័យនោះត្រូវរក្សាការសម្ងាត់។ អ៊ីចឹង ខ្ញុំថាសម័យដែលថា "បោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង" អាចពាក់ព័ន្ធនឹងចលនាតស៊ូផ្សេងទៀត ព្រោះនៅក្នុងរបបពាឆ្នាំ ខ្ញុំជឿជាក់ថាមានភាគីផ្សេងៗជាច្រើន។ ក្នុងសម័យនោះទៀត គឺខ្ញុំជឿជាក់ថាអ៊ីចឹង ព្រោះដូចក្នុងឯកសាររបស់បក្សដែលបានលើកអំពី "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង" គឺមានអីខ្លះ? ហើយសរសេរជាពណ៌ខ្មៅអ៊ីចឹងទៅ ក្នុងវគ្គផ្សេងៗហ្នឹង។ ជាពាក្យស្លោកពណ៌ខ្មៅ។ ខ្ញុំឃើញថាមានអាខ្មាំងយួនឈ្លានពានលេបទឹកដីប្រល័យពូជសាសន៍ហ្នឹងមួយ, ខ្មាំងបង្កប់ស៊ីរូងជាភ្នាក់ងារ សេ.អ៊ី.អា ពីរ, និងខ្មាំងបង្កប់ស៊ីរូងជា កា.ហ្សេ.បេ។ អង្កាល់សម័យនោះ

តាមវគ្គអប់រំ ខ្ញុំមានអារម្មណ៍ថាមានការជឿជាក់ក្នុងសម័យនោះ។

[០៩:២៩:៤៥]

ព្រោះនៅក្នុងការរស់នៅ ធ្វើការតស៊ូជាក់ស្តែង វាមានបញ្ហាលំបាកអ៊ីចឹងដែរ។ មានការរើគ្នា សូម្បីតែចលនាតស៊ូដូចគ្នា ដូចជាកងទ័ពមកពីយួនខាងជើង ពួកយៀកកុងអីហ្នឹង មែនទែនចលនាតស៊ូជាមួយរណសិរ្សរួបរួមជាតិកម្ពុជា។ បើគិតទៅអ្នកតស៊ូស្លាប់រស់ជាមួយរបបធីវគី ឬក៏សហរដ្ឋអាមេរិកនៅវៀតណាមខាងត្បូងអ៊ីចឹង ឬក៏នៅស្រុកខ្មែរ ដូចឧត្តមសេនីយ៍ លន់ នល់ គាត់បានធ្វើរដ្ឋប្រហារអីហ្នឹង។ មែនទែនទាំងអ្នកតស៊ូក្នុងព្រៃ ទាំងអ្នកតស៊ូនៅស្រុក មែនទែននៅមានដៃគូដូចតែគ្នាហ្នឹង។ គ្រាន់តែថាមានសង្គ្រាមអ៊ីចឹង ខាង លន់ នល់ គាត់សម្បូរបែបទៅ ហើយអ្នកនៅព្រៃអ៊ីចឹង មិនមានអាវុធសម្បូរបែបអ៊ីចឹង ហើយការសម្លាប់គ្នាទៅមក ក៏មធ្យោបាយសង្គ្រាមក៏ប្រើប្រាស់ដូចតែគ្នា ប៉ុន្តែបើយើងប្រៀបធៀបទៅខាងអ្នកមាន គេមានគ្រឿងអាវុធច្រើនជាងអ្នកក្រ។ ហើយខាងភាគីសម្តេចព្រះនរោត្តមសីហនុ គឺមានតែកូនចៅកសិករ មានតែកាំបិត ពូថៅ មានតែកាំភ្លើងចាស់ៗអីអ៊ីចឹង។

[០៩:៣១:១២]

អ៊ីចឹង ខ្ញុំឃើញ តាមខ្ញុំលើកជាឧទាហរណ៍ហ្នឹង គឺអាចវាមានដូចថ្នាក់ដឹកនាំលើកអ៊ីចឹងដែរ វាមានទំនាស់តាំងពីសង្គ្រាម៥ឆ្នាំមក មិនមែនកើតមានតែជំនាន់៣ឆ្នាំ៨ខែ២០ថ្ងៃ ហ្នឹងទេ។ គឺទំនាស់គ្នាតាំងពីមុនមក ប៉ុន្តែចលនារបស់មហាជនវាខ្លាំងអ៊ីចឹងទៅ ទប់វាមិនបាន។ ព្រោះមែនទែនរណសិរ្សរួបរួមជាតិកម្ពុជា គឺមានឥទ្ធិពលខ្លាំងក្លានៅក្នុងមហាជន ប្រមូលកម្លាំងបានច្រើន ជាងភាគីឧត្តមសេនីយ៍ លន់ នល់។ អ៊ីចឹងឃើញថា នៅសមរភូមិការប្រយុទ្ធគ្នា គឺស៊ីសាច់ហុតឈាមគ្នា គឺយកឈ្នះ យកចាញ់មែនទែន។ អ៊ីចឹងខ្ញុំឃើញថា ខ្មែរសម័យនោះ គឺចាត់ទុកគ្នាជាខ្មាំងសត្រូវតែម្តង សូម្បីតែសម្តេចព្រះ នរោត្តមសីហនុ ក៏ព្រះអង្គធ្លាក់ពីអំណាច ក៏បញ្ចុះបញ្ចូលកូនចៅចូលព្រៃម៉ាគីដែរ។ ដូច្នេះខ្ញុំឃើញថា ខ្មែរសម័យនោះ ចាត់គ្នាជាខ្មាំងសត្រូវតែម្តង។ ណានៅប្តុកណា គឺសម្លាប់ប្តុកផ្សេងទៀត ដើម្បីជ័យជម្នះ។ នេះជាការពិត។ ប៉ុន្តែជាវិធីសម្លាប់គ្នាតាមបែបណានោះ គឺខ្ញុំមិនដឹងអស់ដែរ ព្រោះខ្ញុំនៅខាងផ្នែកប្រព័ន្ធការផ្សព្វផ្សាយអ៊ីចឹង វាមិនដឹងច្បាស់ពីរឿងយោធា ពីរឿងនយោបាយចាក់ស្រេះយ៉ាងម៉េច ក៏អត់ដឹងដែរ។ ដឹងតែតាមការរៀនសូត្រ តាមការផ្សព្វផ្សាយតែប៉ុណ្ណឹង។

[០៩:៣២:៥៤]

**ស៖** លោក គឹម វុន សូមថ្លែងអំណរគុណចំពោះចម្លើយរបស់លោក។ ខ្ញុំសូមឱ្យលោកបន្ថែម

បន្តិច ពាក់ព័ន្ធទៅនឹងខ្មាំងខាងក្នុង។ លោកបាននិយាយផងដែរ ថាមានខាង សេ.អ៊ី.អា អាមេរិកាំង។ តើមានបណ្តាញ ឬក៏មានអត្តសញ្ញាណនៃខ្មាំងផ្ទៃក្នុង តើមានការផ្លាស់ប្តូរបែបណា ពីខែមេសា ថ្ងៃ១៧ ឆ្នាំ៧៥ រហូតទៅដល់ -- បានន័យថា មានការផ្លាស់ប្តូរអត្តសញ្ញាណខ្មាំង សេ.អ៊ី.អា បែបណា មុនឆ្នាំ ៧៥ និងក្រោយឆ្នាំ៧៥ នោះ?

**ឆ៖** ខ្ញុំមិនដឹងពិតជាក់ស្តែងយ៉ាងណាទេ។ ប៉ុន្តែភេទ ខ្ញុំឃើញថា កម្លាំងដែលអ្នកចាញ់ទៅ ក៏គេមិនព្រមចាញ់ដែរ គេនៅចិញ្ចឹមចិត្ត។ គឺថានៅក្នុងរបប៣ឆ្នាំហ្នឹង គឺមានភាគីជាច្រើន មិនឯកភាពនឹងធ្វើកុម្មុយនីស្តទេ តាមមើល។ ព្រោះនៅក្នុងកម្មាភិបាលរបស់បក្ស អ្នកខ្លះ គ្រាន់តែជាស្លាកទេ ប៉ុន្តែក្នុងគំនិតគេ គេចង់បានអីមួយ ក្រៅពីហ្នឹង។

[០៩:៣៤:១៥]

ព្រោះរបបសម័យនោះ មិនមែនដូចរបបសម័យនេះទេ។ របបសម័យនេះ គឺបើកទ្វារចំហ មហាអំណាចណា ក៏អាចមានផលប្រយោជន៍។ ប៉ុន្តែនៅក្នុងរបប៣ឆ្នាំ គឺគាត់បានរៀបចំយុទ្ធសាស្ត្ររបស់គាត់ គឺធ្វើកុម្មុយនីស្ត។ ដូច្នេះ ការធ្វើកុម្មុយនីស្តដែលយើងឆ្លងកាត់ពីរបប ពីដំណាក់កាលរាជានិយមមកដល់ដំណាក់កាលរបបសាធារណរដ្ឋ ហើយមករបបកុម្មុយនីស្តទៀត ឃើញថា លោកអាចនឹងប៉ាន់ស្មានដឹងថា តើទំនាស់មនោគមន៍វិជ្ជា ទំនាស់យុទ្ធសាស្ត្រ វាឡើងដល់កម្រិតណាហ្នឹង? ខ្ញុំសូមឲ្យលោកពិចារណាមកវិញ ខ្ញុំមិនបកស្រាយអីច្រើនទេ។ ខ្ញុំគ្រាន់តែឲ្យចាប់អារម្មណ៍ ពិចារណាឡើងវិញ តើមានការប្រកាប់ចាក់គ្នាលើខ្លឹមសារជាមនោគមន៍វិជ្ជាឬយុទ្ធសាស្ត្រយ៉ាងណានោះ ឬប្លុកកុម្មុយនីស្ត ប្លុកសេរី ឬក៏ប្លុកផ្សេងទៀតនោះ គឺថាវាស្មុគស្មាញណាស់។

ហើយមួយទៀត ឧបមាថា ថ្នាក់លើបានលើកថាខ្មាំងមានបីប្រភេទ។ តើលក្ខណៈវិនិច្ឆ័យយ៉ាងម៉េច? តាមពិតកូនចៅ កម្មករ កសិករមិនយល់ន័យពាក្យថាស្អីហៅ សេ.អ៊ី.អា? សូម្បីតែខ្ញុំសម័យនោះក៏ខ្ញុំមិនយល់ដែរ។ ជួនកាលប្រើពាក្យច្រឡំថា សេ.អ៊ី.អា យួនអីចឹង អាហ្នឹងខុសមួយបាត់ហើយ។ យួនគឺ យួន។ អាមេរិកគឺ អាមេរិក។ សូវៀត គឺសូវៀត។ ហើយកូនចៅកម្មករ កសិករអ្នកក្រីក្រសម័យនោះមិនបានរៀនទេ។ ដូចខ្ញុំអីចឹង ខ្ញុំរៀនបានតិចណាស់ ព្រោះខ្ញុំនៅក្មេង។ ដូច្នេះមិនយល់ន័យទេលោកពិចារណាមើលអាហ្នឹង។ ដូច្នេះអ្នកអនុវត្តទាំងនោះច្រើនជាអ្នកមិនសូវចេះដឹងខាងវិជ្ជាហ្នឹងទេ។ ព្រោះរៀននយោបាយ គឺរៀននយោបាយជាខ្មែរពាក់ព័ន្ធនឹងភាសាគឺអត់តែម្តង។ ហើយគេមិនពន្យល់អត្ថន័យថា តើ សេ.អ៊ី.អា មានថាយ៉ាងម៉េច? បើដូចឥឡូវនេះ គឺខ្ញុំយល់ច្បាស់ហើយ ស្អីដែលហៅ

សេ.អ៊ី.អា ហ្នឹង? ស៊ីហៅថា កា.ហ្សេ.បេ នោះ? ស៊ីហៅថា យួន?

[០៩:៣៦:៤០]

ពាក្យយួនមិនមែនជាពាក្យដាច់សាច់ទេ ជាពាក្យប្រពៃណីរបស់ខ្មែរទេ។ មកស័យនេះ គឺគេរើសអើង ថាបើនិយាយយួនដាច់សាច់ ត្រូវនិយាយថាវៀតណាម។ ចុះខ្មែរយើងដែលហៅថាខ្មែរហ្នឹងវាមិនមានន័យទេ? អ៊ីចឹង ខ្ញុំថាពាក្យទាំងអស់នេះ ពាក្យថា "សៀម, យួន, ខ្មែរ, លាវ" ជាពាក្យបុរាណ ពាក្យសាមញ្ញធម្មតា យើងតែងតែនិយាយ។ អ៊ីចឹង ខ្ញុំសូមទោសតុលាការថាបើខ្ញុំច្រឡំពាក្យថាយួនអី កុំប្រកាន់។ ព្រោះដូនតា ម៉ែឪខ្ញុំក៏អាចជាប់ពាក់ព័ន្ធគ្នា ព្រោះប្រវត្តិសាស្ត្រវាអ៊ីចឹង។ មិនមែនជាពាក្យដាច់សាច់ទេ។ អ៊ីចឹងខ្ញុំសូមទោសកន្លែងហ្នឹង ក្រែងនិយាយទៅមិនបានប្រើពាក្យសាធារណរដ្ឋសង្គមនិយមវៀតណាមអី សូមកុំប្រកាន់ ព្រោះជួនកាលយើងនិយាយថាខ្មែរអ៊ីចឹង។ និយាយខ្មែរវាបានន័យថាពេញហើយ បើនិយាយកម្ពុជាវាទូលំទូលាយអ៊ីចឹង។ អ៊ីចឹង ខ្ញុំសូមបកស្រាយប៉ុណ្ណឹង។ តាមការយល់របស់ខ្ញុំ។

**ស៖** លោក គីម វុន ថាតើលោកទទួលបានប្រភពព័ត៌មាននេះមកពីណាដែរ ដែលនាំឲ្យលោកអាចជម្រាបប្រាប់យើងបានថា ទាហាន លន់ នល់ ហ្នឹងមិនព្រមចុះចាញ់។ តើលោកបានប្រភពព័ត៌មាននេះពីណាមក?

[០៩:៣៨:២១]

**ឆ៖** ខ្ញុំដើរតាមមូលដ្ឋាន ខ្ញុំអាចដឹង។ ទៅខាងពាយ័ព្យ ខ្ញុំដើរយកព័ត៌មានច្រើនណាស់ ហើយប្រភពព័ត៌មានក្រៅផ្លូវការក្រៅពីកសិកម្មមានពាក់ព័ន្ធនឹងរឿងសន្តិសុខ។ ប៉ុន្តែមិនមែនជាមុខងាររបស់ខ្ញុំទេ ខ្ញុំមិនមែនផ្នែកចារកម្ម ខាងផ្នែកហ្នឹង។ ខ្ញុំទៅយកព័ត៌មាន។ ខ្ញុំបើនិយាយប្រាប់រដ្ឋមន្ត្រី យុន យ៉ាត ប្រាប់គាត់ថា ដឹងព័ត៌មានអ៊ីចឹងទៅ គាត់ថា "មិនមែនមុខងាររបស់យើងទេ មុខងារយើងគឺស្រែស្រូវតើ សិប្បកម្ម ឧស្សាហកម្ម និយាយរួមការកសាងប្រទេស។ មិត្តឯងកុំចាប់អារម្មណ៍នឹងរឿងគេ! ព្រោះរឿងជារឿងតំបន់ រឿងភូមិភាគ រឿងអី។ តាមពិតមានលាក់អាវុធ លាក់ស្រូវអង្ករនៅខាងភូមិភាគពាយ័ព្យអី គឺមហាជនគេអាចដឹង ប្រាប់យើង។ ប៉ុន្តែយើងមិនយកអាហ្នឹងមិនមកប្រាប់អ្នកមេដឹកនាំទេ ព្រោះមុខងារយើងមិនមែនសន្តិសុខឯណា។ រឿងសន្តិសុខ ជារឿងគេផ្សេង។ ដូច្នេះការងារយើង យើងដឹង។ ការងារដែលគេនិយាយប្រាប់ យើងគ្រាន់តែដឹងបានហើយ មិនបាច់និយាយ មិនបាច់នេះទេ"។ គាត់ណែនាំថាអ៊ីចឹង។

[០៩:៣៩:៣០]

អ៊ីចឹងចលនាហ្នឹងតស៊ូ។ ឧបមាថាខ្ញុំលើកថាខ្មែរស ខ្ញុំទៅភូមិភាគឧត្តរ។ ខ្ញុំសូមខាង បងអឿន, ខាង អ៊ំពក អ៊ី ថាខ្ញុំសុំទៅខាងឃុំបឹងល្វា ទៅខាងមូលដ្ឋានចាស់នៅស្រុកស្ទឹងត្រង់។ ឧទាហរណ៍ខ្ញុំលើក អ៊ីចឹងចុះ ប៉ុន្តែគាត់ថាផ្លូវលេខ ក្នុងភូមិភាគ៣០៤ ចាស់ មិនអាចមិត្ត -- មិនអាចទៅបានទេ។ សូម្បីឡានក៏ដោយ ម៉ូតូក៏ដោយ ព្រោះមានខ្មែរស។ ហ្នឹងខ្ញុំលើកបញ្ហោងដែលៗពីឆ្នាំ១៩៧៣ ឥឡូវមកជាប់ហ្នឹង ៣ឆ្នាំ។ ដូច្នេះ គេមិនមែនអនុញ្ញាតឲ្យខ្ញុំទៅយកព័ត៌មានទេ។ ឧទាហរណ៍មួយទៀត ខ្ញុំទៅខាងផ្នែកភូមិភាគបស្ចិម ខ្ញុំទៅយកព័ត៌មានដែរ--

**ស៖** លោកសាក្សី ខ្ញុំសូមទោស ដែលត្រូវកាត់លោក។ ខ្ញុំសូមទោស ដែលខ្ញុំត្រូវតែកាត់លោក ប៉ុន្តែខ្ញុំចង់ជម្រាបលោកថា ពេលវេលាដែលខ្ញុំអាចចោទសួរលោក គឺមានកម្រិតកំណត់។ ហេតុដូច្នេះ ហើយខ្ញុំសូមអភ័យទោស ដែលខ្ញុំត្រូវតែកាត់លោក ហើយខ្ញុំសូមបន្តទៅសំណួរបន្តទៀត ប្រសិនបើលោកមិនប្រកាន់ទេ។ ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបាននិយាយកាលពីព្រឹកមិញនេះ លោកប្រើពាក្យថា “កម្ទេច”។ ខ្ញុំស្នើសុំថាតើលោកអាចពន្យល់ ពាក្យថា “កម្ទេច” ហ្នឹង តើមានន័យបែបណាដែរ? សូមលោកធ្វើការពន្យល់ដោយសង្ខេប ហើយដោយត្រួសៗ។ សូមអរគុណ។

[០៩:៤១:១៣]

**ឆ៖** ពាក្យ “កម្ទេច” ជាពាក្យខ្មែរសាមញ្ញធម្មតា។ កម្ទេច បានថា ធ្វើម៉េចធ្វើឲ្យខ្ទេច។ ឧបមាថា បើមានរបស់អីមួយអ៊ីចឹងទៅ ជាឯកសារ ឬក៏ជាសៀវភៅ យើងចង់កម្ទេចវា គឺយើងគ្រាន់តែកម្ទេចវាឲ្យខ្ទេច។ ប៉ុន្តែអត្ថន័យនយោបាយ ពាក្យថា “កម្ទេច” បានន័យថា នៅលើសមរភូមិ ដើម្បីវ៉ៃកម្ទេចទីតាំង ឬក៏ធ្វើអីមួយតែងតែប្រើកម្លាំងយោធា បាញ់ប្រហារគ្នាទៅមក ដើម្បីសម្លាប់ហៅថា “កម្ទេច” ហើយ។ ដើម្បីបានជ័យជម្នះ ព្រោះនៅលើសមរភូមិចាត់ទុកគ្នាជាខ្មាំងសត្រូវហើយ ដូច្នេះភាគីហ្នឹងគឺត្រូវកម្ទេចគ្នាហើយ បានន័យថា បើបាញ់ទៅវាស្លាប់មនុស្ស វាអាហ្នឹងកម្ទេចហើយ។ ហ្នឹងន័យវាបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងពិនិត្យមើលទៅលើការដកស្រង់មួយ គឺនិយាយអំពីការផ្សព្វផ្សាយអំពីការកម្ទេចខ្មាំង។ តើមានការផ្សព្វផ្សាយតាមវិទ្យុ ឬមួយក៏ផ្សព្វផ្សាយតាមមធ្យោបាយផ្សេងទៀត?

**ឆ៖** សួរហ្នឹង លោកសួរហ្នឹងនៅក្នុងសង្គ្រាម៥ឆ្នាំ ឬក៏សួរជំនាន់៣ឆ្នាំ?

[០៩:៤២:៤៤]

**ស៖** គឺនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ឆ៖** ការកម្មេចយ៉ាងណានោះ ខ្ញុំមិនចូលជ្រៅដែរ ព្រោះខ្ញុំមិនមែនជាការងាររបស់ខ្ញុំ ខ្ញុំអត់ដឹង។

**ស៖** លោក គឹម វុន ខ្ញុំមិនមែនសួរលោកអំពីផែនការទេ។ ឥឡូវនេះ ខ្ញុំសូមលើកសំណួរជាថ្មី។ បន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ៧៥ តើលោកធ្លាប់ឮការផ្សព្វផ្សាយ ដែលការផ្សព្វផ្សាយនិយាយអំពីពាក្យចចាមអារ៉ាម នៃខ្មាំងផ្ទៃក្នុងដែលថា បងប្អូនណាមួយក៏ដោយ ក៏អាចត្រូវអង្គការលើកលែងមិនចោទប្រកាន់ដែរ តើលោកធ្លាប់ឮការផ្សព្វផ្សាយបែបនេះទេ?

**ឆ៖** តាមពិត ខ្ញុំបានឮ ព្រោះនៅក្នុងក្រុមគ្រួសារខ្ញុំក៏មានបញ្ហាដែរ។ ដូច្នេះ បញ្ហានេះ ខ្ញុំបានឮតាមរដ្ឋមន្ត្រីគាត់បានផ្សព្វផ្សាយ ផ្សព្វផ្សាយក្នុងវគ្គអប់រំនយោបាយ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរទៅលើការដកស្រង់ ការផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈវិទ្យុ និងការប្រជុំ។ ដូច្នេះហើយ ឥឡូវយើងផ្តោតតែទៅលើការប្រជុំ។ តើនៅក្នុងការប្រជុំបែបណា ថាតើការប្រជុំរបៀបណា ឬក៏នៅកន្លែងណា ដែលគេលើកយកមកផ្សព្វផ្សាយអំពីបញ្ហាទាំងអស់នេះ?

[០៩:៤៤:៥៨]

**ឆ៖** តាមវគ្គអប់រំនយោបាយ ជួនកាលអាចមានការប្រជុំសាមញ្ញ ប៉ុន្តែក៏អាចប្រជុំវិសាមញ្ញដែរ។ សាមញ្ញ ចង់និយាយថា ប្រជុំធម្មតាក៏ការផ្សព្វផ្សាយបញ្ហាហ្នឹងដើម្បីឱ្យយើងប្រុងប្រយ័ត្នដែរ ព្រោះមែនទែនមានៗ ជាចលនាអីចឹង។ ចលនាតស៊ូដើម្បីដណ្តើមអំណាចនេះ គឺមានច្បាស់លាស់អីចឹងតែម្តង មិនមែនអត់ទេ។ ការផ្តួលរំលំគ្នាហ្នឹង មិនមែនអត់ទេ គឺមានពិតប្រាកដតែម្តង។ អីចឹងត្រូវតែមានការប្រុងប្រយ័ត្ន។ សូម្បីតែខ្ញុំ សម័យនោះខ្ញុំមិនប៉ានដើរទៅណាផង សព្វដងខ្ញុំធ្លាប់ដើរតាម ដើរយកព័ត៌មានទៅដល់ព្រំដែន តាំងពីព្លៃសាន។ និយាយរួម ទូទាំងប្រទេសគឺដើរសឹងទាំងអស់ហើយ ប៉ុន្តែនៅក្រោយមានព្រឹត្តិការណ៍ដែលថាផ្ទៃក្នុងខ្លាំងអីចឹងទៅ ថ្នាក់ដឹកនាំ ក៏ដូចជាខ្លួនខ្ញុំដែរ អត់មានអារម្មណ៍ថាត្រូវដើរទេ។ ព្រោះបើដើរខ្លាចមានគ្រោះថ្នាក់ ព្រោះការបែងចែកគ្នាពីក្នុងភាគីតែមួយ ដែលបែកចំពាមទៅច្រើនអីចឹង វាពិបាកណាស់ មិនដឹងជានរណាខ្មាំង មិនដឹងជានរណាមិត្ត។ និយាយរួមគឺថា បើនិយាយប្រៀបធៀបនឹងទឹកវិញ នៅសម័យនោះគឺថាទឹកហ្នឹងបានល្អក់អស់ទៅហើយ។ ព្រោះមានអ្នកៗបានកកូរកកាយឱ្យល្អក់អស់ទៅហើយ។

[០៩:៤៦:២៧]

ដូច្នេះខ្ញុំមិនសម្លឹងឃើញថា នៅក្នុងទឹកហ្នឹងវាមានឃើញកំពិស ឃើញក្តាម ឃើញត្រីតូចត្រីធំអីយ៉ាងម៉េច គឺអត់ទេ មើលមិនឃើញទេ។ ហើយនៅក្នុងអារម្មណ៍របស់ខ្លួន គឺភ័យខ្លាចរហូតដែរ។ ភ័យ

ខ្លាចដោយយើងវាមានបញ្ហាដែរ បើយើងវាអត់មានបញ្ហា យើងអត់មានភ័យខ្លាចទេ។ ប៉ុន្តែនៅក្នុងក្រុមគ្រួសារខ្ញុំ វាមានបញ្ហា។ ដល់អ៊ីចឹងចេះតែប្រយ័ត្នខ្លួន ចេះតែមានការប្រុងប្រយ័ត្ន និងភ័យខ្លាច។

**ស៖** លោក គីម វុន ពាក់ព័ន្ធទៅក្នុងបញ្ហាប្រជុំដែលគេនិយាយអំពីស្មារតីប្រុងប្រយ័ត្ន ថាតើការប្រជុំនេះ គេធ្វើឡើងនៅក្នុងក្រសួងឃោសនាការ ឬមួយក៏គេធ្វើការប្រជុំនៅក្រសួង ឬក៏នៅកន្លែងផ្សេង?

**ឆ៖** តាមខ្ញុំចាំ បញ្ហានេះនៅក្រសួងខ្ញុំបានធ្វើ ធ្វើដោយខ្លួនឯង ដោយរដ្ឋមន្ត្រី ហើយក្រសួងផ្សេងទៀត និងក្នុងការបើកវគ្គនយោបាយក៏អាចមានដែរ។ ព្រោះរឿងនេះមិនមែនជារឿងលេងសើចទេ គឺជារឿងមែនទែន។ អ៊ីចឹងគឺថាត្រូវតែមានការប្រុងប្រយ័ត្ន។

[០៩:៤៨:00]

**ស៖** ខ្ញុំសូមថ្លែងអំណរគុណ។

**លោក ឃីត រេយ៉ន័រ៖**

ហើយឥឡូវនេះខ្ញុំបង្ហាញឯកសារមួយទៀត គឺE3/11 ភាសាខ្មែរមានលេខ 00063116, និងភាសាបារាំងគឺមានលេខ 00492795, និងភាសាអង់គ្លេសគឺមានលេខ 00486212។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះជូនទៅដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:៤៩:00]

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក គីម វុន ឯកសារដែលបង្ហាញនៅចំពោះលោកមុខនេះ គឺគម្របនៃទស្សនាវដ្ដីទង់បដិវត្ត លេខពិសេស ខែកញ្ញា ឆ្នាំ១៩៧៧។ ហើយផ្ទុយទៅនឹងទស្សនាវដ្ដីទង់បដិវត្តផ្សេងៗទៀត ដែលខ្ញុំបានបង្ហាញលោក ដែលទស្សនាវដ្ដីផ្សេងៗទៀតមានទង់ចំនួនប្រាំ។ ទស្សនាវដ្ដីមួយនេះមានទង់តែមួយធំ ហើយគឺគេដាក់នៅជាងពាក់កណ្ដាលនៃទំព័រឯណោះ។ តើលោកអាចជម្រាបបានដែរទេ ថាហេតុអ្វីបានមានទង់តែមួយ ហើយធំ នៅកណ្ដាលទំព័របែបនេះ?

E1/112.1

**លោក គឹម វុន៖**

**ឆ៖** រឿងទស្សនាវដ្ដីដែលបានកែប្រែរូបភាពពីទង់ប្រាំ មកទង់មួយ ខ្ញុំអត់ដឹងដែរ ហើយមិនដឹងផ្ដាស់នៅពេលណា ព្រោះខ្ញុំមិនបានដឹងពេលវេលាដែលធ្វើហ្នឹងទេ។ ប៉ុន្តែខ្ញុំអះអាងថា ឯកសារនេះជាឯកសារពិត ព្រោះទាំង*ហ្វុង* អក្សរសម័យនោះ និងការឆ្លាក់អក្សរក្រុបអីហ្នឹង គឺជាឯកសារពិតនៅសម័យនោះ។

[០៩:៥០:២៤]

**ស៖** អរគុណលោក។ ឥឡូវនេះ យើងលើកយកចំណុចមួយទៀតគឺនៅទំព័របន្ទាប់គឺ ឯកសារដដែលគឺ E3/11 ERN ភាសាខ្មែរគឺមានលេខ 00063118, ភាសាបារាំងគឺមានលេខ 00492797, និងភាសាអង់គ្លេសគឺមានលេខ 00486214។ ចំណងជើងគឺថា "បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា និងក្នុងឱកាសដែលបក្សប្រកាសចេញចំហជាផ្លូវការក្នុងប្រទេស និងលើឆាកអន្តរជាតិ"។ ដូច្នេះខ្ញុំសូមសួរលោកដូចតទៅ៖ ថាតើបន្ទាប់ពីឆ្នាំ៧៥ ឈានចូល៧៦នុ៎ង តើលោកគិតថាមានទំនាក់ទំនងអ្វីរវាងអង្គការជាមួយហ្នឹងបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** តាមខ្ញុំយល់ អង្គការ និងបក្សកុម្មុយនីស្តកម្ពុជាគ្រាន់តែជាពាក្យប្រើទេ មែនទែន ដូចតែមួយទេ។ បើយើងប្រើពាក្យថា "អង្គការ" គឺមានន័យ "វណសិរ្ស" ជាង ហើយបើប្រើ "បក្សកុម្មុយនីស្តកម្ពុជា" វាមានផ្ទៃក្នុងបក្សហ្នឹងជាង។ ព្រោះពាក្យ "អង្គការ" នេះវាទូលំទូលាយ។

[០៩:៥២:៥៤]

**ស៖** តើលោកដឹងដែរឬទេ ថាមានការប្រកាសឬក៏មានការផ្សព្វផ្សាយណាមួយដែលថា អង្គការគឺជាបក្សកុម្មុយនីស្តកម្ពុជា។ បានន័យថា គេផ្សាយថាវាជាអង្គ -- គឺតែមួយ។

**ឆ៖** ឥឡូវខ្ញុំរំឭកទៅក្រោយវិញបន្តិច ពីការសរសេរទស្សនាវដ្ដីរណសិរ្សរួបរួមជាតិកម្ពុជា។ ធម្មតាអត្ថបទទាំងមូលរបស់បក្សកុម្មុយនីស្តកម្ពុជា រដ្ឋមន្ត្រី ហ៊ូ នឹម គាត់ផ្ដល់សិទ្ធិឲ្យខ្ញុំបំព្រួញសេចក្ដី ហើយកែពាក្យពី "បក្ស" មក "អង្គការ" វិញ។ អ៊ីចឹងហើយមកដល់ជំនាន់៣ឆ្នាំក៏ខ្ញុំស្របតាមមេខ្ញុំហ្នឹងដែរ។ ព្រោះលោកធ្លាប់ណែនាំនៅរោងពុម្ពកន្លែងណាដែលមានខ្លឹមសារបក្សកុម្មុយនីស្តកម្ពុជា គាត់ឲ្យកែសម្រួលមកជាខ្លឹមសាររណសិរ្សវិញ។ ប្រើពាក្យជាអង្គការវិញ ដូច្នេះខ្ញុំអះអាងថា អង្គការ និងបក្សកុម្មុយនីស្តកម្ពុជា គឺជា -- គ្រាន់តែប្រែជារូបភាពទេ ឯខ្លឹមសារនៅដដែល។

[០៩:៥៤:៣៥]

**ស៖** សូមអរគុណលោក គឹម វុន។

**លោក ឃីត រេយ៍ន័រ៖**

ជាបន្តទៅទៀត ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីបង្ហាញដល់សាក្សីនូវឯកសារដែលមានលេខ E3/169 ដូច្នេះខ្ញុំសូមអនុញ្ញាតចំពោះតុលាការ ថាតើខ្ញុំអាចប្រគល់ឯកសារនេះជូនទៅសាក្សីបានដែរឬទេ? ហើយខ្ញុំសូមឱ្យសាក្សីពិនិត្យមើលទៅលើឯកសារទាំងមូល មិនមែនមើលតែទៅលើទំព័រនោះទេ។ ហើយបន្ទាប់មកសូមឱ្យលោកប្រាប់មកខ្ញុំ ថាតើលោកធ្លាប់ស្គាល់ ឬក៏លោកដឹងអំពីឯកសារនេះដែរឬទេ?

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

សូមអញ្ជើញលោកមេធាវី!

[០៩:៥៥:៥៦]

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ការប្រើប្រាស់ឯកសាររបស់សហព្រះរាជអាជ្ញាទេ។ ខ្ញុំចង់ចង្អុលបង្ហាញថា តាមការយល់ឃើញរបស់មេធាវីការពារក្តី មេធាវីការពារក្តីក៏នឹងអាចប្រើប្រាស់ឯកសារដែលមិនបានដាក់បង្ហាញនៅលើ*អ៊ិនធើណេត*ផងដែរ។ ប៉ុន្តែយើងគិតថា គេហាក់ដូចជាមិនឱ្យយើងធ្វើបែបនេះបាន។ ការពិត អានេះគឺអ្វីដែលបានកើតឡើងកាលពីសប្តាហ៍មុន ដែលយើងព្យាយាមហើយគេមិនអនុញ្ញាតឱ្យយើងប្រើប្រាស់ឯកសារបែបនេះ។ យើងទទួលស្គាល់ថា ក្រោយមកគឺមានចេញនូវសេចក្តីសម្រេច ប៉ុន្តែយើងនៅតែមានការយល់ឃើញថា នៅពេលនុ៎ងគឺខាងមេធាវីការពារក្តីដូចជាមានការមិនទទួលបាននូវផលចំណេញ ហាក់ដូចជាចេញប្រៀបទៅលើបញ្ហាមួយនេះ។ ហេតុដូច្នេះខ្ញុំចង់ដឹងថាតើឯកសារហ្នឹងអាចប្រើប្រាស់បានទាំងខាងព្រះរាជអាជ្ញា និងខាងមេធាវីការពារក្តី តើអាចដែរឬទេ?

[០៩:៥៧:១២]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅនឹងការលើកឡើងនេះ។ លោក គឹម វុន គឺជាសាក្សី ហើយគាត់គឺជាសាក្សីដែលប្រភេទពិសេសផងដែរ ប្រហែលជាគាត់មានចំណេះដឹង ឬក៏មានការយល់ដឹងអំពីព័ត៌មានទាំងអស់នេះ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក គឹម វុន ពាក់ព័ន្ធទៅនឹងឯកសារដែលលោកបានទទួល តើលោកអាចជម្រាបបានដែរឬទេ គឺឯកសារនេះគឺជាសុន្ទរកថារបស់សមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ នៃកម្ពុជាប្រជាធិបតេយ្យ ក្នុងសន្និបាតមហាជន ដែលប្រព្រឹត្តិនាឱកាសពិធីបុណ្យខួបលើកទី៣ នៃទិវាមហាជ័យជម្នះថ្ងៃ១៧ មេសា និងទិវានៃការបង្កើតកម្ពុជាប្រជាធិបតេយ្យ។ ជាដំបូងខ្ញុំចង់សួរលោកថា តើលោកចាំដែរឬទេអំពីបុណ្យខួបលើកទី៣ តើលោកធ្លាប់ចាំថាមានពិធីបុណ្យនេះទេ?

[០៩:៥៨:១៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទ សូមគាំទ្រជំហរមេធាវីលោកនួន ជា អម្បាញ់មិញនេះ ហើយសូមលោកប្រធានមេត្តាអនុញ្ញាតធ្វើសេចក្តីសម្រេចទៅលើសំណើនេះ -- ការកត់សម្គាល់នេះ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ហើយបើសិនជាអង្គជំនុំជម្រះមិនច្រឡំទេ ដោយសារមូលហេតុនៃបញ្ហាស្មុគស្មាញ បញ្ហាឯកសារនេះ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានកំណត់នូវបញ្ហានៃការណែនាំអំពីរបៀបរបបក្នុងការដាក់ឯកសារនៅចំពោះមុខ -- ដាក់ដេញដោលឯកសារនៅចំពោះមុខអង្គជំនុំជម្រះសាឡើងវិញ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២។ ហើយដោយយោងនូវខ្លឹមសារដែលមានការផ្លាស់ប្តូរមួយចំនួនទៅលើសេចក្តីសម្រេច ដែលអង្គជំនុំជម្រះធ្លាប់បានអនុវត្តពីមុនៗមកអំពីភាគីដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានសម្រេចយល់

ព្រមឲ្យភាគីមេធាវីការពារក្ដីលោក នួន ជា ប្រើប្រាស់នូវឯកសារមួយ ដែលអង្គជំនុំជម្រះបានសម្រេចថា មិនអនុញ្ញាតឲ្យដាក់ដូច្នេះទេ ដោយផ្អែកលើសេចក្ដីសម្រេចមុន ដោយសារសារៈសំខាន់នៃស្ថានភាពចរិតលក្ខណៈនៃឯកសារ វាមានលក្ខណៈខុសគ្នា។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះមានការកែប្រែលើឯកសារនេះឡើងវិញ ហើយអនុញ្ញាត។

[០៩:៥៩:៥៨]

ប៉ុន្តែគឺមេធាវីមិនប្រើសិទ្ធិនោះទេ ដោយថា -- អះអាងថាលោកមេធាវី ម៉ៃខល កាណាវាស ជាមេធាវីការពារក្ដីលោក អៀង សារី បានតាំងសំណួរដេញដោលចំពោះសាក្សីនោះហើយចំពោះឯកសារដែលខ្លួនមានបំណងធ្វើដូច្នេះ។ អ៊ីចឹងការវិវត្តនៃបញ្ហាក្នុងការដាក់ឯកសារនេះវាផ្សេង វាដោយឡែកពីដំណាក់កាលមុន។ ហើយអំមិញអង្គជំនុំជម្រះបានសម្រេចរួចហើយ ដោយផ្អែកលើខ្លឹមសារនៃបញ្ហាឯកសារ ដែលអង្គជំនុំជម្រះបានឆ្លៀតឱកាសជ្រើសរើសយកនូវប្រធានបទ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការចុងក្រោយទោះបីរបៀបវារៈនៃកិច្ចប្រជុំនោះនៅមានចំនួនច្រើនក៏ដោយ យើងឆ្លៀតយករបៀបវារៈនៃការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះនេះយកមកពិភាក្សាមុន ដើម្បីរកដំណោះស្រាយក្នុងការដេញដោលបញ្ហានេះ ដោយភ្ជាប់ទៅនឹងបញ្ហាដែលប្រឈមនឹងការសម្រេច ការដាក់ឯកសាររបស់ភាគីមេធាវីការពារក្ដី នួន ជា។

[១០:០១:០៧]

ហើយជាបន្តបន្ទាប់ អង្គជំនុំជម្រះបានពន្យល់ភាគីរួចហើយអំពីបញ្ហានេះ បញ្ហាដែលឥឡូវនេះទើបដំណើរទៅមុខនេះ គឺអង្គជំនុំជម្រះបានជម្រាបហើយថាឯកសារដែលមានលេខ E ជាសម្គាល់នេះគឺជាឯកសារកំណត់ថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ដូច្នេះភាគីឲ្យតែមានឯកសារ E3 ដែលបានបញ្ជាក់ហ្នឹង គឺមិនចាំបាច់បង្ហាញអត្តសញ្ញាណក៏បានដែរ ពីព្រោះថា E3 ហ្នឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ អង្គជំនុំជម្រះបានសម្រេចទទួលយកឯកសារហ្នឹងថា ដាក់នៅចំពោះ -- ចាត់ទុកថាដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។

[១០:០១:៥០]

ហើយនៅក្នុងនេះគឺកថាខណ្ឌដែលមានការពាក់ព័ន្ធនេះ គឺអង្គជំនុំជម្រះបានជម្រាបជូនហើយគឺថានៅពេលដែលអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ឯកសារណាមួយត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ ឬមានលក្ខណៈអាចឲ្យអង្គជំនុំជម្រះអាចទទួលយកបាន ភាគីអាចយកឯកសារនោះទៅ

ប្រើប្រាស់សម្រាប់គោលបំណងណាមួយក៏បាន ពោលគឺ “ពុំកំហិតត្រឹមគោលបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ ដរាបណាឯកសារ និងសំណួរទាំងនោះមានភាពពាក់ព័ន្ធ”។

[១០:០២:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៦:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ ដោយមានបញ្ហា អាចមានភ័ន្តច្រឡំបន្តិចលើបញ្ហាការកត់សម្គាល់របស់មេធាវី ដោយបញ្ហានេះ វាពាក់ព័ន្ធគ្នា ហើយដើម្បីឲ្យបានជ្រាបច្បាស់អំពីបញ្ហាដែលមានកត់សម្គាល់ដោយក្រុមមេធាវីការពារក្តី ចំពោះឯកសារដែលអង្គជំនុំជម្រះបានសម្រេច និងយល់ព្រមអនុញ្ញាតឲ្យភាគីតំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញនៅចំពោះមុខសាក្សី ហើយនិងនៅលើអេក្រង់ទូរទស្សន៍នាពេលនោះ ដើម្បីដេញដោលនោះ គឺសូមអង្គជំនុំជម្រះសូមផ្តល់ភារកិច្ច -- ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីបញ្ជាក់បន្ថែមបំភ្លឺអំពីបញ្ហានេះ ឲ្យច្បាស់។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[១០:០៧:២៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។

លោកសហព្រះរាជអាជ្ញា អង្គជំនុំជម្រះយល់ឃើញថាលោកចង់ប្រើប្រាស់ឯកសារដើម្បីសួរសាក្សីរូបនេះ។ ហើយឯកសារហ្នឹង គឺដូចជាមិនមាននៅក្នុង*អ៊ីនធើហ្វេស* ប្រចាំថ្ងៃ ដែលជាទូទៅ គឺថាត្រូវមានឯកសារដាក់នៅក្នុង*អ៊ីនធើហ្វេស* ហ្នឹង ដើម្បីឲ្យភាគីទាំងអស់អាចដឹងជាមុន ថាឯកសារណាខ្លះដែលភាគីទាំងអស់នឹងយកមកប្រើប្រាស់ជាមូលដ្ឋាន សម្រាប់សួរសំណួរទៅកាន់សាក្សីនោះ។ ដូច្នេះតើអ៊ីចឹងទេ លោកសហព្រះរាជអាជ្ញា? ឬក៏លោកមានមូលហេតុអីជាក់លាក់ ដើម្បីពន្យល់ថា ហេតុអីបានជាមិនមានឯកសារហ្នឹង នៅក្នុងបញ្ជី*អ៊ីនធើហ្វេស* ប្រចាំថ្ងៃរបស់អង្គជំនុំជម្រះនោះ?

**លោក ឃីត រេយ៍នរ៖**

ខ្ញុំសូមឆ្លើយតប ទំព័រដំបូងនេះ គឺបានបញ្ចូលទៅក្នុងប្រព័ន្ធ*អ៊ីនធើហ្វេស* ជាភាសាអង់គ្លេសរួចមកហើយ គឺ E3/202។ ទំព័រដំបូងនោះ ជាភាសាអង់គ្លេសបានផ្តល់ជូនជាមុនរួចមកហើយ ដោយ

ខាងការិយាល័យសហព្រះរាជអាជ្ញា។ ដោយសារឃើញថា វាជាឯកសារបកចេញពីភាសាបារាំងនោះៗ ក៏បានបញ្ជូនទៅកាន់ឲ្យសាក្សីផងដែរ។ នេះគឺចំណុចដែលខ្ញុំចង់បញ្ជាក់បំភ្លឺលោកចៅក្រម។

[១០:០៩:០៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះភាគីទាំងអស់បានដឹងជាមុនហើយ ថាឯកសារនេះនឹងត្រូវប្រើប្រាស់តាមរយៈ*អ៊ីនធើហ្វេស* នោះ។ បើសិនជាករណីនោះ វាមិនអីទេ គឺថាអាចប្រើប្រាស់ឯកសារនេះបាន មិនមានបញ្ហាអ្វីទេ លោកសហព្រះរាជអាជ្ញា។

**លោក ឃីត វេយ៍ន័រ៖**

ខ្ញុំសូមធ្វើការកត់សម្គាល់បន្ថែម គឺខ្ញុំគិតថា វាមិនមានប្រយោជន៍នោះទេ ប្រសិនបើមេធាវីការពារក្តី គាត់ព្យាយាមធ្វើការកាត់ជំទាស់ដដែលៗទៅលើបញ្ហានេះ។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក គីម វុន សំណួរចុងក្រោយរបស់ខ្ញុំនោះ។ ខ្ញុំចង់សួរថា តើលោកចាំទេ ការរំឭកខួបលើកទី៣ នៃមហាជ័យជម្នះថ្ងៃ១៧ មេសា នុ៎ង?

[១០:១០:០៦]

**លោក គីម វុន៖**

**ឆ៖** ជាធម្មតានៅក្នុងក្រសួងខ្ញុំ តែងតែធ្វើខួបជ័យជម្នះ ១៧ មេសា។

**ស៖** តើមានអ្វីកើតឡើង គេធ្វើអីខ្លះនៅក្នុងថ្ងៃគម្រប់ខួបនោះ? ជាទូទៅគេធ្វើអ្វីខ្លះ?

**ឆ៖** ជាធម្មតាគឺមានការខទ្មេសនាមពីរដ្ឋមន្ត្រី និយាយពីអត្ថន័យជ័យជម្នះ ១៧ មេសា។

**ស៖** សូមអរគុណ។ តើឯកសារនៅចំពោះមុខលោកនេះ គឺជាឯកសារផ្លូវការ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមើលឯកសារនេះ គឺជាឯកសារពិត។ ប៉ុន្តែបោះនៅឯណាៗ ខ្ញុំមិនដឹង។

**ស៖** តើលោកនឹកឃើញទេ នៅក្នុងសុន្ទរកថានោះ តើគេនិយាយអ្វីខ្លះ?

**ឆ៖** ខ្ញុំនឹកមិនឃើញ ព្រោះមិនបានមើលឯកសារហ្នឹងផង។ ហើយពេលខទ្មេសនាម ក៏ខ្ញុំមិនចាំរហូតដល់ពេលនេះ។ ប៉ុន្តែដឹងថាអត្ថន័យរួមក្នុងហ្នឹង គឺនិយាយពីជ័យជម្នះ ១៧ មេសា។ ខ្ញុំគ្រាន់តែកត់សម្គាល់អ៊ីចេះ ធម្មតាឯកសារថ្នាក់ប៉ុណ្ណឹងៗហើយ មិនមែនគំនិតរបស់លោក ខៀវ សំផន តែម្នាក់ទេ។ ខ្ញុំចាំឃ្លាលោក ខៀវ សំផន លោកតែងតែសរសេរឃ្លាវែង មិនសរសេរឃ្លាខ្លីទេ មិនសូវមានខណ្ឌទេ។

ដូច្នេះខ្ញុំថា មិនមែនប្រធានគណៈប្រធានរដ្ឋហ្នឹងព្រាងសេចក្ដីថ្លែងការណ៍ហ្នឹងដោយខ្លួនឯងទាំងអស់ទេ ហើយធម្មតាធ្វើអីមួយគឺមានថ្នាក់លើពីលើគាត់ហ្នឹងសម្រាប់ព្រាង មិនដឹងជាយ៉ាងដូច្នេះមែនឬអត់ទេ ព្រោះមានតែគាត់ទេអាចដឹងខ្លួនគាត់ច្បាស់។ ប៉ុន្តែការវាយតម្លៃរបស់ខ្ញុំ ខ្ញុំគិតថាអ៊ីចឹង ចំពោះឯកសារនេះ។

[១០:១២:៤២]

**ស៖** តើលោកដឹងថាលោក ខៀវ សំផន នោះសរសេរប្រយោគវែងៗ ដោយមិនមានខណ្ឌនោះ លោកដឹងដោយរបៀបណាដែរ?

**ឆ៖** ព្រោះខ្ញុំធ្លាប់ឃើញអត្ថបទខ្លះ។ នៅក្នុងវិទ្យុសម័យៗសង្គ្រាម៥ឆ្នាំ តែងតែមានអត្ថបទរបស់លោក សរសេរខ្លះ។ ខ្ញុំមិនចាំថាជាអត្ថបទអីទេ ប៉ុន្តែឃ្លារបស់លោកគឺវែងៗ។

**ស៖** សូមអរគុណ។ យើងនិយាយអំពីសុន្ទរកថារបស់លោក ខៀវ សំផន ដដែល។ សំណុំរឿងនៅក្នុងសំណុំរឿងនោះ គឺយើងឃើញមានការដកស្រង់ផ្នែកតូចមួយ ចេញមកពីប្រតិចារឹក នូវអ្វីដែលលោក គឹម វុន បានឆ្លើយតបទៅកាន់អ្នកស៊ើបអង្កេតរបស់តុលាការ។ ឯកសារទី១ នោះគឺ D201/10.1។ លោក គឹម វុន នៅក្នុងការសម្ភាសរបស់លោកជាមួយអ្នកស៊ើបអង្កេត លោកនិយាយថា “ខ្ញុំតែងតែនៅជាមួយគាត់នៅក្នុងរណសិរ្សរួបរួមជាតិ”។ តើអ៊ីចឹងទេ លោកធ្លាប់នៅជាមួយគាត់? លោកតែងតែនៅជាមួយគាត់?

[១០:១៤:១៨]

**ឆ៖** ខ្ញុំមិនបាននៅជាមួយគាត់ជាប់រហូតទេ ប៉ុន្តែពេលខ្លះអាចតែមួយភាគណាទេ។ បើគិតជាភាគរយក្នុង១០០ហ្នឹង មានសូន្យក្បៀសបីភាគរយប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរអំពីអ្វីដែលលោកដឹងពាក់ព័ន្ធទៅនឹង ខៀវ សំផន ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ នៅពេលដែលលោកធ្វើការងារនៅក្រសួងឃោសនាការ និងក្រសួងឃោសនាការអប់រំ។ សំណួរទី១ តើលោកធ្លាប់ធ្វើការនៅក្នុងមន្ទីរ ឬក៏ក្រសួងរបស់លោក ខៀវ សំផន ដែរឬទេ?

**ឆ៖** ខ្ញុំអត់ធ្វើជាមួយទេ ព្រោះខ្ញុំមកក្រសួងផ្សេង មកក្រសួងឃោសនាអប់រំបាទ ខ្ញុំអត់ដែលជួបមុខគាត់ទេ ជំនាន់៣ឆ្នាំ។ ជួបដោយចៃដន្យ ខ្ញុំជួបដោយចៃដន្យ ហើយគាត់ក៏មិនដឹងថាខ្ញុំនៅកន្លែងណា ព្រោះខ្ញុំអ្នកកាសែត ធម្មតាខ្ញុំចេញទៅថតរូបនៅជិតៗភ្នំពេញ ហើយអត់ដែលជួបមុខគាត់ទេ មិនដឹងគាត់នៅមន្ទីរណា ខ្ញុំអត់ដឹង។

[១០:១៥:៥៩]

**ស៖** ខ្ញុំសូមឲ្យលោកបញ្ជាក់ឲ្យច្បាស់ត្រង់ចំណុចនេះ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ តើត្រឹមត្រូវដែរឬទេ ដែលថាលោកបានជួបលោក ខៀវ សំផន តែម្ដងគត់ដោយចៃដន្យ?

**ឆ៖** ខ្ញុំនិយាយថាអ៊ីចឹង។

**ស៖** តើគាត់ហ្នឹងទទួលខុសត្រូវក្នុងការតាមដានការងាររបស់លោកដែរឬទេ?

**ឆ៖** គាត់អត់ដែលបានជួបខ្ញុំ ហើយតាមដានការងារខ្ញុំ ព្រោះខ្ញុំមានក្រសួងផ្សេងហើយ។

**ស៖** តើលោកធ្លាប់ចូលរួមវគ្គនយោបាយ វគ្គអប់រំ វគ្គរៀនសូត្រណាមួយ ដែលនៅពេលនោះមានវត្តមាន ខៀវ សំផន ដែរឬទេ?

**ឆ៖** ខ្ញុំមិនធ្លាប់ដែលបានចូលរួមជាមួយគាត់ទេ ហើយក៏មិនដែលបានជួបគាត់ដែរ។

[១០:១៧:១៣]

**ស៖** តើលោកធ្លាប់ទៅមើលក្រសួងពាណិជ្ជកម្មដែរឬទេ?

**ឆ៖** នៅក្រសួងពាណិជ្ជកម្មខ្ញុំមិនដែលទៅ ប៉ុន្តែបើស្អីទាក់ទងនឹងពាណិជ្ជកម្ម ដូចជា ការដឹកជញ្ជូនរបស់ភូមិភាគ ឬតំបន់នៅកំពង់ផែភ្នំពេញ ខ្ញុំធ្លាប់។ ប៉ុន្តែទៅទាក់ទងនឹងក្រសួង ខ្ញុំអត់ដែលបានទៅ។ ខ្ញុំទៅហ្នឹងគឺដើម្បីថតយកចលនាខ្លះសម្រាប់ផ្សាយ ឬក៏យកព័ត៌មាន។

**ស៖** ពាក់ព័ន្ធទៅនឹងពេលដែលលោកឃើញ ខៀវ សំផន តើត្រឹមត្រូវដែរឬទេ គឺលោកឃើញតែព័ត៌មានស្ដីអំពី ខៀវ សំផន នេះតាមរយៈមិត្តរបស់លោកតែប៉ុណ្ណោះ?

**ឆ៖** បាទត្រឹមត្រូវ។

**ស៖** តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមដែរឬទេ?

**ឆ៖** បើនិយាយជាសិទ្ធិ ខ្ញុំអត់មាន។

[១០:១៨:៥៧]

**ស៖** ជាថ្មីម្ដងទៀតចូលទៅដល់ការសម្ភាសរបស់លោក ដោយអ្នកស៊ើបអង្កេតគឺ D210/11.1។ ខ្មែរគឺ 00833795, អង់គ្លេស 00834717។ លោកបានលើកឡើងថា "ការឃោសនា និងការអប់រំខ្ញុំមិនដែលជួបគាត់នោះទេ។ គាត់ទាក់ទងនឹងឃោសនាអប់រំ ខ្ញុំអត់ដែលឃើញគាត់នោះទេ ហើយគាត់ក៏មិនដែលឃើញលេចមុខ លេចអីដែរ"។

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកក៏បាននិយាយផងដែរ នៅក្នុងឯកសារនោះថា នៅក្នុងអំឡុងពេលនោះ គឺក្រោយ១៧ មេសា ជាភាគច្រើននោះ ឃោសនាការហ្នឹងគឺជាប់ពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន តើត្រឹមត្រូវដែរឬទេ?

**ផ៖** មិនត្រឹមត្រូវទេ។

**ស៖** តើលោកអាចបញ្ជាក់ទេ អ្វីដែលលោកឆ្លើយនេះមានន័យយ៉ាងម៉េចដែរ?

**ផ៖** ខ្ញុំឆ្លើយមានន័យថា គាត់អត់ដែលមានវត្តមានមកនៅក្នុងក្រសួងខ្ញុំទេ។ ព្រោះនៅក្រសួងខ្ញុំមានរដ្ឋមន្ត្រីមួយហើយ។

**ស៖** ក្រោយ ១៧ មេសា ១៩៧៥ តើ ខៀវ សំផន មានថ្លែងសុន្ទរកថាអ្វីដែរឬទេ ឬមានចេញផ្សាយសុន្ទរកថាដែរឬទេ?

[១០:២១:០៨]

**ផ៖** ដូចខ្ញុំបានលើកពីខាងដើម ខ្ញុំថាមាន។ ប៉ុន្តែគ្រាន់អត្ថបទហ្នឹងវាឃើញឃ្លាអីៗហ្នឹងវែង បើវែងៗខ្ញុំជឿថា ចេញពីគាត់។ ប៉ុន្តែបើមានឃ្លាខ្លីៗ អានេះជាការគិតរបស់ខ្ញុំទេ ព្រោះខ្ញុំធ្លាប់ដឹងពីស្នាដៃរបស់គាត់។

**ស៖** ពាក់ព័ន្ធទៅនឹងការរំឭកខួប ពិធីរំឭកខួបមហាជ័យជម្នះនោះ តើលោកចាំថាគេមានធ្វើបទឧទ្ទេសនាមសេចក្ដីថ្លែងការណ៍ដាច់ដោយឡែកៗពីគ្នាដែរឬទេ ជារៀងរាល់ឆ្នាំនោះ?

**ផ៖** ក្នុងពិធីមួយៗដូចមានតែសេចក្ដីថ្លែងការណ៍ ហើយសេចក្ដីថ្លែងការណ៍នេះ ជួនកាលក៏មិនសូវបានមើលផងខ្ញុំ ប៉ុន្តែដឹងថាមាន ធម្មតាមានពិធីខួបហើយតែងតែមាន។

**ស៖** លោក គឹម វុន នៅពេលនេះ ខ្ញុំសូមសួរអំពីអតីតប្រពន្ធរបស់លោក គឺ ហៅ ឈ្មោះ ភ័ណ្ឌ តើលោកអាចជម្រាបជូនយើងខ្ញុំបានដែរឬទេ? តើមានអ្វីកើតឡើងចំពោះប្រពន្ធរបស់លោកនៅក្នុងឆ្នាំ ១៩៧១ ដែលមានឈ្មោះ ជឹម ឈាណារី ហៅ ភ័ណ្ឌ នោះ?

**ផ៖** *(សាក្សីយំ)*

[១០:២៣:១៦]

**លោក ឃីត រេយ៍ន័រ៖**

បាទ សូមឲ្យលោកសម្រួលអារម្មណ៍ យើងយល់អំពីស្ថានភាពរបស់លោក។

**ស៖** លោក គឹម វុន តើលោកចង់ឲ្យខ្ញុំបន្តសួរសំណួរបន្តទៀតដែរឬទេ?

**ឆ៖** សួរចុះ។

**ស៖** លោកបាននិយាយនៅក្នុងការស្ដាប់ចម្លើយរបស់អ្នកស៊ើបអង្កេត លោកបានថា "ប្រពន្ធរបស់លោក គឺគេហៅទៅរៀនសូត្រ ហើយបន្ទាប់មកបានបាត់ខ្លួនរហូត"។ តើលោកអាចរៀបរាប់ និងរំឭកហេតុការណ៍នៃការកោះហៅនៅពេលនោះ ហើយបាត់ខ្លួនដែរឬទេ?

[១០:២៥:០០]

**ឆ៖** តាមពិតទៅខ្ញុំអត់ដឹងរឿងអីទេ។ ប៉ុន្តែមុននឹងមានបញ្ហានេះ គាត់មានការផ្លាស់ប្តូរការងារច្រើន ហើយខ្លួនខ្ញុំក៏បានផ្លាស់ប្តូរច្រើនកន្លែងនៅក្នុងក្រសួង គិតទៅក្នុងមន្ទីរពីលេខ២៥ ដល់លេខ២៩ ប្រហែលជាខ្ញុំចល័តនៅតាមមន្ទីរនុ៎ងរហូត។ ដោយឡែកតែមន្ទីរពីរទេ ដែលខ្ញុំមិនបានចល័តទៅ។ គឺថានៅសម័យនោះ ការងារដែលក្បែរគ្នាគឺតាមរដ្ឋមន្ត្រីគាត់ចាត់តាំងឲ្យប្រពន្ធខ្ញុំ ទៅនៅធ្វើការងារជាអនុប្រធានមន្ទីរនៅឃោសនាការ។ ភារកិច្ចរបស់គាត់ប្រចាំថ្ងៃគឺ អានវិទ្យុ តែក្រោយមកវិញក៏ឃើញ ដកមកនៅមន្ទីរ ក-២៥ វិញ មកធ្វើលេខាឲ្យលោកស្រី យុន យ៉ាត។ ភារកិច្ចរបស់គាត់មួយផ្សេងទៀត គឺសម្រាប់ស្រង់ប្រវត្តិរូបកម្មាភិបាលយុទ្ធជន យុទ្ធនារីនៅក្នុងក្រសួង។ ហើយនិងមានការងារមួយផ្សេងទៀត ជាគ្រូបង្រៀនសម្រាប់បង្រៀនក្មេង។ នៅក្នុងរយៈពេលហ្នឹងហើយ ដែលគាត់ត្រូវបែកពីខ្ញុំ។ ហើយខ្ញុំមិនដឹងថា គេអញ្ជើញឲ្យទៅរៀននៅកន្លែងណា ក៏ខ្ញុំអត់ដឹង ព្រោះជាគំនិតរបស់រដ្ឋមន្ត្រី។ ពេលដែលដកប្រពន្ធខ្ញុំទៅរៀន ក៏គាត់មិនដែលប្រាប់ថាទៅណាដែរ។ ខ្ញុំឡើងទៅសួរដល់កន្លែង។ ព្រោះកន្លែងនុ៎ងជាធម្មតាខ្ញុំមិនដែលទៅជួបគាត់ នៅផ្ទះដែលគាត់នៅ។ ប៉ុន្តែដល់ពេលអ៊ីចឹង ខ្ញុំថា វាមានអីត្រូវខ្លាចទេ យើងត្រូវឡើងទៅសួរដល់កន្លែងគាត់នោះ។

[១០:២៧:៣០]

អ៊ីចឹងខ្ញុំអនុញ្ញាតពីអ្នកយាមទ្វារចូលទៅផ្ទះគាត់ផ្ទាល់តែម្តង សួរគាត់ពីរឿង -- ថារឿងអីដែលប្រពន្ធខ្ញុំទៅរៀនហ្នឹង? គាត់ក៏អត់ប្រាប់ខ្ញុំដែរ។ គាត់គ្រាន់តែប្រាប់ខ្ញីថា អត់ទាន់ប្រាប់មិត្តឯងបានទេ ទាល់មិត្តឯងរៀនកន្លះខែសិន បានគាត់អាចប្រាប់បាន។ គាត់ថាឲ្យត្រឡប់ទៅធ្វើការវិញទៅ!

ដូច្នេះព័ត៌មានពីប្រពន្ធបានប៉ុណ្ណឹង។ ហើយពេលដែលទៅក៏អត់មានយកអីវ៉ាន់ទៅទាំងអស់។

**ស៖** លោក គឹម វុន តើលោកមានកូនដែរឬទេជាមួយនឹងប្រពន្ធមុនរបស់លោកនោះ នៅពេលនុ៎ង?

**ឆ៖** ខ្ញុំមានកូនស្រីមួយ អាយុជិតមួយខួប។

**ស៖** តើមានអ្វីកើតឡើងចំពោះកូនស្រីរបស់លោកនោះ?

**ឆ៖** ខ្ញុំអត់ដឹង។ មិនដឹងជាទៅហ្នឹងមានភាពយ៉ាងម៉េចនៅទីណា គឺអត់ដឹងទេ។

**ស៖** យើងយល់ច្បាស់ទាំងអស់គ្នា គឺប្រសិនបើយើងនិយាយអំពីថ្ងៃដែលកូនរបស់លោក -- ប្រពន្ធរបស់លោកបាត់ខ្លួននោះ តើនៅពេលនោះកូនហ្នឹងនៅជាមួយលោកដែរឬទេ?

[១០:២៩:៣០]

**ឆ៖** ក្នុងរយៈ៣ឆ្នាំ អ្នកដែលមានកូន ធម្មតានៅតាមក្រសួងមន្ទីរតែងយកទៅដាក់នៅកន្លែងកុមារ នៅកន្លែងមានមេដោះជួយមើល ហើយដល់ពេលចប់ការងារបានម្ដាយទៅយកកូនមកវិញ។ ដូច្នេះមិននៅជាប់ជាមួយខ្ញុំ ឬជាប់ជាមួយម្ដាយទេ ព្រោះយើងមានភារកិច្ចត្រូវធ្វើរៀងខ្លួន។ អ៊ីចឹងកូនត្រូវមានមេដោះមើលនៅមន្ទីរកុមារហ្នឹងមើល។ កន្លែងដែលមន្ទីរកុមារដែលមើលហ្នឹង នៅកន្លែងគរុកោសល្យចាស់។

**ស៖** នៅថ្ងៃបាត់ខ្លួននោះ តើលោកបានឃើញប្រពន្ធរបស់លោក ឬក៏ឃើញកូនរបស់លោកដែរឬទេ?

**ឆ៖** ឃើញអីទាំងអស់។

[១០:៣០:៤០]

**ស៖** តើ យុន យ៉ាត នៅក្រោយពេលបាត់ខ្លួននោះ ប្រពន្ធរបស់លោកបាត់ខ្លួននោះបានប្រាប់ហេតុផលទេ តើហេតុអ្វីបានជាប្រពន្ធរបស់លោកត្រូវបានចាប់ទៅហើយបាត់ខ្លួននោះ?

**ឆ៖** ក្រោយដែលខ្ញុំរៀនសូត្រជីវទស្សន៍ ធ្វើប្រវត្តិរូបហើយ គាត់ហៅទៅពីរនាក់ទាល់មុខគ្នា គាត់បានប្រាប់ដោយខ្លីថា ប្រពន្ធខ្ញុំគឺជាភ្នាក់ងារ សេ.អ៊ី.អា ជាខ្សែបណ្ដាញរបស់ សេ.អ៊ី.អា។ ប៉ុន្តែនៅពេលនោះអារម្មណ៍ខ្ញុំ ដូចខ្ញុំបាននិយាយពីខាងដើមអ៊ីចឹង ខ្ញុំអត់យល់ស្របទេ។ ព្រោះការរស់នៅជាមួយគ្នា វាតែងតែដឹងពីចំណុចខ្លាំងចំណុចខ្សោយរបស់ប្ដីប្រពន្ធ។ ហើយដែលបានរៀនសូត្រផ្សព្វផ្សាយពីរឿងខ្មាំងបីប្រភេទ ដូចខ្ញុំបានលើកអ៊ីចឹងតែងតែបានផ្សព្វផ្សាយ។ ម្ល៉ោះហើយសូម្បីតែប្ដីប្រពន្ធក៏អាចសង្កេតមើលសកម្មភាពរបស់ខ្លួនឯងដែរ។ អ៊ីចឹងហើយបានជាប្រពន្ធខ្ញុំពេលហ្នឹងតែងតែនិយាយថា មានមិត្តភក្ដិមួយចំនួនគេដកទៅឲ្យធ្វើស្រែ។ គាត់និយាយថាមានការព្រួយបារម្ភណាស់ ខ្លាចខ្ញុំហ្នឹងពាក់ព័ន្ធនឹងអ៊ីចឹង។ ខ្ញុំថា ខ្ញុំអត់មានអីពាក់ព័ន្ធទេ ខ្ញុំស្អាតស្អំ ខ្ញុំអត់មានពាក់ព័ន្ធនឹងនរណា។ ហើយខ្ញុំមិនដែលធ្វើការនៅកន្លែងតំបន់ កន្លែងភូមិភាគទេ ខ្ញុំនៅធ្វើការនៅកន្លែងមជ្ឈិម ដូច្នេះខ្ញុំ -- ថ្នាក់ដឹកនាំជាន់ខ្ពស់អាច

ស្គាល់ខ្ញុំច្បាស់ណាស់។ ខ្ញុំជឿថាគាត់មិនអាចសម្លាប់ខ្ញុំបានទេ។ ខ្ញុំតែងប្រាប់គាត់អ៊ីចឹង។

[១០:៣១:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីរូបនេះ ហើយនិងនៅក្នុងអំឡុងពេលឈប់សម្រាក និងហើយអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងដប់មួយ ខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ឬ/និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយសារពេលវេលាចុងក្រោយនៃភាគីនេះហើយ។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក គីម វុន ចម្លើយរបស់លោកដែលផ្តល់នៅចុងក្រោយនេះ គឺនិយាយពាក់ព័ន្ធទៅនឹងភរិយារបស់លោក។ ភរិយារបស់លោក គឺធ្វើការជិតស្និទ្ធជាមួយនឹងខាងមជ្ឈិម តែមិនពាក់ព័ន្ធជាមួយនឹងភ្នាក់ងារណាមួយនោះទេ។ ហើយខ្ញុំជំរុញឲ្យគាត់រឹងមាំ ដើម្បីឲ្យមានការប្រុងប្រយ័ត្ន។ តើលោកអាចជម្រាបបានដែរឬទេ ថាតើលោកនិយាយពាក្យបែបនេះ ដូចដែលខ្ញុំនិយាយប្រាប់លោកអំមិញហ្នឹងថាលោកនិយាយជាមួយគាត់ហ្នឹង នៅពេលណា?

[១០:៥២:៣២]

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំសូមកែបន្តិច ពាក្យថា ប្រពន្ធខ្ញុំធ្វើការនៅកន្លែងមជ្ឈិម។ ខ្ញុំចង់និយាយថា កាលពីជំនាន់សង្គ្រាមមក ធ្វើការងារនៅក្នុងអង្គភាពមជ្ឈិម មិនមែនទៅធ្វើជាមជ្ឈិមបក្សនោះទេ។ ហើយកាលណាដែលខ្ញុំនិយាយហ្នឹង គឺពេលដែលមានមនុស្សមួយចំនួនដែលខាងក្រសួងបានដកទៅឲ្យធ្វើស្រែ ឬក៏ផ្លាស់ការងារពីទីកន្លែងនោះ ប្រពន្ធខ្ញុំហាក់ដូចជាមានការភ័យភិតដែរ ខ្លួនខ្ញុំក៏ភ័យភិត ចេះតែមានការពិភាក្សាគ្នាដែរ ដូច្នេះ និយាយប្រាប់គ្នានៅពេលហ្នឹង។ ព្រោះពេលជួបគ្នា គឺពេលយើងឈប់ពីធ្វើការងារ មានតែសម្រាកនៅពេលយប់អីហ្នឹង ។

**ស៖** តើលោកអាចជម្រាបបានដែរឬទេ ថាតើប្រពន្ធលោកមានស្រុកកំណើតមកពីខាងណាដែរ?

**ឆ៖** ស្រុកកំណើតពិតប្រាកដ ដូចជាមិនជាក់លាក់ ហើយក៏មិនដឹងថាគាត់កើតនៅឯណា ព្រោះជាកូនរាជការ នៅក្នុងសង្គមចាស់ តែងតែផ្លាស់ប្តូរទីកន្លែង។ ឪពុកក្មេកខ្ញុំបាទ គាត់ជាមន្ត្រីបម្រើការងារនៅក្រសួងសាធារណការ ហើយគាត់មានភារកិច្ចបើកឡាន។ ដល់អីចឹងទៅ ការងារចេះតែផ្លាស់ពីកំពង់ធំ ទៅក្រចេះ ឬក៏ទៅកន្លែងផ្សេង។ បើគិតជាស្រុកកំណើតរបស់ឪពុកក្មេក គឺនៅខេត្តកំពង់ធំ នៅភូមិជ្រាប់ ស្រុកសន្ទុក ខេត្តកំពង់ធំ។

[១០:៥៤:៣១]

ឯម្តាយ គឺនៅភូមិវត្តព្រៃកព្រះអង្គ ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ប៉ុន្តែការងារជំនាន់ជិតរដ្ឋប្រហារ គាត់ទៅធ្វើការនៅខេត្តក្រចេះ។ ហើយប្រពន្ធខ្ញុំបាទ ក៏រៀនសូត្រអី ក៏នៅខេត្តក្រចេះហ្នឹងដែរ នៅនឹងទីប្រជុំជន អ៎! នៅក្នុងទីរួមខេត្ត។

**ស៖** លោក គឹម វុន នៅក្នុងចម្លើយជាមួយខាងសហចៅក្រមស៊ើបអង្កេត លោកនិយាយថា មានមនុស្សបាត់ខ្លួនក្នុងពេលប្រហែលគ្នាជាមួយនឹងប្រពន្ធរបស់លោកដែរ។ លោកនិយាយអំពី ប៉ង់, កត់, ហើយនិង ឆយ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ បងឆយ គឺថាផ្លាស់ទីកន្លែងធ្វើការងារ ក៏ខ្ញុំមិនដឹងថាគាត់ផ្លាស់នៅកន្លែងណា។

**ស៖** ពាក់ព័ន្ធទៅនឹងឈ្មោះ កត់ មុនពេលដែល កត់ បាត់ខ្លួនហ្នឹង តើ កត់ ហ្នឹង គាត់មានតួនាទីអ្វីដែរ មុនពេលដែលបាត់ខ្លួន?

**ឆ៖** កត់ មានតួនាទីដឹកនាំដូចប្រពន្ធខ្ញុំដែរ។ គាត់ជាអនុប្រធានមន្ទីរឃោសនាការ។ ក្រោយមក -- អង្គាល់មុនគាត់ទៅនៅខាងផ្នែកកាសែតទាំងអស់គ្នាទេ ប៉ុន្តែក្រោយមកមានការចាត់តាំងពីរដ្ឋមន្ត្រីឱ្យទៅធ្វើការងារដឹកនាំនៅឃោសនាការហ្នឹង មាន បងឆយ ប្រធាន, មាន កត់ អនុប្រធាន ប៉ុន្តែទទួលបន្ទុកខាងអីក៏ខ្ញុំមិនដឹងដែរ ហើយនិងប្រពន្ធខ្ញុំ គាត់អនុប្រធានដែរ ប៉ុន្តែការងាររបស់គាត់នៅកន្លែងនោះការងារបច្ចេកទេស គឺអានវិទ្យុ។

[១០:៥៦:៥៣]

**ស៖** លោកក៏បានបន្ថែមផងដែរថា ប្រធានមន្ទីរឃោសនាការក៏បាត់ខ្លួន គឺមានទាំងឈ្មោះ ហ៊ូ នឹម ហើយនិង ទីវ អុល។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** តាមពិតតាំងពីមុនមក ខ្ញុំឮតាមមិត្តភក្តិទេ ឮថាមេខ្ញុំចាស់មានលោក ហ៊ូ នឹម, លោក ទីវ អុល កាលពីជំនាន់សង្គ្រាម៥ឆ្នាំ គឺគាត់ជាមេខ្ញុំ។ គាត់ជារដ្ឋមន្ត្រីក្រសួងឃោសនាការ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍កាលពីមុនរបស់លោក ពាក់ព័ន្ធទៅនឹង កុយ ធួន លោកនិយាយថា លោកដឹងថាគេចាប់ខ្លួន។ ខ្ញុំសូមដកស្រង់៖ "ដោយសារតែខ្ញុំអានទស្សនាវដ្តីទង់បដិវត្ត ហើយទំព័រទាំងអស់ហ្នឹង គឺៗនិយាយអំពីចម្លើយសារភាពរបស់ កុយ ធួន"។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ប្រហែលជាលោកពិបាកក្នុងការឆ្លើយ ប៉ុន្តែលោកអាចជម្រាបបានដែរឬទេ ថាតើនៅក្នុងឆ្នាំណាដែលលោកអានទស្សនាវដ្តីទង់បដិវត្តនោះ?

[១០:៥៨:១៣]

**ឆ៖** មកដល់ពេលនេះ ខ្ញុំដូចជាភ្លេចភ្លាំង ប៉ុន្តែខ្ញុំចំណាប់អារម្មណ៍ក្នុងក្បាលទស្សនាវដ្តី គឺខ្ញុំចាប់អារម្មណ៍លោក កុយ ធួន ច្រើនជាងគេ ព្រោះនៅក្នុងទំព័រទាំងអស់គឺ សុទ្ធតែជាចម្លើយរបស់លោក កុយ ធួន ទាំងអស់។ ឯពេលនៅឆ្នាំណា ខ្ញុំមិនចាំ។

**ស៖** សូមអរគុណ។ ពាក់ព័ន្ធទៅនឹងក្រសួងឃោសនាការវិញ គឺក្រសួងឃោសនាការអប់រំក្រោយពេលបាត់ ហ៊ូ នឹម តើជាការត្រឹមត្រូវដែរឬទេ ដែលថា យុន យ៉ាត គាត់មកកាន់ក្រសួងទាំងពីរនេះតែម្តង?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** លោកក៏បានបញ្ជាក់នៅក្នុងចម្លើយរបស់លោកកាលពីមុន ដែលនិយាយថា គឺមានពេល

មួយដែល នួន ជា គាត់ទទួលខុសត្រូវខាងឃោសនាការ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បើនិយាយមែនទែនទៅ ការងារថ្នាក់ដឹកនាំមិនមែនជាការងារជំនាញរបស់គាត់ទេ។ ប៉ុន្តែ ក្នុងពេលរដ្ឋមន្ត្រី យុន យ៉ាត មិនមានវត្តមាន គឺគាត់ចុះទៅផ្ទាល់នៅកន្លែង ជួយមើលការខុសត្រូវ។

[១០:៥៩:៥៣]

**សៈ** លោកនិយាយថា ពាក់ព័ន្ធទៅនឹងរយៈពេលក្រោយពេលដែលគេចាប់ប្រពន្ធលោកទៅហ្នឹង គឺគេបញ្ជូនលោកទៅរៀននយោបាយប្រហែលជាកន្លះខែ។ ថាតើខ្លឹមសារនៃការរៀនសូត្រនយោបាយហ្នឹង គឺមានអ្វីខ្លះ? តើលោកអាចជម្រាបបានដែរឬទេ? ហើយក្នុងនេះលោកនិយាយថា រៀបឲ្យ -- រៀបចំខ្លួនដើម្បីកសាងប្រទេស និងដើម្បីប្រយុទ្ធប្រឆាំងនឹងខ្មាំងដែលបង្កប់ខ្លួន។ ដូច្នេះហើយត្រូវមានការប្រុងប្រយ័ត្ន តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**សៈ** ពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងចំពោះលោក តើវាជាការត្រឹមត្រូវដែរឬទេ ថានៅក្នុងពេលមួយនោះ គេបញ្ជូនលោកទៅធ្វើការ ធ្វើជាប្រធានវិទ្យុកម្ពុជា -- ប្រធានកម្មវិធីវិទ្យុកម្ពុជាប្រជាធិបតេយ្យ។ តើត្រឹមត្រូវឬទេ? គឺវិទ្យុកម្ពុជាក្រោម សូមអភ័យទោស។

**ឆ៖** បាទ ត្រឹមត្រូវ។

[១១:០១:០០]

**សៈ** នៅពេលលោកធ្វើជាប្រធានកម្មវិធីវិទ្យុហ្នឹង តើលោកធ្វើការនៅក្រសួង នៅភ្នំពេញ ឬមួយក៏នៅកន្លែងណាផ្សេង?

**ឆ៖** ខ្ញុំធ្វើការនៅក្នុងក្រសួងឃោសនាការទាំងអស់ គ្រាន់តែបែងចែកតាមផ្នែកភាសាផ្សេងៗពីគ្នា។

**សៈ** លោក គឹម វុន នៅក្នុងចម្លើយនៅក្នុងចម្លើយនៃការសម្ភាសរបស់លោកពីលើកមុន គឺឯកសារ E3/381 ខ្មែរមានលេខ 00357205, ភាសាបារាំង គឺមានលេខ 00402997, និងភាសាអង់គ្លេសមានលេខ 00365528។ គេសួរលោកអំពីការផ្សព្វផ្សាយ អំពីខ្លឹមសារនៃការផ្សព្វផ្សាយនៅពេលដែលលោកនៅជាប្រធានកម្មវិធីវិទ្យុកម្ពុជាក្រោម។ ហើយលោកនិយាយអំពីកម្មវិធីវិទ្យុដទៃទៀត ហើយលោកនិយាយថា "មានកម្មវិធីមួយដែលផ្សាយជាភាសាវៀតណាម ដែលធ្វើឡើងដោយ ប៉ា(ស៊ីក) មកពីខាងវៀតណាមខាងជើង ដែលនិយាយអំពី ១ការចាប់ខ្លួនវៀតណាម ឬក៏និយាយអំពីការដោះ -- ចម្លើយ

សារភាពរបស់វៀតណាម"។ តើត្រឹមត្រូវដែរឬទេ?

[១១:០២:៤៦]

**ឆ៖** *(មីក្រូហ្វូនមិនដំណើរការ)* ត្រូវ។

**ស៖** គឹម វុន តើលោកចាំដែរឬទេ ថាតើកម្មវិធីនេះមានឈ្មោះអ្វីដែរ គឺកម្មវិធីដែលផ្សាយពីចម្លើយសារភាពឈ្លើយសឹកវៀតណាមនោះ តើកម្មវិធីនោះមានឈ្មោះអ្វីដែរ?

**ឆ៖** តាមខ្ញុំចាំ ដូចជាថា ភស្តុតាងដែលមិនអាចប្រកែកបានរបស់ខ្មាំងយួនឈ្លានពាន។

**ស៖** តើកម្មវិធីវិទ្យុ ឬក៏ការផ្សព្វផ្សាយបែបណាដែលគេផ្សព្វផ្សាយអំពីចម្លើយសារភាពនេះ?

**ឆ៖** ចម្លើយសារភាព គឺមានយកសំឡេងផ្ទាល់របស់កងទ័ព។

**ស៖** ឥឡូវនេះ ក្នុងមានលោកជាប្រធានកម្មវិទ្យុកម្ពុជាក្រោម តើអ្នកណាជាអ្នកទទួលខុសត្រូវ ឬក៏ចូលរួមនៅក្នុងការជ្រើសរើសឯកសារ ឬក៏ជ្រើសរើសព័ត៌មានដែលត្រូវផ្សព្វផ្សាយ?

[១១:០៤:៣៣]

**ឆ៖** ព័ត៌មានដែលទទួលបាន មានប្រភពពីរ។ ទី១ ប្រភពដែលយកព័ត៌មានពីព្រំដែន។ ទី២ យើងសរសេរបំបែកប្រភពតាមព័ត៌មានចេញពីចម្លើយរបស់ឈ្លើយសឹកវៀតណាមខ្លះ។ ព្រោះឈ្លើយសឹកវៀតណាម និងខ្មែរក្រោម វាបើគិតយើង ជាភូមិសាស្ត្រគឺនៅក្នុងទឹកដីរបស់គេ។ ដូច្នេះ ចម្លើយខ្លះអាចមានការពាក់ព័ន្ធ ប៉ុន្តែកន្លែងដែលយើងមិនយល់អំពីភាសាយួន យើងឲ្យខាងភាសាយួនជួយប្រាប់ខ្លះដើម្បីយើងដឹងភូមិសាស្ត្រ ទឹកដីកម្ពុជាក្រោមយ៉ាងណាៗ ព្រោះយើងមិនបានចុះទៅដល់ទឹកដីរបស់គេទេ។ បើសម័យនោះយើងអាចបានទៅ តែត្រឹមភ្នំដិន ហើយមិនមែនទៅក្នុងជំនាន់ខ្ញុំធ្វើការជាភាសាកម្ពុជាក្រោមហ្នឹងទេ គឺធ្លាប់ដឹងព័ត៌មានដែលនៅវិទ្យុកម្ពុជាប្រជាធិបតេយ្យយើងធ្លាប់បានដើរទៅ ដឹងពីភូមិសាស្ត្រខ្លះ។ ប៉ុន្តែចូលជ្រៅទៅដល់ខាងក្នុង យើងមិនទទួលបានព័ត៌មានទេ។ បើចង់បានទទួលព័ត៌មានពិត ចង់ដឹងភូមិសាស្ត្រ យើងជួបនឹងខ្មែរក្រោមដែលភៀសខ្លួនមកព្រំដែន មកស្រុកខ្មែរយើងពេលដែលមានកើតវឹកវរនៅយួនខាងត្បូង។

[១១:០៦:២០]

**ស៖** សូមអរគុណ។ នៅពេលនេះសូមឲ្យលោកផ្តោតជាសំខាន់ទៅលើកម្មវិធី វិទ្យុកម្ពុជាក្រោមដែលលោកកាន់កាប់។ តើមានធ្លាប់ផ្សាយនូវសុន្ទរកថាណាមួយដែរឬទេ?

**ឆ៖** កម្មវិធីរបស់ខ្ញុំអត់មានទេ មានតែផ្សាយអត្ថបទដែលយើងសរសេរដោយខ្លួនយើងផ្ទាល់

ហើយនិងសំឡេង សំឡេងជាខ្មែរក្រោម។

**ស៖** លោក គីម វុន ខ្ញុំចង់សួរអំពីអតីតប្រពន្ធរបស់លោកឡើងវិញ។ នៅក្នុងចម្លើយមុខចៅក្រមស៊ើបអង្កេតនោះ លោកបានឆ្លើយថា "គឺខ្ញុំមិនច្បាស់ថា គាត់នៅរស់ឬក៏ស្លាប់នោះទេ ក៏ប៉ុន្តែខ្ញុំលែងឮដំណឹងពីគាត់ទៀតហើយ"។ ថាតើត្រឹមត្រូវដែរឬទេ នេះជាចំណុចដែលលោកបាននិយាយ។

**ឆ៖** ត្រឹមត្រូវបាទ។

[១១:០៧:៣០]

**ស៖** តើនៅពេលនេះ ចាប់ពីឆ្នាំ១៩៧៧ មកនោះ លោកនៅតែមិនដឹងអំពីគាត់ដដែល។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** មកដល់ពេលនេះ ខ្ញុំនៅតែអត់ដឹងព័ត៌មានអ្វីទាំងអស់។

**ស៖** ដើម្បីឲ្យខ្ញុំយល់ឲ្យច្បាស់ តាំងពីឆ្នាំ៧៧ មក តើមាននរណាដែលជាអ្នកថ្នាក់លើរបស់លោក ធ្លាប់បានបង្ហាញឯកសារណាមួយដើម្បីឲ្យលោកនោះបានដឹងឲ្យបានប្រាកដថា តើវាមានអ្វីកើតឡើងចំពោះជោគវាសនារបស់ប្រពន្ធលោក?

**ឆ៖** តាំងពីនោះមកខ្ញុំអត់ដែលបានទទួលព័ត៌មានអីក្រៅពីការរៀនសូត្រ ហើយដែលគាត់ប្រាប់ការពិតថា ប្រពន្ធខ្លួនឯងជាភ្នាក់ងារខ្សែបង្កប់របស់ សេ.អ៊ី.អា។

**ស៖** លោក គីម វុន ប្រសិនបើមានឯកសារណាមួយនៅសល់ តើលោកចង់អានដោយផ្ទាល់ភ្នែករបស់លោកដើម្បីឲ្យលោកស្ងប់អារម្មណ៍ដែរឬទេ អំពីបញ្ហានេះ?

[១១:០៩:០៨]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំយល់អំពីការសួរសំណួរនេះ ក៏ប៉ុន្តែវាហាក់ដូចជាមិនសមរម្យ ហើយមិនសមទៅនឹងអ្វីដែលយើងសួរចំពោះសំណួរបែបនេះ។

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំគិតថា នេះមិនមែនជាការជំទាស់ផ្លូវច្បាប់ទេ ពីខាងមេធាវីការពារក្តី។ ដូច្នេះហើយ ខ្ញុំសូមនៅតែអនុញ្ញាត -- ឲ្យលោកប្រធានអនុញ្ញាតឲ្យខ្ញុំបង្ហាញឯកសារនេះទៅកាន់សាក្សី។

[១១:០៩:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១១:៤៤]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអាចបង្ហាញអត្តសញ្ញាណឯកសារ ដែលលោកមានការបំណងសួរដេញដោលចំពោះសាក្សីនៅសំណួរចុងក្រោយអម្បាញ់មិញនេះទេ? ហើយនិងប្រធានបទអីទៅដែលនៃខ្លឹមសារនៃឯកសារនោះ?

**លោក ឃីត រេយ៍ន័រ៖**

ឯកសារនោះមានលេខ E3/342។ បញ្ជីអ្នកទោសដែលបាន -- បញ្ជីអ្នកទោសស-២១ ដែលបានកែប្រែរួចមកហើយ។ អ្វីដែលខ្ញុំចង់សួរនោះ គឺវាពាក់ព័ន្ធទៅនឹងអ្វីដែលលោកសាក្សី គីម វុន បាននិយាយអំពីការបាត់ខ្លួនប្រពន្ធរបស់គាត់។ គាត់មិនដឹងថាមានអ្វីកើតឡើងចំពោះប្រពន្ធរបស់គាត់។

ដូច្នេះ តាមចម្លើយដែលគាត់ប្រាប់អង្គជំនុំជម្រះនោះ គឺវាសមរម្យដែលគាត់ត្រូវដឹងអំពីបញ្ហានេះ។ ដោយសារហេតុផលនេះហើយ ហើយក្នុងន័យមនុស្សធម៌ចំពោះគាត់ ទើបខ្ញុំសូមដាក់បង្ហាញនិងលើកឯកសារនេះជូនទៅដល់គាត់។ សូមអរគុណ។

[១១:១៣:០៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា មុន។ សូមអញ្ជើញ!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា យើងកំពុងតែមិនបានពិចារណាទៅលើការជំទាស់ផ្លូវច្បាប់នៅពេលនេះ នៅពេលដែលសហព្រះរាជអាជ្ញាគាត់សួរថា តើសាក្សីចង់ឃើញឯកសារនេះដែរឬទេ?

ខ្ញុំសូមសន្និដ្ឋានថា ប្រសិនបើយើងនិយាយអំពីបញ្ហាមនុស្សធម៌ វាជាបញ្ហាមនុស្សធម៌ដែលត្រូវ

ផ្តល់ជូនសាក្សីនេះនូវឱកាស និងលទ្ធភាពពិចារណា និងពិនិត្យមើលឯកសារនេះជាលក្ខណៈឯកជន មិនមែនក្នុងតុលាការជាសាធារណៈនោះទេ។ ប្រសិនបើឯកសារនេះមានមែននោះ ភាគីអាចកត់សម្គាល់បាន ហើយក្នុងន័យមនុស្សធម៌នោះ មិនចាំបាច់បង្ហាញឯកសារនេះជាលក្ខណៈនៅក្នុងតុលាការនេះនោះទេ។ យើងដឹងហើយថា ដើម្បីសុខមាលភាព និងដើម្បីជាប្រយោជន៍ទៅដល់សាក្សីនេះ គឺយើងគួរតែបង្ហាញឯកសារនេះជូនទៅសាក្សីក្នុងលក្ខណៈឯកជន ដែលវាជាលក្ខណៈមនុស្សធម៌ចំពោះគាត់។

[១១:១៤:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន សូមគោរពលោកប្រធាន។ ខ្ញុំសូមអន្តរាគមន៍ដោយខ្លី ដើម្បីគាំទ្រសហភាតារបស់ខ្ញុំ។ ខ្ញុំគិតថា ជាការពិតណាស់ចំពោះសាក្សី បើសិនជាមានឯកសារពាក់ព័ន្ធនឹងគ្រួសាររបស់គាត់ គាត់មានសិទ្ធិដឹងអំពីឯកសារទាំងអស់។ ក៏ប៉ុន្តែបើយើងគិតអំពីមនុស្សធម៌នោះ មិនត្រូវធ្វើយ៉ាងនេះទេ ជាការ -- ហើយជាការពិតណាស់ដែលថាកន្លែងនេះមិនមែនជាកន្លែងសមស្របទេ ក្នុងការដែលឲ្យសាក្សីនេះអានអំពីព័ត៌មានដែលដឹងអំពីព័ត៌មានទាក់ទងនឹងគ្រួសាររបស់គាត់ ទោះបីយ៉ាងណាក្តីទង្វើអាក្រក់វាបានធ្វើហើយទៅហើយ។ ហើយអ៊ីចឹងសូមឲ្យតុលាការប្រព្រឹត្តទៅលើបុគ្គលគ្រប់រូបនៅក្នុងសាលសវនាការនេះ ឲ្យគិតអំពីសិទ្ធិរបស់គាត់ ហើយសិទ្ធិជាឯកជនរបស់គាត់ទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

នេះគឺជាគោលបំណងនៃការជំទាស់របស់ខ្ញុំហើយលោកប្រធាន ដែលថាក្នុងន័យមនុស្សធម៌ហ្នឹងគួរតែធ្វើដូចអ្វីដែលបានលើកឡើង។

[១១:១៥:៤៥]

**លោក ឃីត រេយ៉ន័រ៖**

គឺខ្ញុំបានស្តាប់--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា អ៎! ដើមបណ្តឹងរដ្ឋប្បវេណីមុនណ៎ះ! មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រដល់ខាងការពារក្តីដែរ ក្នុងការលើកគំនិតនេះឡើងគឺថា ត្រូវ -- យើងអាចពិភាក្សា -- យើងអាចដាក់ចូលក្នុងការពិភាក្សាបាន ក៏ប៉ុន្តែសាក្សីនេះ បើចង់ដឹងអំពីឯកសារនេះ គាត់អាចមើលឯកសារនេះក្នុងលក្ខណៈជាឯកជនទៅកុំឲ្យមកមើលនៅក្នុងសាលសវនាការនេះ។

[១១:១៦:២៨]

**លោក ឃីត រេយ៉ន័រ៖**

អ្វីដែលខ្ញុំចាប់អារម្មណ៍នេះគឺថា លោក គឹម វុន នោះ គឺគាត់អាចទទួលឯកសារនេះបាន ប្រសិនបើគាត់ចង់បាននោះ។ ខ្ញុំទុកឲ្យលោកប្រធានជាអ្នកសម្រេចទៅលើបញ្ហានេះ។

[១១:១៦:៤១]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៨:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដោយសារបញ្ហាស្នើសុំដាក់ឯកសារចុងក្រោយ ដើម្បីដេញដោល ឬក៏សួរទៅសាក្សីរូបនេះ ដោយតំណាងសហព្រះរាជអាជ្ញាហ្នឹង ឃើញថាមានមតិជំទាស់ជាច្រើនទាំងភាគីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផង ហើយគឺក្នុងន័យគោលការណ៍មនុស្សធម៌ផង។ ហើយជាការសមស្របណាស់ដែលការបង្ហាញឯកសារប្រភេទនេះ ចំពោះសាក្សីជាលក្ខណៈឯកជន ហើយគួរតែត្រូវបានធ្វើតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ ដូច្នេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យដាក់បង្ហាញឯកសារសាក្សីនេះទៅ ជូនទៅ -- ដាក់បង្ហាញឯកសារនេះ ជូនទៅសាក្សីនៅពេលនេះទេ។

ហើយតំណាងសហព្រះរាជអាជ្ញា បើសិនជាមានសំណួរអ្វីចង់សួរទៀត សូមអញ្ជើញ! ហើយសូមប្រាប់ផងថា តើការបែងចែកពេលវេលារវាងតំណាងសហព្រះរាជអាជ្ញា និងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងម៉េចដែរ? ពីព្រោះពេលវេលាកាន់តែកៀកនឹងដល់ពេលត្រូវ

សម្រាកហើយ នៅតែ៤០មីនុត ទៀតប៉ុណ្ណោះ។

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន ដែលបានបញ្ជាក់បំភ្លឺត្រង់ចំណុចនេះ។

នៅពេលនេះខ្ញុំពុំមានសំណួរបន្ថែមទៀតទេ ដូច្នេះខ្ញុំសូមផ្ទេរវេទិកាម៉ោងនេះទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១១:២០:៥៧]

**លោកស្រី បេនី យេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំនឹងសួរសំណួររបស់ខ្ញុំនេះ គឺឲ្យបានចប់មុនពេលអាហារថ្ងៃត្រង់ ក៏ប៉ុន្តែបើសិនមិនអាចទេនោះ ខ្ញុំសូមបន្ត១៥នាទីទៀត ក្រោយពេលអាហារថ្ងៃត្រង់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! ជាក់ស្ដែងសិន តើភាពពាក់ព័ន្ធនៃការតាំងសំណួរនេះយ៉ាងដូចម្ដេច? ហើយលទ្ធភាព១៥មីនុតហ្នឹង អង្គជំនុំជម្រះនឹងពិចារណាជាក់ស្ដែងនៅពេលចុងម៉ោងនេះ។ អង្គជំនុំជម្រះនឹងប្រឹងប្រែងខិតខំគ្រប់គ្រងសវនាការធ្វើយ៉ាងណាឲ្យមានប្រសិទ្ធភាពតាមពេលវេលាដែលបានកំណត់។ ដូចបានកំណត់រួចហើយ ចៀសវាងកំណត់ហើយពន្យារពេលៗ ដដែលហ្នឹងឃើញថា ទំនងជាកិច្ចការសម្រេចសេចក្ដីក្នុងការគ្រប់គ្រងដឹកនាំសវនាការរបស់អង្គជំនុំជម្រះមិនមានប្រសិទ្ធភាពទេ។ អង្គជំនុំជម្រះធានា និងប្រឹងប្រែងគ្រប់គ្រងកិច្ចដំណើរការធ្វើយ៉ាងណាឲ្យមានប្រសិទ្ធភាពកាន់តែខ្ពស់ កាន់តែមានប្រសិទ្ធភាពខ្លាំងឡើង។

**លោកស្រី បេនី យេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពអស់លោក លោកស្រីក្រុមប្រឹក្សាជំនុំជម្រះ។ ខ្ញុំ បេនី យេ ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១១:២២:១៨]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** លោក គឹម វុន ចំណុចទី១នេះ ខ្ញុំចង់និយាយអំពីពេលដែលលោកមកដល់ទីក្រុងភ្នំពេញ។ លោកថា លោកមកដល់ភ្នំពេញនៅថ្ងៃទី២០ មេសា ឆ្នាំ១៩៧៥។ ខ្ញុំចង់សួរថា នៅពេលដែលលោកចូលមកដល់ភ្នំពេញនោះ តើស្ថានភាពនៅក្នុងក្រុងនេះយ៉ាងម៉េចដែរ? តើលោកបានឃើញអ្វីខ្លះ?

**លោក គឹម វុន៖**

**ឆ៖** ជារួមនៅភ្នំពេញ ក្រោយថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ ឃើញមិនសូវមានមនុស្សដូចកាលមុនទេ។ មនុស្សមានតិចតួច មានតែកងទ័ព មានតែក្រសួងមន្ទីរតាមកន្លែង១ខ្លះ មិនមានមនុស្សកកកុញដូចជំនាន់មុនទេ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី បន្ថយល្បឿននៅក្នុងការនិយាយ! និយាយឲ្យបានយឺតបន្តិច ដើម្បីមានផ្តល់លទ្ធភាពជូនទៅខាងអង្គភាពបកប្រែ អាចបានបកប្រែពេញលេញនៅក្នុងពាក្យពេចន៍ដែលលោកស្រីបាននិយាយ។

[១១:២៣:៣០]

**លោកស្រី បេនី យេ៖**

លោកប្រធាន ខ្ញុំនឹងធ្វើតាម។

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** តើលោកឃើញមានប្រជាជនស៊ីវិលកំពុងតែចាកចេញពីទីក្រុងដែរឬទេនៅពេលនោះ?

**លោក គឹម វុន៖**

**ឆ៖** នៅពេលនោះខ្ញុំអត់បានឃើញទេ ព្រោះប្រជាជនជម្លៀសចេញទៅអស់ហើយ។

**ស៖** នៅពេលដែលលោកនិយាយថា ឃើញទាហាននោះ ទាហានកំពុងធ្វើអ្វីដែរ?

**ឆ៖** ទាហានមែនទែនមានតែទាហានជាកងទ័ពរណសិរ្សចូលទៅក្នុងក្រុងភ្នំពេញ នៅតាមអង្គភាពរបស់គេ។ ព្រោះកន្លែងគេមានបែងចែកកន្លែងណាដែលគេស្នាក់នៅបាន។

**ស៖** នៅពេលដែលលោកនិយាយថា លោកមកដល់ថ្ងៃទី២០ ខែមេសា នោះ តើលោកបានធ្វើដំណើរមកជាមួយនឹងក្រុមវិទ្យុពីស្ទឹងត្រង់ ឬក៏យ៉ាងម៉េច?

**ឆ៖** តាមពិត វិទ្យុរណសិរ្សក្រុងភ្នំពេញគេមកមុនយូរហើយ ព្រោះវិទ្យុជាវិទ្យុចល័ត ឯខ្ញុំ ខ្ញុំមកតាមក្បួនឡានផ្សេង ដឹកសម្ភារៈតិចតួចខាងផ្នែករោងពុម្ព មកតាមក្រោយ មកតាមផ្លូវចម្ការលើ ចម្ការអណ្ដូងចុះពីលើមក ចុះមកក្រោមវិញ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចូលទៅដល់ប្រធានបទមួយទៀត លោកបានលើកឡើងថា នៅចន្លោះឆ្នាំ៧៥ រហូតមកដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យលោកបានធ្វើការងារជាអ្នកនិពន្ធសារព័ត៌មាន ក្រោយមកលោកជាប្រធានវិទ្យុកម្ពុជាក្រោម។ ខ្ញុំចង់លើកឡើងអំពីពេលវេលាដែលលោកធ្វើជាអ្នកនិពន្ធព័ត៌មាន។ តើលោកចាប់ផ្ដើមធ្វើការងារជាអ្នកនិពន្ធព័ត៌មាននេះពីពេលណាមក នៅក្រសួងឃោសនាអប់រំនោះ?

[១១:២៦:០៧]

**ឆ៖** តាមពិតទៅ ខាងផ្នែកនិពន្ធនេះកិច្ចការសំខាន់របស់ខ្ញុំតាំងពីជំនាន់រណសិរ្ស ខ្ញុំធ្វើការតែខាងផ្នែករោងពុម្ពទេ។ ប៉ុន្តែនៅពេលខ្លះ ដូចខ្ញុំបានលើកខាងដើម ខ្ញុំក៏អាចចូលរួមជាមួយលោក ហ៊ូ នឹម ឬក៏ ទីវ អុល ក្នុងការតែងនិពន្ធជាអត្ថបទខ្លះជាជំនួយរបស់គាត់ នៅពេលខ្លះទេ ព្រោះការងារខ្ញុំជាមូលដ្ឋានគឺការងាររោងពុម្ព។ ដូច្នេះមានតែលោកទាំងពីរហ្នឹង អាចបណ្ដុះបណ្ដាលខ្ញុំតាំងពីពេលនោះមកបើគិតទៅ ប៉ុន្តែការងារស្នូលខ្ញុំមិនអនុគ្រោះឲ្យទៅធ្វើការងារនិពន្ធនេះទេ។ ទើបពេលចូលភ្នំពេញហើយក្រោយពីរៀបចំក្រុមថតរូបអីដែលនៅក្រោមការដឹកនាំរបស់ខ្ញុំហើយ បានលោកស្រី យុន យ៉ាត បានចាត់តាំងខ្ញុំឲ្យចូលមកក្នុងការងារនិពន្ធនេះមែនទែន គឺនៅក្នុងឆ្នាំ១៩៧៥ ហើយ។

**ស៖** សូមអរគុណ។ ដូច្នេះ លោកចាប់ផ្ដើមនិពន្ធសារព័ត៌មាននេះក្រោយជ័យជម្នះហ្នឹង ឬក៏លោកចាប់ផ្ដើមនិពន្ធព័ត៌មានហ្នឹងមុនពេលយូរមកហើយ?

**ឆ៖** តាមពិតទៅការងារនេះ តាំងពីជំនាន់លោករដ្ឋមន្ត្រី ហ៊ូ នឹម នៅ។ ប៉ុន្តែដូចខ្ញុំបានជម្រាបអីចឹងនៅក្នុងរោងពុម្ពរបស់ខ្ញុំ ខ្ញុំអាចជួយការងារសិល្បៈផង ជាថតរឿង ជាចម្រៀង ហើយនិងការងារនិពន្ធជាកំណាព្យអី គឺដូចខ្ញុំបាននិយាយពីខាងដើម។ ជំនាន់រណសិរ្ស គឺខ្ញុំបានធ្វើការងារច្រើន ក្រៅពីការងាររោងពុម្ពហ្នឹងគឺមានការងារសិល្បៈ ជាសិល្បៈសម្ដែង ជាច្រៀងចម្រៀង ព្រោះអង្កាល់នោះយើងអត់ទាន់មានក្រុមសិល្បៈអីច្រើនគ្នាទេ។ ដូច្នេះកម្លាំងនៅក្នុងរោងពុម្ពហ្នឹងត្រូវជួយគ្នាទៅវិញទៅមក គេក៏ជួយយើងធ្វើរោងពុម្ព យើងក៏អាចជួយសិល្បៈហ្នឹងបានដែរ។

[១១:២៨:៣៣]

ដូច្នេះការងារនិពន្ធវាចាប់ផ្ដើមតាំងពីជំនាន់នៅជាមួយលោក ហ៊ូ នឹម ម៉្ដេះ។ ឯអង្កាល់ពីឆ្នាំ៧១ នោះ ខ្ញុំអត់ទាន់ទេ ព្រោះអង្កាល់នោះខ្ញុំគ្រាន់តែសរសេរលើក្រដាសផ្ចិតកាបូន និងសរសេរជានៅលើ*ឥង់ស៊ីលេ*តប៉ុណ្ណោះ។ ហើយក្រោយមក ការងារដូចខ្ញុំបាននិយាយ ដោយមិនមានកម្លាំងច្រើនអ៊ីចឹង ចេះតែមានការជួយគ្នាទៅវិញទៅមក ហើយពេលខ្លះរដ្ឋមន្ត្រីក្រសួងឃោសនាការក៏គាត់ត្រូវការមានជំនួយជួយគាត់អ៊ីចឹងទៅ។ល។ ដូច្នេះដូចជាបង្រៀនខ្ញុំឲ្យចេះហ្នឹងដែរ។ អ៊ីចឹងបានពេលអត្ថបទខ្លះដែលទាក់ទងនឹងឯកសាររបស់បក្សឲ្យខ្ញុំយកមកប្រែជាសម្រាយមកវិញ ហើយនិងកាត់ចោលកន្លែងខ្លះ។ យើងទៅកាត់ចោលពាក់កណ្ដាលអ៊ីចឹងទៅ ឬក៏ជាងពាក់កណ្ដាលអ៊ីចឹង។ យើងបង្រួមយកធ្វើជាខ្លឹមសាររណសិរ្សវិញ។ អាហ្នឹងជាភារកិច្ចដែលខ្ញុំត្រូវធ្វើហ្នឹង គឺមានតាំងពីនុ៎ងមក។

[១១:២៩:៤៥]

**ស៖** ខ្ញុំសូមបញ្ជាក់បំភ្លឺជាមុន ទី១ ខ្ញុំនិយាយអំពីក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ ជាមុន។ ខ្ញុំយល់ថានៅពេលនោះ លោកត្រូវបានគេតែងតាំងឲ្យធ្វើជាអ្នកនិពន្ធកាសែត។ ដូច្នេះ ខ្ញុំចង់ដឹងថា តើក្រោយរំដោះភ្លាមៗនៅថ្ងៃ១៧ ខែមេសា នោះ ដែលលោកត្រូវបានគេតែងតាំងអ្នកនិពន្ធសារព័ត៌មាន ឬក្រោយរំដោះយូរទៀត ទើបគេតែងតាំង?

**ឆ៖** មែនទែនមុនដំបូង ដូចខ្ញុំនិយាយពីខាងដើម។ មុនដំបូង ខ្ញុំត្រូវទៅដឹកនាំក្រុមថតរូប។ រៀនអំពីបញ្ហាថតរូបហ្នឹង ឲ្យចេះទាំងអស់គ្នាទៅ ព្រោះការរៀនថតរូបហ្នឹង ដើម្បីយើងបង្កើតអី យើងបង្កើតពីរ ឬក៏បី ក្នុងកាមេរ៉ាហ្នឹង វាមានបីផ្នែក ទី១ ថតខ្សែភាពយន្តដែរ។ ទី២ ថតរូបភាពសម្រាប់ទស្សនាវដ្ដីរូបភាពនិងកាសែត។ ដូច្នេះ ការងារខ្ញុំហ្នឹងអង្កាល់ហ្នឹងដឹកនាំរៀនហើយ ហើយខ្ញុំចេះតែនៅពាក់ព័ន្ធនឹងរឿងនិពន្ធហ្នឹងដែរ ប៉ុន្តែមិនទាន់ពេញទេ ព្រោះខ្ញុំវាជាប់រវិលខាងផ្នែកថតរូប។ ប៉ុន្តែខ្ញុំនៅជាអ្នកនិពន្ធ ប៉ុន្តែវាមិនទាន់សរសេរអីបានច្រើនទេ គ្រាន់តែឆ្លៀតពេលខ្លះ សរសេរជាដំណឹង។

[១១:៣១:៤១]

**ស៖** ដូច្នេះ លោកជាអ្នកសរសេរនូវការប្រកាសតែប៉ុណ្ណោះ។ តើលោកធ្លាប់សរសេរព័ត៌មានស្ដីអំពីការជម្លៀសទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** នៅពេលនោះ ប្រធានបទដែលនិយាយថា “ជម្លៀសពីទីក្រុងភ្នំពេញ” មិនមានទេ។ ប្រធានបទសំខាន់ដែលខ្ញុំត្រូវសរសេរសម័យនោះ គឺដូចខ្ញុំបានលើកពីខាងដើមជាបន្តបន្ទាប់ គឺសរសេរពីរឿងកិច្ចការពារប្រទេស និងការកសាងប្រទេស។ សំខាន់ លើការកសាងប្រទេស គឺខ្ញុំតែងតែដើរទៅមូលដ្ឋាន

យកព័ត៌មាន ពីចលនាមហាជនធ្វើទំនប់ប្រឡាយ លើកប្រព័ន្ធភ្លឺស្រែ ពីសិប្បកម្ម ពីឧស្សាហកម្ម ពីកងទ័ព ពីការបង្កបង្កើនផលជាមូលដ្ឋាន។ ដូច្នេះ ពីរឿងជម្លៀសអី អត់ពាក់ព័ន្ធទេ ព្រោះមិនមានថ្នាក់ដឹកនាំអត់មានលើកឱ្យយើងសរសេរទេ។ ព្រោះព័ត៌មានហ្នឹង មិនមែនជាព័ត៌មានសេរីទេ គឺព័ត៌មានដែលមានការកម្រិតព្រំដែនឱ្យយើងសរសេរ ឈរលើមាគ៌ានយោបាយ គោលនយោបាយវប្បធម៌របស់បក្ស។

[១១:៣៣:១០]

**ស៖** ប្រសិនបើលោកនិយាយថា គេបានកំណត់ការសរសេរនិពន្ធព័ត៌មានរបស់លោក តើនរណាគេជាអ្នកកំណត់ឱ្យលោកសរសេរចំណុចនេះ ឬក៏មិនសរសេរចំណុចនោះ?

**ឆ៖** ខ្ញុំតែងតែនិយាយតាំងពីជំនាន់ លោក ហ៊ូ នឹម, ទីវ អុល មកដល់លោកស្រី យុន យ៉ាត។ ដូច្នេះ មានតែមេដឹកនាំនៅក្នុងក្រសួងខ្ញុំទេ ដែលគាត់មានសិទ្ធិអាចណែនាំ ហើយនិងមន្ត្រីក្រោមឱវាទរបស់គាត់ ជាមេបន្តរបស់ខ្ញុំទៀត។

**ស៖** នៅពេលដែលលោកនិយាយថា ព័ត៌មានមួយចំនួនមិនត្រូវបោះផ្សាយនៅក្នុងកាសែតនោះទេ។ តើនរណាជាអ្នកទទួលបាននូវសារព័ត៌មានទាំងអស់នោះ? យើងត្រូវចែកជូនអ្នកណាគេខ្លះ?

**ឆ៖** តាមខ្ញុំដឹង ព័ត៌មានទាំងអស់នោះ យើងបញ្ជូនទៅគ្រប់មូលដ្ឋានទូទាំងប្រទេស។ ដោយមានអ្នកទៅយក ហើយគេរៀបចំជាគីបៗនោះ បើយើងបោះច្រើន ក្នុងសម័យ៣ឆ្នាំ គឺគេបោះច្រើនណាស់។ ច្រើនច្បាប់ ខ្ញុំមិនចាំ ប៉ុន្តែថាដឹកទាំងឡានៗ។ ដូច្នេះច្រើន។

**ស៖** តើគេមានចែកជូនទៅដល់ប្រជាជនស៊ីវិលដែរឬទេ?

[១១:៣៥:០១]

**ឆ៖** តាមខ្ញុំសាកសួរ ព្រោះការសរសេរ ឬក៏ការបោះពុម្ពផ្សាយ យើងតែងតែចង់តាមដានឱ្យដឹងថាតើដល់ ទៅដល់មូលដ្ឋានឬអត់? បញ្ហានេះជួនកាលក៏ដល់ ប៉ុន្តែជួនកាលអាចមិនដល់ដែរ។ ហេតុអីបានខ្ញុំនិយាយថាជួនកាលអាចទៅដល់ អាចមិនទៅដល់? ពីព្រោះយើងភ្លាប់បានហើយ ដូចខ្ញុំលើកពីខាងដើមហើយ កន្លែងខ្លះធ្វើស្រូវអង្ករបានច្រើនមែន ប៉ុន្តែប្រជាជនអត់បានហូបទេ។ ការដឹកពីភ្នំពេញទៅ គឺដឹកមានតាំងពីខោអាវ កំណាត់ភួយ មុង សម្ភារៈផ្សេងៗ ពីជ័យជម្នះហ្នឹង គឺយើងនៅសំណល់ក្នុងឃ្លាំងច្រើនណាស់ដែលត្រូវទៅឱ្យទៅមូលដ្ឋាន។ ប៉ុន្តែការដឹកទៅ ជួនកាលអត់ដល់។ ប្រជាជននៅតែក្រ អត់មានបាយហូបដដែល។ អីចឹងបានន័យចម្លល់របស់ខ្ញុំជុំវិញនឹងការផ្សព្វផ្សាយ ខ្ញុំថាអាចដល់និងអាចមិនដល់។ ព្រោះមានលទ្ធភាពហ្នឹង គឺខ្ញុំបានសាកសួរនៅមូលដ្ឋានហើយ កន្លែងខ្លះគឺគេទៅដល់ មានសព្វ

គ្រប់។ ហើយជួនកាលគេយកកាសែត ឬក៏យកទស្សនាវដ្ដី ឬឯកសារហ្នឹងទៅផ្សព្វផ្សាយទូលាយតែម្ដង ឲ្យមហាជនដឹង។

[១១:៣៦:២៦]

អ៊ីចឹងសម័យនោះ ខ្ញុំឃើញថាមានលទ្ធភាពបានទៅដល់ និងមិនអាចទៅដល់ដែរ។ ហើយមូលហេតុដូចខ្ញុំបានរៀបរាប់ពីខាងដើមហើយ គឺថាពិបាកដែរ ព្រោះខ្ញុំជួបទិដ្ឋភាព -- ដូចខ្ញុំនៅភ្នំពេញ ខ្ញុំមិនមានការអត់ឃ្លានអីទេ ប៉ុន្តែប្រជាជនមូលដ្ឋានមានការអត់ឃ្លាន។ យ៉ាងណាមិញ កាសែតដែលយើងខំធ្វើ ឯកសារដែលយើងបោះពុម្ពផ្សាយ អាចមានលទ្ធភាពអ៊ីចឹងដែរ។

**សៈ** លោកបាននិយាយថា នៅតាមជនបទ តាមតំបន់មួយចំនួនមិនមានម្ហូបអាហារគ្រប់គ្រាន់។ តើលោកមានរាយការណ៍អំពីបញ្ហានេះទេ? តើគេអនុញ្ញាតឲ្យលោករាយការណ៍អំពីបញ្ហាខ្វះខាតម្ហូបអាហារនេះទេ?

**ឆៈ** ខ្ញុំបានបញ្ជាក់ពីខាងដើមហើយថា ខ្ញុំជួបបញ្ហាអីដែលវាមិនប្រក្រតី ខ្ញុំតែងផ្ដល់ព័ត៌មានជូនទៅរដ្ឋមន្ត្រីដែរ។ ប៉ុន្តែដូចគាត់បានណែនាំខ្ញុំហើយ ថាការងារអីមិនមែនជាការងារយើង យើងមិនត្រូវដឹង ហើយយើងដូចជាមិនបានផ្សព្វផ្សាយឲ្យអ្នកណាដឹងដែរ។

[១១:៣៨:០១]

**សៈ** សូមអរគុណ។ តើលោកអាចប្រាប់បានទេថា មានភាពខុសគ្នាយ៉ាងណារវាងសារព័ត៌មានដែលលោកធ្វើការ ហើយនិងទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីទង់ -- និងទស្សនាវដ្ដីយុវជន យុវនារី។ តើទាំងពីរប្រភេទហ្នឹង វាខុសគ្នាបែបណា រវាងទស្សនៈសារព័ត៌មានដែលលោកធ្វើការ និងទស្សនាវដ្ដីទង់បដិវត្ត?

**ឆៈ** បើនិយាយទៅ ទង់បដិវត្តគឺសម្រាប់ផ្ទៃក្នុងបក្ស។ សូម្បីតែខ្ញុំក៏មិនដែលបានមើលអីឲ្យគ្រប់ក្បាលដែរ ព្រោះយើងអត់ត្រូវមើល។ វាច្រើនតែផ្សព្វផ្សាយ ហើយបានមើលតិចតួចណាស់ទង់បដិវត្ត ព្រោះសម្រាប់តែកម្មាភិបាលថ្នាក់លើ។ ខ្ញុំមែនទែនមានមុខងារជាកម្មាភិបាលដែរ ប៉ុន្តែជាកម្មាភិបាលក្រៅបក្ស។ ដូច្នេះខ្ញុំមានឱកាសច្រើនក្នុងការមើលបានខ្លះ ដោយសារខ្ញុំធ្វើការជាប់នឹងប្រព័ន្ធផ្សព្វផ្សាយ។ ឯចំណែកឯអត្ថបទដែលពួកខ្ញុំសរសេរ មែនទែនទៅ យើងនិយាយថាជាខ្លឹមសារសម្រាយ វាមិនមានអីសម្ងាត់ទេ។ ឯទង់បដិវត្តគឺដឹងតែថ្នាក់លើ និងថ្នាក់ដឹងនាំហ្នឹងឯងដែលត្រូវដឹងច្រើន។ ឯកាសែតនិងទស្សនាវដ្ដីរូបភាពអីហ្នឹង គឺទូលាយតែម្ដង។ ចតរូបមកគឺដើម្បីផ្សាយឲ្យមហាជន យកពីមហាជន

ផ្តល់ទៅឲ្យមហាជនវិញ។ ហើយកាសែតក៏មានគោលការណ៍យ៉ាងដូច្នោះដែរ ដូចគ្នា។ ឯទង់បដិវត្តនេះ គឺមិនមែនពីមហាជនទេ គឺពីដឹកនាំថ្នាក់លើ ទៅដឹកនាំថ្នាក់តាមលំដាប់។ មិនមែនទូលាយនៅក្នុងមហាជនទូទៅទេ។

[១១:៤០:១៦]

**ស៖** កាលពីម្សិលមិញលោកនិយាយថា លោកមានពេលអាចអានទស្សនាវដ្តីទង់បដិវត្ត ដើម្បីយកមកអានសារព័ត៌មានរបស់លោក តើអត្ថបទដែលលោកសរសេរដែលពឹងផ្អែកទៅលើទស្សនាវដ្តីបដិវត្តហ្នឹង អត្ថបទហ្នឹងជាអត្ថបទបែបណា? របៀបណាដែរ?

**ឆ៖** អត្ថបទជាប្រភេទអត្ថបទណែនាំ និយាយពីការពារ និងការកសាងប្រទេស។ ហើយយើងអាចដកស្រង់យកចំណុចណាមួយដែលទាក់ទងនឹងវិស័យទាំងនោះ។ សូម្បីតែយើងសរសេរពីកសិកម្ម ពីឧស្សាហ៍កម្មក៏ដោយ គឺត្រូវតែមានពាក្យតាមដំណាក់កាលមួយៗ។ ឧបមាថាដូចពាក្យថា "ការពារ និងកសាងប្រទេស តាមសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ" យើងត្រូវយល់ន័យរួមហើយ យើងយកមកបំប៉ែកសរសេរទៀត។ ហើយមួយទៀត ជាគោលនយោបាយថា ក្នុងដីមួយហិកតាធ្វើឲ្យបាន៣តោន។ អាហ្នឹងដំណាក់កាលមួយទៅ។ ហើយដំណាក់មួយទៀត ថាខំធ្វើហ្នឹងឲ្យបាន៣តោន និងលើសពីហ្នឹងទៀត ដើម្បីឲ្យសល់ច្រើន ដើម្បីឲ្យប្រជាជនធូរធារ ហើយនិងអាចលក់ចេញទៅក្រៅបាន។ អានេះ នេះជាឧទាហរណ៍នៅក្នុងសរសេរ គឺយើងចង់ច្បុចយកចំណុចណាមួយយកមកបំប៉ែកសរសេរ។

[១១:៤១:៥១]

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយថា សារព័ត៌មានគឺជាមធ្យោបាយដើម្បីផ្សព្វផ្សាយនូវសារ ឬក៏ព័ត៌មានអំពីទស្សនាវដ្តីទង់បដិវត្តផ្សព្វផ្សាយទៅដល់មហាជន។ តើវាជាការត្រឹមត្រូវដែរឬទេដែលខ្ញុំនិយាយបែបនេះ?

**ឆ៖** បាទ ជាការត្រឹមត្រូវហើយ។

**ស៖** លោកបាននិយាយថា ក្នុងមានជាអ្នកយកព័ត៌មាន លោកធ្លាប់ចុះទៅតាមខេត្ត ដើម្បីថតរូបភាព និងប្រមូលព័ត៌មាន។ សំណួររបស់ខ្ញុំ គឺថា តើលោកចុះទៅតាមតំបន់ណាខ្លះនៅពេលនោះ?

**ឆ៖** តាមខ្ញុំចាំបាន គឺយើងចុះទៅគ្រប់ភូមិភាគ និងតំបន់។ ហើយសហការជាមួយភូមិភាគ និងតំបន់ ដើម្បីយកចំណុចណាមួយដែលយើងចង់ទៅពិភាក្សាជាមួយគាត់ ឲ្យគាត់ផ្តល់ថា អាចទៅបាន យើងទៅបាន។ បើគាត់ថា មិនអាចទៅបានទេ គឺមិនអាចទៅបានទេ។ ព្រោះដូចខ្ញុំលើពីខាងដើមហើយ

ព្រោះកន្លែងខ្លះនៅមានអសន្តិសុខនៅឡើយទេ។ វាមិនមែនទាន់ថា អត់មានហេតុការណ៍អីទេ។ ដូច្នេះគេខ្លាចប៉ះពាល់ដល់កម្លាំងយើងទៅធ្វើការអ៊ីចឹង គេមិនឲ្យយើងទៅទេក្នុងតំបន់ខ្លះ។

[១១:៤៣:៣៣]

**ស៖** តើលោកចុះទៅខេត្តហ្នឹង ទៅញឹកញាប់កម្រិតណាដែរ?

**ឆ៖** តាមពិត ខ្ញុំទៅញឹកញាប់ដែរ។ មានពេលខ្លះត្រូវទៅ១ថ្ងៃ ២ថ្ងៃ ៥ថ្ងៃ ១អាទិត្យ ឬពេលខ្លះអាចទៅដល់កន្លះខែក៏មានដែរ។

**ស៖** តើលោកអាចជ្រើសរើសបានថា លោកចង់ទៅពេលណា? ទៅកន្លែងណា? ឬមួយក៏មានអ្នកដទៃផ្សេងដែលជាអ្នកសម្រេចជំនួសលោក?

**ឆ៖** បើយើងចង់ទៅកន្លែងណា យើងស្នើទៅខាងថ្នាក់ដឹកនាំផ្ទាល់ម្ដង រដ្ឋមន្ត្រី។ ព្រោះរដ្ឋមន្ត្រីអាចទាក់ទងសំបុត្រអនុញ្ញាតទៅមន្ទីរថ្នាក់លើ ដើម្បីចេញលិខិតអនុញ្ញាតឲ្យយើងធ្វើដំណើរ។

**ស៖** នៅពេលដែលលោកនិយាយថា លោកផ្ដោតទៅលើតំបន់មួយចំនួន។ តើលោកផ្អែកទៅលើអ្វីដែលលោកធ្វើការផ្ដោត ឬក៏លោកធ្វើការសម្រេចចិត្តក្នុងការផ្ដោតយកតំបន់ណាមួយនោះ?

[១១:៤៤:៥៩]

**ឆ៖** ការផ្ដោតរបស់យើងពេលនុ៎ង ដូចខ្ញុំបានលើកពីខាងដើម គឺប្រធានបទជាច្រើនដែលតម្រូវឲ្យយើងទៅ។ ព្រោះការសរសេរបើយើងទៅដល់ទីកន្លែងយើងអាចសរសេរដំណឹងក៏បានល្អ យល់ពីចលនានៅកន្លែងហ្នឹង ហើយក៏ដឹងព័ត៌មានច្បាស់ពីកន្លែងហ្នឹងយើងអាចថត យើងអាចយកមកព័ត៌មានយកមកសរុបព័ត៌មាន ហើយវាអំណោយទានដល់យើងក្នុងការសរសេរទៅឃើញចលនាជាក់ស្ដែងយើងមានគំនិតក្នុងការសរសេរ។ បើបានព័ត៌មានហើយយើងមិនមានគំនិត គឺថ្នាក់លើក្រសួងត្រូវតែឲ្យចុះទៅទៀត។ បើសរសេរពីរឿងស្ទូងស្រែ ធ្វើស្រូវអត់កើត ដូចពួកនិស្សិតនៅសាកលវិទ្យាល័យភ្នំពេញអ៊ីចឹងគាត់ គេធ្លាប់តែរៀន ហើយគាត់មកសរសេរដំណឹងដូចប្រភេទថា កសិកម្ម ឧស្សាហកម្ម ឬក៏ធ្វើទំនប់ប្រឡាយអីគាត់ពិបាកៗផ្សារភ្ជាប់ណាស់។ ដូច្នេះមានតែចុះទៅមូលដ្ឋាន ទៅស្ទូងស្រូវជាមួយនឹងប្រជាជនអ៊ីចឹងទៅ ទៅសម្រាកលេងជាមួយគាត់អ៊ីចឹងទៅ ដល់អ៊ីចឹងទៅវាអាចមានគំនិតផ្សារភ្ជាប់ព្រោះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តែងតែឲ្យអ្នកធ្វើការហ្នឹងជាប់ជាមួយអ្នកក្រីក្រ បើយើងមិនជាប់ជាមួយអ្នកក្រីក្រ អត់ដឹងថា អ្នកក្រីក្រហ្នឹងលំបាកវេទនាយ៉ាងម៉េចទេ។

[១១:៤៦:៣១]

អ៊ីចឹងថ្នាក់ដឹកនាំត្រូវឲ្យយើងផ្សារភ្ជាប់នៅហ្នឹង ដើម្បីឲ្យមានគំនិតចេះផ្សារភ្ជាប់ខ្លួនឃើញការលំបាក ឬក៏ឃើញចលនាជាក់ស្ដែងទៅយើងអាចសរសេរជាបទពណ៌នា ជាបទយកការណ៍ ឬក៏អាចធ្វើជារឿងខ្លី រឿងវែងអីបាន យកមកសរសេរបាន។

**ស៖** ប្រសិនបើលោករស់នៅជាមួយកសិករឲ្យបានជិតស្និទ្ធនៅតាមជនបទហ្នឹង គឺលោកអាចពណ៌នាអំពីស្ថានភាពរស់នៅ អំពីការរស់នៅរបស់គេ អ៊ីចឹងមែនទេ?

**ផ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកអាចពណ៌នាបានទេថា តើនៅពេលនុ៎ងប្រជាជនហ្នឹងគាត់រស់នៅស្ថានភាពបែបណា? គាត់ធ្វើការក្នុងស្ថានភាពបែបណា?

**ផ៖** តាមពិតទៅការសម្រេចទៅកន្លែងណាដែលយើងចង់ទៅដល់ ទាល់តែមានសម្រេចពីថ្នាក់ដឹកនាំនៅមូលដ្ឋាន យើងមិនអាចចេះតែចុះទៅបានទេ។ ដូចខ្ញុំបានលើកពីខាងដើម ទាល់តែយើងចុះទៅឃើញជាក់ស្ដែងអ៊ីចឹង។ ដូចខ្ញុំលើកពីខាងដើមហើយ វាមានគំនិតក្នុងការសរសេរ។ អ៊ីចឹងយើងចុះទៅហ្នឹង គឺមានគោលដៅសម្រាប់តែយើងសរសេរ យើងដឹងតែពីរឿងការងារយើងទេ។

[១១:៤៨:២១]

**ស៖** ខ្ញុំយល់ថា លោកមានការបញ្ជាដើម្បីឲ្យគិតពិភាក្សាទៅលើព័ត៌មានមួយចំនួន ប៉ុន្តែនៅពេលដែលលោកចុះទៅតាមខេត្តហ្នឹង តើលោកឃើញថា ស្ថានភាពប្រជាជន ស្ថានភាពការងាររបស់ប្រជាជននៅពេលនុ៎ងវាយ៉ាងម៉េចដែរ? បានន័យថា តើលោកឃើញផ្ទាល់ភ្នែកហ្នឹងតើស្ថានភាពនុ៎ងវាមានលក្ខណៈបែបណា?

**ផ៖** ទីកន្លែងដែលខ្ញុំទៅដល់ គឺគេតែងមានទទួល ហើយខ្ញុំមិនឃើញថា ការលំបាកអីអត់ឃ្លានអីទេ។ ទៅដល់ឃើញហូបគ្រប់គ្រាន់ដែរកន្លែងដែលខ្ញុំទៅ កម្មាភិបាលគាត់នាំទៅគឺដូចមិនមានជីវភាពតោកយ៉ាកអីទេ។ ហើយសកម្មភាពធ្វើការងារបើយើងមើលទៅ ដូចជាសកម្មប្រយុទ្ធដែរ ព្រោះធម្មតាខ្ញុំឃើញថា ឧបមាថា ទៅជីក ឬក៏លើកទំនប់កាត់ស្ទឹងជីនិតមួយ នៅអន្លង់ចង្អៀង នៅពេលបើកការដ្ឋាននោះ ក្រសួងឃោសនាការ និងក្រសួងឃោសនាអប់រំ ក៏ចុះទៅដល់កន្លែងការដ្ឋាននោះដែរ ហើយយើងមានទាំងថតរូបធម្មតា និងថតកុនផងដែរ ដើម្បីឃើញចលនានោះ។ ហើយខ្ញុំឃើញថា នៅក្នុងឯកសារផ្សេងៗដែលទូរទស្សន៍ផ្សព្វផ្សាយរាល់ថ្ងៃក៏ឃើញពីចលនាទាំងនោះដែរ ចលនាៗទប់ស្ទឹងធ្វើទំនប់ធ្វើអីហ្នឹង។

[១១:៥០:១០]

អ៊ីចឹងកាលនោះ ពួកខ្ញុំចុះទៅ គឺមានទាំងពីរ ឬក៏ទៅតែមួយក្រសួងទេ។ ប៉ុន្តែយើងក្រសួងទាំងពីរហ្នឹងតែងតែសហការគ្នា ហើយទៅជាមួយគ្នា ទៅឡានជាមួយគ្នា ក្នុងដំណើរជាមួយគ្នា។ ដូច្នេះ នៅសម័យនោះគឺខ្ញុំបានឃើញចលនាសស្រាក់សស្រាំអ៊ីចឹង។ ប៉ុន្តែថា គិតពីរឿងថាកន្លែងនោះអត់ឃ្លានស្លាប់ ហូបអីៗអត់ៗឃើញទេក្នុងសម័យនោះ។ ព្រោះខ្ញុំទៅដល់ឃើញតែកន្លែងដែលគេមានអីហូបគ្រប់គ្រាន់ ធ្វើការអីមើលទៅដូចមានកម្លាំងកំហែងដែរ។

**ស៖** ប្រហែល២-៣នាទីមុននេះ លោកនិយាយថា នៅតាមជនបទប្រជាជនមិនមានចំណីអាហារគ្រប់គ្រាន់ ហើយគេមិនឲ្យលោករាយការណ៍ៗនៅក្នុងព័ត៌មានអំពីបញ្ហានេះទេ។ ប៉ុន្តែឥឡូវនេះលោកនិយាយ នៅពេលដែលលោកចុះទៅ គឺលោកនិយាយថា លោកមិនដែលឃើញមានការអត់ឃ្លានប្រជាជនមានម្ហូបអាហារគ្រប់គ្រាន់នោះ។ តើលោកអាចបញ្ជាក់បានទេ ថាតើមួយណាដែលត្រឹមត្រូវ? ថាតើប្រជាជនអត់ឃ្លាន ឬមួយក៏មានអាហារគ្រប់គ្រាន់?

[១១:៥១:៣០]

**ឆ៖** ខ្ញុំសូមបញ្ជាក់ទិដ្ឋភាពពីរ។ ទិដ្ឋភាពទី១ និយាយពីរឿងអត់ឃ្លាន។ តាមពិតនៅសម័យនោះជួនកាលគោលដៅដែលខ្ញុំទៅ គឺខ្ញុំចង់ដឹងការពិតណាស់។ ខ្ញុំចុះទៅដល់មូលដ្ឋានខ្លះដែលមានការអត់ឃ្លានដែរ ជាពិសេសចុះទៅតំបន់២៥ ដែលខ្ញុំចាប់ផ្តើមការងារដំបូង ខ្ញុំចុះទៅតំបន់២៥ គឺស្អាងកោះធំហ្នឹងឯង។ ដូច្នេះ នៅតំបន់នោះ មនុស្សភាគច្រើនចេញពីភ្នំពេញទៅ ខ្ញុំឃើញថាមានការហូបពោតក្រហម ព្រោះមនុស្សច្រើនពេកហើយ រាប់ -- បើគិតទៅវាច្រើន មនុស្សរាប់លាន។ អ៊ីចឹងខ្ញុំឃើញថាក្នុងសម័យនោះ ឃើញមានជួបការអត់ឃ្លានមែន។ ប៉ុន្តែក្រោយដែលខ្ញុំចុះទៅក្រោយៗ គឺកម្មាភិបាលនាំទៅកន្លែងដែលមិនមានទិដ្ឋភាពហ្នឹងទេ។ ដូច្នេះ បានជាសម័យនោះខ្ញុំវាយតម្លៃថា មិនឃើញមានការអត់ឃ្លានអីទេ។ ព្រោះគេនាំទៅតែកន្លែងអត់មានការអត់ឃ្លាន ឲ្យខ្ញុំឃើញថាអត់ឃ្លានម៉េចកើត! ព្រោះនៅភ្នំពេញ អត់មានរឿងអត់ឃ្លានអីទេ យើងហូបពេញ។ ម៉្យោមានបីពេល មិនមានបង្អែមអីសេរីដូចយើងថាចង់ហូបបង្អែមរាល់ថ្ងៃអី អាហ្នឹងមិនបានទេ។ ព្រោះមានថ្ងៃ១០ ថ្ងៃ២០ អីគេ។

[១១:៥២:៥៣]

ហើយបើនិយាយនៅភ្នំពេញ តាមសហជីព និងតាម -- និយាយរួមតាមអង្គភាពអត់មានអត់ឃ្លានទេ។ ព្រោះបាយ គិតទៅគេហូបរួម។ អង្គាល់នោះ គេធ្វើបាយចំហុយគឺ ដូចអង្គភាពខ្ញុំនៅ

ឃោសនាការនៅ ៣៣ មិនដែលអត់ឃ្លានទេ ហើយត្រីក្នុងមួយឆ្នាំៗ ដល់ភ្នំពេញមនុស្សចេញអស់អ៊ីចឹងទៅ យើងដឹកមកពីព្រែកឆ្លៅ មកពីច្រាំងចំរេះអីហ្នឹង គឺដឹកពីដៃមក គឺច្រើនណាស់។ ដូច្នេះយើងអត់ឃើញមានទិដ្ឋភាពអត់ឃ្លានហ្នឹងទេ។

ខ្ញុំចង់និយាយថា នៅក្នុងឯកសារច្រើននិយាយពីរឿងអត់ឃ្លានស្លាប់ ត្រូវគេធ្វើបាបជាដើមអ៊ីចឹងចុះ។ ប៉ុន្តែខ្ញុំអ្នកយកព័ត៌មាន សម័យនោះខ្ញុំមិនដែលឃើញទិដ្ឋភាពហ្នឹងទេ។ ហើយទិដ្ឋភាពដែលខ្ញុំបានឃើញគឺនៅក្នុង គឺខ្ញុំបានលើកនៅលើកដំបូងដែលខ្ញុំចេញទៅធ្វើការនៅតំបន់២៥ ឃើញប្រជាជនច្រើនពេកអ៊ីចឹងទៅ ឃើញថាអត់ឃ្លានមែន ហូបពោតក្រហម ហូបអីខ្លះ។

[១១:៥៤:០៧]

**ស៖** សូមអរគុណ។ លោកបាននិយាយថា ប្រជាជនថ្មីដែលមកដល់តំបន់២៥ តើលោកអាចពន្យល់បានទេថា តើប្រជាជនថ្មីនោះមានន័យយ៉ាងម៉េច?

**ឆ៖** ចង់និយាយថា ប្រជាជនថ្មីគឺប្រជាជនដែលជម្លៀសចេញពីក្រុងភ្នំពេញ។ ដូច្នេះ បើគិតជាចំនួនគឺមានច្រើនណាស់។ គឺតំបន់នោះត្រូវការទទួលមនុស្សច្រើន ព្រោះនៅជិតនឹងភ្នំពេញ មនុស្សចេញទៅគឺ -- ហើយនៅក្នុងចំណោមយើងហ្នឹងអាចមានមនុស្សដែលចេញទៅក្នុងតំបន់នោះច្រើនដែរ តាមគិតមើលទៅ មានទាំង -- និយាយរួមមានមនុស្សច្រើន។

**ស៖** តើលោកមានបានឃើញទេ តើគេធ្វើការទទួល ឬក៏ការទទួលយកប្រជាជននោះ ធ្វើបែបណាដែរ នៅពេលដែលមានប្រជាជនច្រើនកុះករបែបនេះ?

[១១:៥៥:១២]

**ឆ៖** ជាធម្មតាយើងត្រូវគិតថា បើមានចំនួនមនុស្សច្រើនហើយ វាមិនខុសអីពីជនភៀសខ្លួនទេ។ ហើយជំនាន់ហ្នឹងអត់មាន យូ.អ៊ិន ឯណាមកជួយ ដូច្នេះតាមស្ថានភាពអ៊ីចឹងទៅ។ ព្រោះនៅខែមេសាហ្នឹង ១៧មេសា គិតទៅ បើគិតពីចូលឆ្នាំគឺចូលឆ្នាំរួចហើយ ដូច្នេះ វាជិតធ្លាក់ភ្លៀងហើយតាមមើល។ ដូច្នេះមានតែចែកគ្នានៅតាមផ្ទះ តាមវត្ត តាមកន្លែងទីសាធារណៈ ដែលអាចទូលំទូលាយគឺជនភៀសខ្លួនអាចទៅនៅកន្លែងនោះបាន។ ហើយមិនដឹងថា ខាងមូលដ្ឋានហ្នឹងចាត់វិធានការហ្នឹងយ៉ាងម៉េចទេ ព្រោះខ្ញុំមិនដឹងដែរ ខ្ញុំមិនបានសួរដេញដោល ព្រោះរឿងស្មុគស្មាញរបស់គាត់ដែរ។ ព្រោះមនុស្សច្រើនណាស់គាត់ត្រូវទទួល។ ហើយធម្មតា ក្នុងសង្គ្រាមយើងច្បាំងគ្នា មិនដែលមានអីដែលច្រើនទេ ជាម្ហូបអាហារជាពិសេសអ្នកដែលនៅជុំវិញភ្នំពេញ គឺខ្វះតាំងពីអំបិលហូបក្នុងសង្គ្រាម។ ដូច្នេះ ខ្ញុំជឿថាការអត់ឃ្លាន

ហ្នឹងវាមានចំនួនធំធេង ហើយឲ្យខ្ញុំពន្យល់ពីបញ្ហាហ្នឹង ក៏ខ្ញុំវាមិនដឹងដែរ។

[១១:៥៦:២៨]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់និយាយម្ដងទៀតអំពីប្រជាជនថ្មី។ តើលោកធ្លាប់សរសេរអត្ថបទពាក់ព័ន្ធទៅនឹងប្រជាជនថ្មីនេះដែរឬទេ?

**ឆ៖** ជាគោលនយោបាយនៃការផ្សព្វផ្សាយរបស់យើង យើងមិនដែលបែងចែកអ្នកថ្មី អ្នកចាស់ទេ។ ហើយក្នុងព័ត៌មានគឺមិនឲ្យនិយាយតែម្ដង។ និយាយបាននៅក្នុងខ្លឹមសារទង់បដិវត្តអី ប៉ុន្តែដូចពួកខ្ញុំសរសេរនេះគឺថា អត់សរសេរបានទេ ព្រោះត្រូវជួនកាលគេយកទៅផ្សាយវិទ្យុបាន អត្ថបទហ្នឹង គេស្រង់ពីកាសែតយកទៅផ្សាយវិទ្យុក៏មាន។ ដូច្នេះ ខ្ញុំសរសេរតែជ្រុងណាដែលអាចមើលទៅថាមិនប៉ះពាល់ដល់នយោបាយទេ ព្រោះកម្ពុជាប្រជាធិបតេយ្យគិតគូររឿងនយោបាយនូវការផ្សព្វផ្សាយហ្នឹងណាស់។ ព្រោះការផ្សព្វផ្សាយថ្នាក់ដឹកនាំ ធ្លាប់និយាយថាវាដូចជាកាំភ្លើងធំមួយដែរ បើបាញ់ចេញទៅហើយ វាត្រូវតែ -- ដូច្នេះគឺបញ្ជាក់អត្ថន័យគឺវាអ៊ីចឹង។ នៅហ្នឹងគឺការសរសេរគឺត្រូវប្រយ័ត្នប្រយែងហើយមានការឆ្លងមើលខ្លឹមសារហ្នឹងជិតដល់ណាស់ មិនអាចខ្លួនយើងម្នាក់ហ្នឹងអះអាងថាមានភាពពេញលេញទេ គេពិនិត្យទាំងពីរទស្សនៈរួម នៅលើបច្ចេកទេស ឃ្លាប្រយោគ។ ហើយធ្វើមុនដំបូងហ្នឹងត្រូវឆ្លងការពិនិត្យខ្លឹមសារហ្នឹងតែម្ដង។ ហើយគណៈនិពន្ធត្រូវកែឲ្យអស់តែម្ដង មិនឲ្យប៉ះពាល់ទេ។

[១១:៥៨:១៣]

**ស៖** សូមអរគុណ។ លោកបាននិយាយថាទស្សនាវដ្ដីទង់បដិវត្តបាននិយាយអំពីពាក្យប្រជាជនថ្មី។ តើលោកអាចប្រាប់បានដែរឬទេថា ទស្សនាវដ្ដីទង់បដិវត្តហ្នឹងនិយាយអំពីអ្វីទាក់ទងទៅនឹងប្រជាជនថ្មី?

**ឆ៖** ខ្ញុំមិនចាំថា យ៉ាងណាៗទេ។ ខ្ញុំអត់បានឃើញដែរ។ ប៉ុន្តែខ្ញុំនិយាយៗពីសិទ្ធិទេ សិទ្ធិខាងខ្ញុំសរសេរទូលាយ និងសិទ្ធិដែលសម្ងាត់។ បើសម្ងាត់គេអាចសរសេរថា ប្រជាជនចាស់-ថ្មី ហ្នឹងបាន។ បែងចែកប្រភេទ ប៉ុន្តែសរសេរដូចក្នុងនេះមិនអាចបែងចែកប្រភេទអ៊ីចឹងបានទេ។ គឺប្រជាជនទូទៅនិយាយជាមនុស្សទូទៅ។

**ស៖** លោកបាននិយាយថា លោកបានថតរូបនៅតាមជនបទនៅពេលដែលលោកចុះទៅយកព័ត៌មាន។ តើលោកថតរូបភាពអ្វីខ្លះនៅពេលនោះ?

[១១:៥៩:២៣]

**ឆ៖** រូបភាពសំខាន់ ដូចខ្ញុំបានលើកពីខាងដើម គឺសម្រាប់បម្រើការផ្សព្វផ្សាយនៅក្នុងកាសែត នៅក្នុងរូបភាពជាទស្សនាវដ្ដី។ ហើយមួយទៀតសម្រាប់ធ្វើជាខ្សែភាពយន្ត ម៉្លោះហើយទិដ្ឋភាពដែលយើងថត ថតពីចលនាដែលមានផលប្រយោជន៍។ មិនមែនថតដូចកាសែតយើងឥឡូវ មានគ្រោះថ្នាក់ចរាចរអីចឹងទៅ យើងសរសេរអត្ថបទនិយាយពីហ្នឹង។ ដូច្នេះ សិទ្ធិនៅក្នុងការសរសេរពេលនោះ គឺបើថ្នាក់ដឹកនាំណែនាំឱ្យសរសេរពីរឿងការពារប្រទេស កសាងប្រទេស គឺមានសិទ្ធិសរសេរតែពីអ្វីដែលអាចឱ្យប្រជាជនគាត់យល់បាន។

**ស៖** តើមានការរឹតបន្តឹងដែរឬទេក្នុងការថតរូបបើធៀបទៅនឹងការសរសេរ គឺមានការរឹតបន្តឹង។ អីចឹង ការថតរូបហ្នឹងមានការរឹតបន្តឹងដែរឬទេ?

**ឆ៖** តាមពិតការថតរូប ក៏មានប្រុងប្រយ័ត្នដូចគ្នា ដូចអត្ថបទដែរ ព្រោះមានប្រធានបទដូចគ្នាដែរ។ បើថតរូប គ្រាន់តែថត អត់មានប្រធានរូប អាហ្នឹងក៏មិនអាចប្រើការបាន។ ដូច្នេះ បានពួកខ្ញុំត្រូវរៀនពីបញ្ហាហ្នឹង។ រៀនទាំងពីបច្ចេកទេស បច្ចេកទេសនយោបាយ និងបច្ចេកទេសថតរូប។ បច្ចេកទេសនយោបាយចង់និយាយថា តើរូបយើងមួយសន្លឹកហ្នឹងមានអត្ថន័យយ៉ាងម៉េច? វាមានន័យយ៉ាងម៉េច? វាអាចឆ្លុះបញ្ចាំងអំពីសកម្មភាពដែលជាប់នឹងគោលនយោបាយការកសាងប្រទេសដែរឬទេ។

[១២:០១:៣៧]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមបញ្ចប់សំណួររបស់ខ្ញុំ ហើយសូមអរគុណលោកដែលបានឆ្លើយនូវសំណួររបស់ខ្ញុំនេះ ហើយខ្ញុំសូមឱ្យលោកធ្វើដំណើរទៅវិញប្រកបដោយសុវត្ថិភាព។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកសាក្សី។ ឥឡូវហ្នឹង ដល់ពេលត្រូវសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។ មន្ត្រីរដ្ឋតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាកពិសាថ្ងៃត្រង់។ ហើយចំពោះសាក្សីនៅបន្ទប់រង់ចាំសម្រាប់សាក្សីរូបនេះ ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅរសៀលនេះ នៅវេលាម៉ោងដែលបានកំណត់ គឺម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។

កូនក្តីរបស់ខ្ញុំស្នើសុំអនុញ្ញាតតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងខាងក្រោម ដោយសារតែគាត់មានអាការៈឈឺខ្នង ឈឺចង្កេះ ហើយមិនអាចផ្តល់អារម្មណ៍បាន។ ហើយលិខិតស្នើសុំ -- លិខិតលះបង់សិទ្ធិនឹងដាក់ជូនទៅអង្គជំនុំជម្រះ។

[១២:០៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរសវនាការពីចម្ងាយ នៅបន្ទប់ឃុំខ្លួនមួយខាងក្រោមសាលសវនាការនេះ សម្រាប់រយៈពេលធ្វើសវនាការមួយរសៀលនេះ ដោយមូលហេតុមានបញ្ហាសុខភាពមិនអាចអង្គុយតាមដានយូរនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះបាន។ សំណើសុំរបស់លោក នួន ជា ធ្វើឡើងមានមូលហេតុសមស្រប អង្គជំនុំជម្រះសម្រេចយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយលោក នួន ជា បានលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ។

[១២:០៣:៥៩]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្ជាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយដែលស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់ អាច

ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង១៣:៣៥ នាទី)*

[១៣:៣៥:១៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសូមសួរបញ្ជាក់ទៅខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថាតើសូមឲ្យបំភ្លឺថាឯកសារដែលពាក់ព័ន្ធនឹងតំណាងសហព្រះរាជអាជ្ញា មានបំណងប្រគល់ជូនទៅសាក្សីកាលពីព្រឹកមិញនេះ សួរថាតើតំណាងសហព្រះរាជអាជ្ញាបានចាត់ចែងប្រគល់ទៅឲ្យសាក្សីរូបនេះ តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញហើយឬនៅ? ទី១។ ទី២ សូមបញ្ជាក់អំពី -- បំភ្លឺអំពីខ្លឹមសារដែលមានឈ្មោះ នៅក្នុងបញ្ជីនោះ ដែលប្រាកដថា ជាឈ្មោះរបស់អតីតភរិយារបស់សាក្សី ហើយមានលេខរៀងនៅក្នុងបញ្ជីឯកសារណា? អត្តសញ្ញាណឯកសារនោះ ហើយនិងគាត់ហ្នឹងមានវត្តមានបានន័យថា មកដល់មន្ទីរស-២១ នៅពេលណា? ហើយបញ្ជូនចេញនៅពេលណា? សូមផ្តល់ព័ត៌មានដោយសង្ខេប ប្រសិនបើអាចធ្វើទៅបាន។ សូមអញ្ជើញ!

[១៣:៣៦:៥៤]

**លោក ឃីត រ៉េយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅនឹងសំណួរទាំងអស់នេះ។ ទី១ យើងបានទាក់ទងជាមួយនឹងអង្គភាពគាំពារសាក្សី អ្នកជំនាញក្នុងពេលអាហារថ្ងៃត្រង់។ ឯកសារដែលខ្ញុំចង់ផ្តល់ជូននោះ គឺបញ្ជីអ្នកទោសស-២១ ដែលបានកែប្រែ។ ឯកសារដើមនេះ យើងគួរតែរកជាភាសាខ្មែរ យើងយល់ថា ដូច្នេះ យើងគួរតែរកឯកសារដើមជាភាសាខ្មែរ។ យើងបានខិតខំនៅពេលម៉ោងសម្រាកអាហារថ្ងៃត្រង់នោះ គឺ

យើងព្យាយាមរកឯកសារដើម។ ខ្ញុំចាកចេញពីបន្ទប់របស់ខ្ញុំ២០នាទីមុននោះគឺថា យើងមិនទាន់បានរកឃើញនៅឡើយនោះទេ។ ឯកសារដែលយើងអាចផ្តល់ជូនទៅកាន់លោកសាក្សី គឹម វុន នោះគឺថា ឯកសារដើមនឹងរកជូនមុនពេលបញ្ចប់រសៀលនេះ។

ឆ្លើយតបទៅនឹងសំណួរទី២ លោកប្រធាន ឯកសារនោះបង្ហាញឈ្មោះ របស់ស្ត្រីម្នាក់ឈ្មោះ ឈឹម ណារី ហៅ ភ័ណ្ឌ ប្រពន្ធរបស់ ជាំ (ឆោម) ដែលគាត់ជាប្រធានក-២៥ និងធ្វើការងារនៅក្នុងក្រសួងឃោសនាការ ដែលគាត់ជាយុទ្ធជននៅក្នុងមន្ទីរក-២៥។ ហើយយើងឃើញហើយថា ប្រពន្ធរបស់គាត់នោះត្រូវបានបាត់ខ្លួន និងចូលទៅដល់ទីនោះនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨។ លោកប្រធាន នេះគឺជាអ្វីដែលចង់បានចង់ជូនព័ត៌មានដល់លោកប្រធាន។

[១៣:៣៨:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាកិច្ចបន្ត តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វី មានបំណងចង់សួរដល់សាក្សីរូបនេះដែរឬទេ?

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួន ដើម្បីចោទសួរលោកឲ្យបញ្ជាក់ អំពីចម្លើយរបស់លោកមួយចំនួន។ កាលពីម្សិលមិញ លោកបានឆ្លើយថា "នៅពេលដែលវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជា មានទីតាំងនៅប-២០នោះ គឺមានន័យថា មុនពេលទីក្រុងភ្នំពេញដួលរលំ គឺមានផ្សាយអំពីសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន នៅតាមវិទ្យុនោះ ហើយមានការសរសេរដោយមានការចូលរួមពីសម្តេច នរោត្តម សីហនុ"។ ហើយលោកឆ្លើយថា "គឺថាមិនមែនតែ ខៀវ សំផន ម្នាក់ឯងអ្នកសរសេរទេ គឺត្រូវតែមានការឯកភាពីសម្តេច នរោត្តម សីហនុ ផងដែរ"។ តើលោកមានចងចាំថា លោកបានឆ្លើយអ៊ីចឹងទេ?

**លោក គីម វុន៖**

**ឆ៖** បាទ ខ្ញុំបានឆ្លើយ។

**ស៖** តើលោកបានឃើញផ្ទាល់ទេ រវាងការទាក់ទងគ្នារវាងសម្តេច សីហនុ ហើយនិងលោក ខៀវ សំផន នៅពេលនោះ? ឬក៏លោកគ្រាន់តែទទួលបានព័ត៌មានជាក់លាក់ណាមួយ ដែលអាចឲ្យលោកបញ្ជាក់បានថា មានការប្រព្រឹត្តទៅយ៉ាងអ៊ីចឹងមែននោះ? ឬក៏លោកស្មានៗទេ នៅពេលដែលលោកនិយាយបែបនេះនោះ?

[១៣:៤០:៤៦]

**ឆ៖** ខ្ញុំនិយាយគឺក្នុងកាលៈទេសៈនៅពេលនោះ គឺខ្ញុំវាយតម្លៃថាអ៊ីចឹង។

**ស៖** ខ្ញុំស្តាប់ឮថាជាការវិភាគរបស់លោក។ ខ្ញុំចង់ដឹងថាតើការវិភាគនេះមានមូលដ្ឋានទៅលើព័ត៌មានជាក់លាក់ណា ដែលធ្វើឲ្យលោកសន្និដ្ឋានបែបនេះនោះ? តើលោកបានឃើញផ្ទាល់ទេ រវាងការទាក់ទងគ្នារវាងសម្តេច សីហនុ និងលោក ខៀវ សំផន នោះ? ឬក៏លោកដឹងរឿងអីមួយពាក់ព័ន្ធទៅការទាក់ទងរវាងគាត់ទាំងពីរនាក់នេះ? ឬក៏គ្រាន់តែជាការសន្និដ្ឋាន ការវិភាគរបស់លោកផ្ទាល់ខ្លួនទេ?

**ឆ៖** ធម្មតានៅក្នុងពេលៗរណសិរ្សរួបរួមជាតិកម្ពុជា គឺមានអង្គសម្តេចព្រះ នរោត្តម សីហនុជាប្រធាន។ ហើយខ្ញុំនិយាយនេះ បើនិយាយជាពេលវេលាខ្ញុំមានអារម្មណ៍ថា នៅពេលនោះខ្ញុំនិយាយថាអ៊ីចឹង ខ្ញុំវាយតម្លៃថាអ៊ីចឹង។ ឯការឃើញជាក់ស្តែងថា សម្តេចព្រះ នរោត្តម សីហនុ និងលោក ខៀវ សំផន សម្រេចយ៉ាងណា ខ្ញុំមិនដឹងទេ។ នេះជាការវាយតម្លៃខ្ញុំនៅពេលនោះ មិនមែនខ្ញុំនិយាយនៅពេលដែលគេសួរនោះទេ គឺខ្ញុំមានអារម្មណ៍ថា បើមិនមានការសម្រេចពីថ្នាក់លើ ថ្នាក់ក្រោមមិនអាចនឹងៗចេញថ្លែងការណ៍ហ្នឹងបានទេ។

[១៣:៤២:៣៩]

**ស៖** កាលពីព្រឹកមិញនេះលោកបានបង្ហាញអំពីអារម្មណ៍មួយ ដែលលោកឆ្លើយថាបើតាមលោកនោះ សុន្ទរកថាដែលបានផ្សាយនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺក្រោយពីវ៉ៃយកទីក្រុងភ្នំពេញបាន គឺប្រហែលជាមិនមែនលោក ខៀវ សំផន ម្នាក់ឯងជាអ្នកសរសេរទេ។ ហើយលោកក៏បានឆ្លើយផងដែរថា បើតាមលោកចាំនោះពាក់ព័ន្ធទៅនឹងសុន្ទរកថា ដែលសរសេររបស់លោក ខៀវ សំផន នៅសម័យរណសិរ្សនោះ គឺគាត់សរសេរច្រើនតែប្រើឃ្លាវែងៗ។ តើនេះជាធាតុផ្សំតែមួយគត់ទេ ដែលថាឃ្លាវែងនេះ ទើបឲ្យលោកសន្និដ្ឋានបានថា ជារបស់ ខៀវ សំផន ឬក៏មានចំណុចណាផ្សេងទៀតដែល

ធ្វើឱ្យលោកអាចយល់បានថា ហេតុអីបានជាលោកគិតថា លោក ខៀវ សំផន ម្នាក់ឯងនោះមិនអាចសរសេរបានទេ មានអ្នកផ្សេងសរសេរជាមួយគាត់ដែរនោះ?

**ឆ៖** ចម្លើយខ្ញុំ គឺដូចខ្ញុំឆ្លើយខាងលើ។

[១៣:៤៤:១៣]

**ស៖** តើលោកអាចបន្ថែមបានទេ ព្រោះថាខ្ញុំមិនសូវយល់ទេ គឺមានន័យថា លោកនៅរក្សាចម្លើយព្រឹកមិញដដែល ឬក៏លោកមានអ្វីចង់បន្ថែមទៀតចំពោះចម្លើយរបស់លោកនេះ?

**ឆ៖** មានន័យថាលោក ខៀវ សំផន មិនអាចនឹងធ្វើអត្ថបទថ្លែងការណ៍ហ្នឹងដោយឯកឯងបានទេ។ ខ្ញុំវាយតម្លៃថាអ៊ីចឹងនៅពេលនោះ។

**ស៖** លោកសាក្សី អ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតបានសួរលោក ហើយខ្ញុំព្យាយាមសង្ខេបពីអ្វីដែលលោកឆ្លើយ ពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន។ លោកបានប្រៀបធៀបគាត់ដូចទៅជាជំរីពិការ គឺថាអត់មានជើង ហើយអត់មានកម្លាំង។ លោកក៏បានឆ្លើយថា "លោក ខៀវ សំផន ត្រូវបានចាត់ទុកថា ជាជនរងគ្រោះ"។ នេះជាការយល់ឃើញតាំងពីសម័យនរោត្តម សីហនុ ហើយក៏នៅក្នុងសម័យរណសិរ្ស ហើយក៏ដូចជានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ ហើយលោកបានឆ្លើយបន្ថែមទៀតថា បើតាមលោក នោះគឺថា គាត់មិនដែលអំណាចពិតប្រាកដទេ លោក ខៀវ សំផន នោះ"។ ប្រសិនបើជាខ្ញុំមិនច្រឡំទេ លោកបញ្ជាក់ថា "តួនាទីរបស់លោក ខៀវ សំផន ក្នុងអំឡុងរបបប្រជា -- របបប្រជាៗធិបតេយ្យនោះគឺ គ្រាន់តែធានាការដឹកនាំ ផ្គត់ផ្គង់ស្បៀងទៅកាន់មូលដ្ឋាន ហើយនិងមានតួនាទីទទួលគណៈប្រតិភូបរទេសដែលមកទស្សនកិច្ច ហើយនិងអមដំណើរសម្តេច សីហនុ និងភរិយាទៅទស្សកិច្ចនៅជនបទ"។ តើខ្ញុំសង្ខេបត្រឹមត្រូវទេ នូវចម្លើយរបស់លោកចំពោះសហចៅក្រមស៊ើបអង្កេតនោះ ឬក៏ខ្ញុំយល់ច្រឡំទេ?

**ឆ៖** ខ្ញុំឯកភាព១០០ភាគរយ។

[១៣:៤៧:០៣]

**ស៖** ខ្ញុំសូមសួរសំណួរមួយចំនួនដើម្បីព្យាយាមពន្យល់ -- យល់ឱ្យច្បាស់ ហើយលោកឱ្យ -- សូមលោកឆ្លើយឱ្យច្បាស់ ជាការយល់ដឹងរបស់លោក ឬក៏ជាការវិភាគ? លោកបានឆ្លើយថា "លោកបានជួប ខៀវ សំផន នៅក្នុងពេលលោកធ្វើដំណើរចុះទៅយកព័ត៌មាននៅតាមស្រុកស្រែ"។ តើលោកជួប លោក ខៀវ សំផន ញឹកញាប់ដែរឬទេ? ព្រោះព្រឹកមិញខ្ញុំឮដូចជា លោកថាជួបតែមួយដងទេ។

អ៊ីចឹងតើលោក ជួបគាត់ប៉ុន្មានដងដែរ?

**ឆ៖** មែនទែនទៅខ្ញុំជួបដោយចៃដន្យតែមួយដងគត់ ប៉ុន្តែមិនមែនជួបមុខបាននិយាយគ្នាទេ។ ខ្ញុំគ្រាន់តែឃើញដំណើរទេ ព្រោះខ្ញុំចេញទៅថតរូបនៅមូលដ្ឋានដែរ ហើយខ្ញុំសួរមិត្តភក្តិទៅ គេថា ឃើញលោកជិះឡានជាមួយសម្តេចឪ ហើយអាចមានលោកតា ប៉ែន នុត នៅក្នុងហ្នឹងដែរ។ ហើយខ្ញុំក៏ឃើញតែឡានហ្នឹងដែរ ប៉ុន្តែមើលទៅ ច្បាស់ដឹងថាជាមានគាត់ហើយ។ អ៊ីចឹងដោយចៃដន្យហ្នឹងគឺ -- តាមពិតទៅ ខ្ញុំមិនដែលជួបមុខគាត់ផ្ទាល់ទេ ក្នុងជំនាន់៣ឆ្នាំហ្នឹង។

[១៣:៤៨:២៥]

**ស៖** ដូច្នេះ គឺថាលោកមិនដែលជួបគាត់ផ្ទាល់ទេ។ លោកក៏មិនដែលពិភាក្សាជាមួយគាត់អំពីតួនាទី របស់គាត់ដែរ គាត់ក៏មិនដែលធ្លាប់ជាមេរបស់លោកដែរ។ គាត់មិនដែលពិនិត្យផ្ទៀងផ្ទាត់ការងាររបស់លោកទេ។ នេះគឺជាអ្វីដែលលោកឆ្លើយពីព្រឹកមិញ។ តើមានបានទទួលព័ត៌មានអំពីតួនាទីរបស់លោក ខៀវ សំផន នៅក្នុងមន្ទីរមួយដែលឈ្មោះថា ក-៣ ឬ ក-១ ហើយលោកដឹងអំពីដំណើរការនៃមន្ទីរ៨៧០ ដែរឬទេ?

**ឆ៖** ក្នុងសម័យនោះ ខ្ញុំអត់ដឹងថ្នាក់ដឹកនាំនៅកន្លែងណាទាំងអស់។ ខ្ញុំដឹងតែក្រសួងខ្ញុំ។

**ស៖** តើលោកមានព័ត៌មានជាក់លាក់អំពីទំនាក់ទំនងពីចម្ងាយរវាង ខៀវ សំផន, អៀង សារី , ប៉ុល ពត, នួន ជា, អៀង ធីរិទ្ធ និង សុន សេន ដែរឬទេ? តើលោកដឹងទេ ថាអ្នកណាខ្លះបានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍?

**ឆ៖** កិច្ចការថ្នាក់ដឹកនាំខ្ញុំអត់មានសិទ្ធិដឹងទេ។

[១៣:៥០:០១]

**ស៖** ខ្ញុំសួរសំណួរលោកជាលក្ខណៈទូទៅ។ តើលោកមានព័ត៌មានណាផ្សេងទៀតទេ ដែលអាចឲ្យគាំទ្រទៅលើការវិភាគរបស់លោកនោះ ដែលលោកថា ខៀវ សំផន នោះមិនដែលមានអំណាចពិតប្រាកដទេនោះ? លោកមានព័ត៌មានអីខ្លះដែលធ្វើឲ្យលោកអះអាងបែបនេះនោះ?

**ឆ៖** ខ្ញុំឲ្យលោកពិចារណា ធម្មតាមនុស្សខ្ញុំ ខ្ញុំឆ្លងកាត់ការតស៊ូរហូតដល់មក៣ឆ្នាំ រហូតដល់បញ្ចប់នៅឆ្នាំកៅប៉ុន្មាន? ចប់ខ្មែរក្រហមទាំងអស់ គឺខ្ញុំចូលមកកម្ពុជាវិញ។ ក្នុងជីវិតរបស់ខ្ញុំ ខ្ញុំអាចដឹងអ្នកណាមានអំណាច អ្នកណាអត់។ អ៊ីចឹង ខ្ញុំការសន្និដ្ឋាន ឬការវាយតម្លៃរបស់ខ្ញុំ ខ្ញុំដឹងថា លោក ខៀវ សំផន មិនមានអំណាច អត់មានទ្រព្យសម្បត្តិ។ ហើយបើលោកចង់ដឹងផ្ទាល់ សួរគាត់ខ្លួនឯងទៅ អាច

ដឹងហើយ។ ព្រោះខ្ញុំ ខ្ញុំវាយតម្លៃថាអ៊ីចឹង។

[១៣:៥១:៣០]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមចូលដល់ប្រធានបទមួយផ្សេងទៀត ពេលនេះ គឺពាក់ព័ន្ធនឹងតួនាទីរបស់លោក នួន ជា ម្តង។ កាលពីព្រឹកមិញនេះ លោកនិយាយអំពី នួន ជា ហើយកាលពី -- ជាមួយសហចៅក្រមស៊ើបអង្កេតនោះ លោកក៏បាននិយាយពីតួនាទីរបស់គាត់ដែរ។ លោកបញ្ជាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា គាត់មកដឹកនាំក្រសួងឃោសនាការ ក្រោយពីពេលគេចាប់លោក ហ៊ូ នឹម ហើយនិងក្រោយពេលដែលលោកស្រី យុន យ៉ាត នោះបានឡើងទៅកាន់ក្រសួងទាំងពីរនោះ”។ ហើយលោកកាលពីព្រឹកមិញនោះ លោកបញ្ជាក់ថា “នួន ជា នោះគាត់មកម្តងម្កាលទេ”។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ ថាតើលោក នួន ជា គាត់ធ្វើអ្វីដែរនៅក្រសួងឃោសនាការអប់រំនោះ?

**ឆ៖** តាមពិតទៅ លោក នួន ជា មាននាទីមួយធ្វើកម្មវិធីអប់រំ។ កម្មវិធីអប់រំដែលខ្ញុំចាំនៅពេលនោះ គឺអប់រំពីរឿងអី? អប់រំពីវិស័យកសិកម្ម។ គាត់យកសៀវភៅក្រាស់ដែលក្រុមអ្នកបច្ចេកទេសចិននៅមេច្បារហ្នឹង យកមកផ្សព្វផ្សាយម្តងមួយទំព័រៗ។ នេះជាការងារដែលខ្ញុំដឹង។ ហើយក្រៅពីនោះទាក់ទងនឹងអត្ថបទផ្សេងៗ ខ្ញុំមិនដឹងថា ការណែនាំទៅ បងផែន ទៅ គុល អីសរសេរអីយ៉ាងម៉េចខ្ញុំមិនដឹងទេ។ ប៉ុន្តែខ្ញុំដឹងតែនាទីរបស់គាត់ គឺនាទីអប់រំថ្មីហ្នឹង គឺទាក់ទងនឹងវិស័យកសិកម្ម។ ឯកសារដែលបានមក ដូចខ្ញុំបញ្ជាក់ខាងដើម គឺនៅកន្លែងមន្ទីរពិសោធន៍មេច្បារ ដែលអ្នកបច្ចេកទេសចិន គេបង្កាត់ពូជស្រូវនៅទីនោះ។ ផ្សាយ គឺផ្សាយរាល់ថ្ងៃ។

[១៣:៥៣:៥៣]

**ស៖** តើលោក នួន ជា មកនេះគ្រាន់តែផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងខាងវិស័យកសិកម្ម ឬក៏គាត់មានតួនាទីគ្រប់គ្រងការងារនៅក្រសួង ឬក៏គ្រប់គ្រងទៅលើព័ត៌មានដែលផ្សព្វផ្សាយតាមវិទ្យុនោះ? តើគាត់មកជំនួសការងារលោកស្រី យុន យ៉ាត ឬក៏គាត់គ្រាន់តែមកហ្នឹង ដើម្បីបន្ថែមលើអ្នកស្រី យុន យ៉ាត ទេ?

**ឆ៖** កម្មវិធីជាមូលដ្ឋានរបស់គាត់ ដូចខ្ញុំបានលើកពីខាងដើម គឺមានកម្មវិធីនាទីអប់រំថ្មីអំពីកសិកម្មនៅមេច្បារហ្នឹងមួយ។ ហើយការណែនាំទៅផ្នែកសរសេរផ្សេងទៀត។ ខាងភាសាខ្មែរនៅពេលនោះ ខ្ញុំមិនដឹងទេ។ ព្រោះខ្ញុំត្រូវដកមកខាងកម្ពុជាក្រោមវិញហើយ។ ហើយក្នុងរយៈពេលហ្នឹងឯងដែលលោក នួន ជា ទៅធ្វើការនៅឃោសនាការ។ ហើយវត្តមានរបស់គាត់នៅពេលនោះ គឺច្រើនតែលោកស្រី

យុន យ៉ាត អត់នៅ។

[១៣:៥៥:១៦]

**ស៖** តើលោកដឹងទេថា តើមានទំនាក់ទំនងអ្វីរវាងក្រសួងឃោសនាការ និងក្រសួងការបរទេស នោះ? ឧទាហរណ៍ដូចជាថា មានឯកសារសម្រាប់ក្រសួងការបរទេស ហើយមានបោះពុម្ពនៅក្រសួង ឃោសនាការអប់រំទេ?

**ឆ៖** ឯកសារ តាមខ្ញុំចាំដូចមិនមានអីពាក់ព័ន្ធច្រើនទេ។ ពាក់ព័ន្ធនឹងការផ្សាយវិទ្យុកម្ពុជាប្រជាធិបតេយ្យជាភាសាខ្មែររបស់រដ្ឋាភិបាលសម័យនោះ គឺមានសេចក្ដីថ្លែងការណ៍ ឬក៏ដំណឹងគណៈប្រតិភូពីបរទេសមក គឺមានគេយកឯកសារហ្នឹងមកឲ្យខាងផ្នែកក-៣៣ហ្នឹង អានដើម្បីផ្សាយ។ ហើយនិងមានកម្មវិធីមួយទៀត គឺកម្មវិធីភាសាអង់គ្លេស ក៏ធ្វើចេញពីហ្នឹងដែរ។

**ស៖** តើលោកមានចាំអំពីការផ្សព្វផ្សាយសុន្ទរកថាដែលធ្វើឡើងដោយលោក អៀង សារី ឬក៏លោក នួន ជា ដែរឬទេ?

[១៣:៥៦:៤៣]

**ឆ៖** កម្មវិធីវិទ្យុទាំងអស់ ខ្ញុំផ្ដោតតែទៅលើកម្មវិធីរបស់ខ្ញុំទេ។ ឯកម្មវិធីផ្សេងទៀត ខ្ញុំមិនបានចាប់អារម្មណ៍ច្រើនទេនៅពេលនោះ។ ហើយមិនដឹងថាមានអីដែលទាក់ទងនឹងបញ្ហាថ្លែងការណ៍នោះទេ។

**ស៖** នៅសម័យរណសិរ្ស គឺមុនឆ្នាំ៧៥ តើលោកមានធ្លាប់ជួបលោក ហ៊ូ យន់ ទេ? តើ ហ៊ូ យន់ ធ្វើការឲ្យខាងផ្នែកព័ត៌មានទេ?

**ឆ៖** តាមខ្ញុំដឹងមុខងារនៅក្នុងសម័យរណសិរ្ស លោក ហ៊ូ យន់ គឺជារដ្ឋមន្ត្រីទទួលបន្ទុកខាងកែទម្រង់ជនបទ និងសហករណ៍។ ឯពាក់ព័ន្ធនឹងការផ្សាយ ឬក៏ព័ត៌មានស្អីទៀត ខ្ញុំមិនដឹង។

**ស៖** អ៊ីចឹងលោកមិនដែលមានទំនាក់ទំនងអ្វីជាមួយគាត់ទេមែនទេនៅសម័យនោះ?

**ឆ៖** ខ្ញុំមិនដែលមានការទាក់ទងអីជាមួយគាត់ទេ បើជួបជាមួយគាត់ គ្រាន់ថានិយាយលេងធម្មតា ពេលខ្លះទៅក៏កាត់សក់ឲ្យគាត់ទៅជំនាន់សង្គ្រាម៥ឆ្នាំ។ មេដឹកនាំបួនរូបដែលខ្ញុំធ្លាប់កាត់សក់ឲ្យបួនប្រាំរូបហ្នឹងមានលោក ខៀវ សំផន ក៏ខ្ញុំធ្លាប់កាត់សក់ឲ្យគាត់។ ហើយដូច្នេះយើងមិនបាននិយាយលេងអីទេជាមួយកម្មាភិបាលថ្នាក់ខ្ពស់។ ហើយលោក ហ៊ូ យន់ ក៏អាចខ្ញុំធ្លាប់កាត់សក់ឲ្យគាត់ដែរ។ ព្រោះអង្គាល់ហ្នឹងខ្ញុំចេះ ពេលខ្លះខ្ញុំចេះ អ៊ីចឹង ខ្ញុំឆ្លៀតកាត់សក់ឲ្យគាត់ដែរ។

[១៣:៥៩:០៦]

**ស៖** តើលោកដឹងអំពីជោគវាសនារបស់លោក ហ៊ូ យន់ ទេក្រោយឆ្នាំ៧៥ មកនោះ?

**ឆ៖** ខ្ញុំមិនបានដឹងអំពីព័ត៌មានពីលោក ហ៊ូ យន់ ទេ។ បើនៅប-២០ ខ្ញុំធ្លាប់ជួបគាត់។ ប៉ុន្តែឆ្នាំ៧៥ ខ្ញុំមិនដែលជួប។

**ស៖** ឥឡូវនេះចូលទៅដល់ប្រធានបទចុងក្រោយ ដែលពាក់ព័ន្ធទៅនឹងទស្សនាវដ្តីយុវជន យុវនារីបដិវត្ត។ លោកបានឆ្លើយថា លោកជាអ្នកទទួលបន្ទុកក្នុងការរៀបចំ និងបោះពុម្ពទស្សនាវដ្តីនេះ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** អត់ត្រឹមត្រូវទេ។

**ស៖** បើអ៊ីចឹងតើលោកមានតួនាទីអ្វីដែរ ពាក់ព័ន្ធទៅនឹងទស្សនាវដ្តីយុវជន យុវនារីបដិវត្តនេះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្តិច នៅក្នុងរោងពុម្ព យើងបោះឯកសារទស្សនាវដ្តីបី។ មានទង់បដិវត្ត, មានរណសិរ្ស ឯយុវជន យុវនារីនេះ ទើបបោះក្រោយទេ ប្រហែលជាក្នុងឆ្នាំ៧២, ៧៣ ហើយក៏មិនដឹងខ្ញុំមិនចាំ។ ព្រោះខ្ញុំមិនដែលបានជួបឯកសារហ្នឹងទេ ខ្ញុំទើបតែឃើញអង្កាល់នៅមន្ទីរ ៣១ ខ្ញុំនៅឃោសនាការខ្ញុំឃើញ។ ដូច្នេះទស្សនាវដ្តីហ្នឹងទើបនឹងចេញ ដូចក្រោយរណសិរ្ស ឬក្រោយទង់បដិវត្តទេ។ ហើយទស្សនាវដ្តីនេះ គឺសម្រាប់បម្រើសម្ព័ន្ធយុវកក។

[១៤:០១:៣៣]

**ស៖** តើលោកដឹងទេ អ្នកណាជាអ្នកសរសេរអត្ថបទសម្រាប់ទស្សនាវដ្តីយុវជន យុវនារី បដិវត្តនេះ?

**ឆ៖** តាមខ្ញុំដឹង បង្កើតដំបូងមានតែលោកស្រី យុន យ៉ាត គាត់សរសេរ។

**ស៖** ដើម្បីឲ្យបានច្បាស់នោះ គឺថាលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា "យុន យ៉ាត ជាអ្នកសរសេរអត្ថបទ ដោយមានជំនួយពីក្រុមរបស់ខ្ញុំ"។ តើព័ត៌មាននេះត្រឹមត្រូវដែរឬទេ? គឺមានន័យថា លោកមានក្រុមការងាររបស់លោកមួយសម្រាប់ជួយលោកស្រី យុន យ៉ាត ក្នុងការសរសេរអត្ថបទសម្រាប់ទស្សនាវដ្តីនេះ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដហើយ ប៉ុន្តែមិនមែននៅក្នុងរណសិរ្សរួបរួមជាតិទេ គឺនៅក្នុងរយៈពេល ៣ឆ្នាំ ហើយប្រពន្ធខ្ញុំក៏បានធ្វើជាលេខាផ្ទាល់សម្រាប់ធ្វើអត្ថបទនេះដែរ។ ហើយក្រោយមកបានពួកខ្ញុំមួយចំនួនក៏អាចជួយសរសេរជាដំណឹង ព្រោះអត្ថបទធំៗខាងរដ្ឋមន្ត្រីមានកម្លាំងគាត់ធ្វើផ្សេងទៀត។

ជួយយុវជន យុវនារី ជំនាន់៣ឆ្នាំ គឺមានពួកខ្ញុំជួយសរសេរជាដំណឹងខ្លីៗខ្លះ។

[១៤:០៣:២១]

**ស៖** តើទស្សនាវដ្ដីយុវជន យុវនារីបដិវត្តនេះសម្រាប់អ្នកណា? គឺមានន័យថា មាន -- តើអ្នកដែលមានអាយុពីប៉ុន្មានឆ្នាំទៅបានអាចអានទស្សនាវដ្ដីនេះបាន?

**ឆ៖** មែនទែនចូលជាសមាជិកសម្ព័ន្ធយុវកកបានទាល់តែអាយុ១៨ឆ្នាំ ដូច្នេះអាយុ១៨ឆ្នាំ អាចចូលសម្ព័ន្ធយុវកកបានហើយ។ ហើយក៏មានសិទ្ធិអានទស្សនាវដ្ដីហ្នឹងដែរ។ ហើយយុវជនផ្សេងទៀតក៏គេអាចអានបានដែរ ប៉ុន្តែក្របខ័ណ្ឌបម្រើគឺបម្រើសម្ព័ន្ធយុវកក។

**ស៖** ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តនេះ គឺមានគោលដៅបំពាក់បំប៉នមនោគមន៍វិជ្ជា តើមានគោលដៅក្នុងការជំរុញឲ្យមានកំហឹងពីសំណាក់យុវជន ឬក៏ធ្វើឲ្យយុវជនទុំងស្អប់ទៅលើវណ្ណៈ -- ទៅលើខ្មាំងនៃវណ្ណៈ ហើយនិងជំរុញឲ្យយុវជន យុវនារីហ្នឹងកម្ទេចខ្មាំងរបស់ប្រជាជាតិរហូតទៅដល់ផុតរលត់អស់ពីក្នុងទឹកដីនោះ តើលោកមានចាំទេ ចាំអំពីការផ្សាយណាមួយនៅក្នុងទស្សនាវដ្ដីនេះដែលមានគោលដៅដូចដែលខ្ញុំបានរៀបរាប់នេះទេ?

[១៤:០៥:០៣]

**ឆ៖** ខ្ញុំមិនបានយល់ឲ្យជ្រាលជ្រៅជាងនេះទៀតទេ។ ព្រោះខ្ញុំឃើញថា បក្សកុម្មុយនីស្តកម្ពុជាអាចចាត់ទុកសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជាគឺជាដៃស្តាំរបស់បក្ស ដូច្នេះអ្នកណាចូលក្នុងហ្នឹងគឺជាអ្នកអនុវត្តការងារអីមួយដែលឈានមុខគេ ដូច្នេះគឺខ្លឹមសារហ្នឹងបម្រើអ៊ីចឹង។ ហើយអង្គការយុវជន យុវនារីនេះក៏ត្រូវមានការអប់រំនយោបាយស៊ីជម្រៅជាងមហាជនធម្មតាដែរ។

**ស៖** តើការបណ្តុះមនោគមវិជ្ជានេះគឺថា មានការជំរុញឲ្យមានការខឹង ឬការស្អប់ខ្មាំងដែរទេ?

**ឆ៖** ខ្មាំងសត្រូវតាមពិតទៅ យើងមិនគិតថាអីសុទ្ធតែជាខ្មាំងទេ សូម្បីតែគូសត្រូវយើងក៏យើងក៏ចាត់ទុកជាមិត្តបានដែរ។ ឧទាហរណ៍ថា មនុស្សហ្នឹងគ្នាអត់ដាច់ខាតផង ស្ទាក់ស្ទើរអីអ៊ីចឹង ដូច្នេះយើងមិនអាចចាត់ទុកថាអ្នកហ្នឹងជាខ្មាំង ១០០ភាគរយទេ ត្រូវមានវិធីធ្វើម៉េច? ដូច្នេះការអប់រំសម័យនោះគឺគេឲ្យមានការវិភាគចំណុចខ្លាំងខ្សោយ ព្រោះមនុស្សវាមានចំណុចខ្លាំង និងចំណុចខ្សោយ។ ដូច្នេះបើយើងមើលថា តែខ្មាំងទាំងអស់អ៊ីចឹង ខ្មាំងសម័យនោះគេចង្អុលតែប្រាប់មេដឹកតែប៉ុន្មាននាក់ទេ។ នៅក្នុងពាក្យស្លោករបស់រណសិរ្សរួបរួមជាតិកម្ពុជាគឺក្នុងសម័យធ្វើសង្គ្រាម គឺនិយាយពីពួកមេរដ្ឋប្រហារតែប៉ុន្មាននាក់ហ្នឹង។ អ្នកពាក់ព័ន្ធនឹងរដ្ឋប្រហារទម្លាក់សម្តេចឪ គឺចាត់ទុកជាខ្មាំង។ ហើយទស្សនាវដ្ដីនេះបើ

និយាយមែនទែនវាមានធាតុផ្សំទាំងរណសិរ្សផងដែរ បើគិតទៅ។ វាមិនមែនធាតុផ្សំតែបក្សកុម្មុយនីស្ដកម្ពុជាតែមួយមុខទេ។ បើនិយាយពីរណសិរ្ស គឺវារួមផ្សំកម្លាំងជាតិទាំងអស់ចូលរួមក្នុងហ្នឹង។ អ៊ីចឹងក្នុងការដុតកំហឹង ចងកំហឹងអីគឺមិនមែនចេះតែធ្វើៗទេ គឺមានគោលដៅមួយច្បាស់លាស់។

[១៤:០៧:៥៥]

**សៈ** លោកសាក្សី តើលោកមាននៅចាំអំពីកំណាព្យមួយដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅទស្សនាវដ្ដីលេខ១០ ខែតុលា ឆ្នាំ១៩៧៥ ឃើញនៅក្នុងទស្សនាវដ្ដីយុវជន យុវនារីបដិវត្ដហ្នឹងហើយ។ គឺឯកសារលេខ E3/729 ERN ជាភាសាខ្មែរ 0063432 (ស៊ីក) ទៅដល់ 33, ភាសាបារាំង 00364250 ទៅដល់ 51, ERN ជាភាសាអង់គ្លេស 00357929 ទៅដល់ 30។ គឺមានចំណងជើងថា "កុំភ្លេចគំនុំឈាមបុព្វបុរសបដិវត្តន៍យើង"។ តើលោកមាននៅចាំអំពីកំណាព្យមួយនេះទេ?

**ឆៈ** ខ្ញុំអាចឮ តែខ្ញុំមិនចាំ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើលោកមិនដឹងទេ ខ្ញុំអស់សំណួរហើយ។ សូមអរគុណចំពោះការឆ្លើយសំណួររបស់លោក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនមេធាវីពីរក្រុមទៀត។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។

[១៤:០៩:៤០]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក គង់ សំអុន៖**

សូមគោរព -- ជម្រាបសួរលោក គឹម វុន។ ខ្ញុំ គង់ សំអុន មេធាវីរបស់លោក ខៀវ សំផន មានសំណួរចំនួន ដើម្បីតាំងសួរលោក ហើយសូមឲ្យលោកជួយសហការឆ្លើយនូវសំណួរដែលពាក់ព័ន្ធតាម

ដែលលទ្ធភាពលោកដឹងបាទ។

**ស៖** ក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ លោកបានចំណាយពេលយ៉ាងច្រើន ហើយឆ្លើយទៅនឹងបញ្ហាពាក់ព័ន្ធនឹងតួនាទីរបស់លោក ខៀវ សំផន។ ហើយអ្វីដែលលោកបានឆ្លើយចំពោះតំណាងសហព្រះរាជអាជ្ញា ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាលោកចៅក្រម ឡាវ៉ែន៍ អម្បាញ់មិញនេះ។ ខ្ញុំសូមមានសំណួរមួយចំនួនទៀតហ្នឹង ដើម្បីបញ្ជាក់បន្ថែមទៅលើអ្វីដែលជាប្រយោជន៍សម្រាប់អង្គជំនុំជម្រះនៅទីនេះ ត្រូវការដើម្បីធ្វើការសម្រេចសេចក្តីទៅលើវាសនារបស់លោក ខៀវ សំផន នេះ។ ជាចំណុចរួម ខ្ញុំនឹងសួរលោកពាក់ព័ន្ធនឹងអំណាចរបស់លោក ខៀវ សំផន ហើយដែលភាគីខាងដើមបានសួរយ៉ាងច្រើនហើយ ពាក់ព័ន្ធទៅនឹងការអត្ថាធិប្បាយរបស់លោក ដែលលោកបានប្រៀបធៀបទៅនឹងដំរីពិការ ដែលជាអំណាចរបស់លោក ខៀវ សំផន ថាមិនមានកម្លាំងជាដំរីគ្មានជើង។

[១៤:១១:១០]

នេះជាអ្វីដែលលោកបានរៀបរាប់កន្លងមក ហើយអម្បាញ់មិញនេះ លោកចៅក្រម ឡាវ៉ែន៍ ក៏បានសួរបញ្ជាក់ឲ្យលោកបង្ហាញពីភស្តុតាងនានា ដើម្បីគាំទ្រនូវការអះអាងរបស់លោក ថាហេតុអីបានជាលោកប៊ានថា លោក ខៀវ សំផន គ្មានអំណាចនៅពេលនោះ។ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងវ័យកុមារភាពរបស់លោក កាលឆ្នាំ៦៦,៦៧ ដែលលោកបានឆ្លើយថា លោកមានបងប្រុសរបស់លោកជាមន្ត្រីរាជការបាននិទានរឿងរបស់លោក ខៀវ សំផន ឲ្យលោកស្តាប់។

តើលោកនៅចាំបានថា ជាសម្តីរបស់លោកធ្លាប់ឆ្លើយចំពោះអ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតនៃតុលាការនេះដែរទេ?

**លោក គឹម វុន៖**

**ឆ៖** នៅពេលនោះ ខ្ញុំមិនបានឆ្លើយលម្អិតអំពីលោក ខៀវ សំផន ទេ ប៉ុន្តែខ្ញុំនៅចងចាំ បងប្រុសគាត់ធ្លាប់និយាយ កាលខ្ញុំនៅក្មេងតូចៗ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ កាលហ្នឹងលោកអាយុប្រហែលប៉ុន្មានដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលនិយាយ ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ!

**លោក គឹម វុន៖**

**ឆ៖** បាទ នៅពេលនោះ ខ្ញុំប្រហែលអាយុប្អូនប្រាំឆ្នាំហើយ តាមមើល។ ព្រោះខ្ញុំមិនចាំដែរ ព្រោះយូរហើយ។ អង្គាល់ ស៊ីម គាត់និយាយ គឺគាត់និយាយតែរឿងលោក ខៀវ សំផន ទេ ព្រោះគាត់មករៀននៅភ្នំពេញ។ ការទស្សន៍ទាយរបស់គាត់ គឺត្រូវ។

[១៤:១៣:៣០]

**ស៖** បាទ ដើម្បីកំណត់ត្រា ខ្ញុំបាទសូមបង្ហាញជូនឯកសារ D201/10.1 ដែលជា -- ដោយសារពុំមានបកប្រែ អ៊ីចឹង ខ្ញុំសូមអានសាឡើងវិញ។ នៅក្នុងប្រតិចារឹកដែលបានធ្វើសម្ភាសលោក ដោយអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនោះ ដែលមានលេខសម្គាល់ D201/10.1 ដែលមានលេខ ERN ជាភាសាខ្មែរ 00833791, ជាភាសាអង់គ្លេស 00834919, ជាភាសាបារាំង 00835738 ដល់ 39។ ក្នុងកាលនោះ លោកបានឆ្លើយនៅក្នុងខ្សែអាត់ ប៉ុន្តែមិនមាននៅក្នុងសម្រង់សង្ខេប នៃចម្លើយរបស់លោកទេ ដែលបញ្ជាក់ថា ខ្ញុំសូមអានជូនទាំងស្រុងនូវចម្លើយរបស់លោក។ មានពីរចំណុចជាប់គ្នា ប៉ុន្តែសំខាន់នៅចំណុចចុងក្រោយ ដែលខ្ញុំចង់និយាយពេលនេះ ប៉ុន្តែដោយសារវា២ នៅក្នុងផ្នែកជាប់គ្នា អ៊ីចឹងខ្ញុំសូមអានអានទាំងពីរ។ លោកឆ្លើយថា "ជំនាន់រណសិរ្សហ្នឹង នៅជាមួយគាត់ ខ្ញុំមិនដែលឃើញថា គាត់មានអំណាចអី។ អ៊ីចឹងបានខ្ញុំថា ដំរីហ្នឹងធំតែដំរី ប៉ុន្តែដូចដំរីបាក់ជើង ដំរីអត់មានកម្លាំង ហើយជុំវិញបញ្ហានេះលោក ខៀវ សំផន ខ្ញុំដឹងប្រវត្តិគាត់មក ហើយធ្លាប់រៀនសូត្រ ធ្លាប់ឮបងនិទានកាលជំនាន់៦៧, ៦៨ មក ព្រោះបងប្អូនខ្ញុំ អ្នករាជការនៅភ្នំពេញដែរ។ គាត់តែងនិយាយនិទានរឿង ខៀវ សំផន អី១ ហើយសម័យនោះ គឺបើនិយាយក្នុងរដ្ឋអំណាចរបស់សម្ដេច សីហនុ នោះ ខៀវ សំផន ឃើញតែរងគ្រោះហើយ"។

[១៤:១៦:២៥]

លោកមានចាំ -- បាទ សូមទោស ដោយសារខ្ញុំត្រូវទុកពេលសម្រាប់ការបកប្រែ អ៊ីចឹងខ្ញុំបង្អង់បន្តិច ចាំខ្ញុំសួរបន្ត ចាំលោកឆ្លើយ។

អ៊ីចឹងសូមលោកឆ្លើយបញ្ជាក់ថា តើលោកចាំការថ្លែងបែបនេះទេ កាលអ្នកស៊ើបអង្កេតទៅសួរលោកនោះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

លោករង់ចាំក្បាលមីក្រូប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាក្រហមជាមុនសិន សឹមលោកនិយាយ ទើបប្រព័ន្ធសំឡេងរបស់លោកចូលទៅក្នុងប្រព័ន្ធសំឡេង ដែលអ្នកបកប្រែអាចបកប្រែទៅជាភាសាផ្សេងៗទៀត ហើយភាគីពាក់ព័ន្ធជាភាសាខ្មែរ ក៏អាចស្តាប់បានដែរ។

**លោក គីម វុន៖**

**ឆ៖** បាទ ខ្ញុំចាំ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ តើលោកអាចរៀបរាប់អំពីការនិទានរបស់បងប្រុសលោក ចំពោះលោកកាលពីសម័យនោះដែរទេ ទាក់ទងនឹងលោក ខៀវ សំផន នេះ?

**ឆ៖** កាលបង ស៊ីម និយាយប្រាប់ខ្ញុំ គាត់តែងតែនិទានរឿងហ្នឹង ប៉ុន្តែខ្ញុំមិនដឹងគោលបំណងគាត់ជាស្អី ព្រោះគាត់មករៀននៅភ្នំពេញ។ និទានពីរឿង ខៀវ សំផន តាមខ្ញុំចាំគាត់និយាយថា លោក ខៀវ សំផន មែនទែន កាលនោះដូចមានឋានៈជាមន្ត្រីថ្នាក់ខ្ពស់ដែរ។ ប៉ុន្តែឃើញថា នៅក្នុងជីវភាពរបស់គាត់ក្នុងសម័យនោះ ដូចជាមិនល្អប្រសើរដូចអ្នកដទៃទេ ឃើញថា ជួនកាលគាត់ជិះកង់ដូចប្រជាជនធម្មតា។ ដូច្នេះ វាបើយើងមើលទៅ ថាដូចជាមិនមែនជាមន្ត្រីថ្នាក់ខ្ពស់របស់រដ្ឋាភិបាលទេ ប៉ុន្តែខ្ញុំនៅក្មេង ខ្ញុំគ្រាន់តែចាំពាក្យ ខ្ញុំមិនចាំ -- យើងដឹងជាវិញ្ញាណ ហើយការចងចាំរបស់ខ្ញុំពីសម័យនោះមកឥឡូវ អាចចាំដោយស្រពេចស្រពិល ព្រោះខ្ញុំចេះតែស្តាប់គាត់ទៅ។ ហើយចំណុចដែលគាត់និយាយមួយទៀត គឺថា អូនឯងចាំមើល ខៀវ សំផន ឡើងប្រធានាធិបតី។ ហើយខ្ញុំក៏មិនចាប់អារម្មណ៍ ព្រោះខ្ញុំមិនយល់ថា ស្អីប្រធានាធិបតីផង ព្រោះខ្ញុំនៅក្មេង ប៉ុន្តែគាត់ប្រើពាក្យៗ អ៊ីចឹង។

[១៤:១៩:១៤]

ហើយម្យ៉ាងទៀតរឿងរាជការធ្វើបាបគាត់សម័យនោះ ជួនកាលគាត់និយាយដែរ ប៉ុន្តែខ្ញុំមិនដឹងគាត់ជាអ្នកតស៊ូ ឬក៏យ៉ាងម៉េចទេ ខ្ញុំមិនដឹងទេ។ ព្រោះនៅក្នុងសម័យនោះ នៅខាងតំបន់ដែលខ្ញុំធ្លាប់រស់នៅ ធ្លាប់ឮគេនិយាយថា មានខ្មែរក្រហមមានអី។ ហើយមិនដឹងថា ការនិយាយស្តីរបស់គាត់ពាក់ព័ន្ធនឹងចលនាតស៊ូ ឬយ៉ាងណាទេ ខ្ញុំមិនដឹងដែរ ប៉ុន្តែខ្ញុំធ្លាប់តែឮបងនិយាយប្រាប់អ៊ីចឹង។ ហើយយើងក្មេងៗ យើងមិនបានចាប់អារម្មណ៍អីស៊ីជម្រៅថា អ្នកណាជាស្អីទេ។ នេះគ្រាន់តែជាការចងចាំខ្ញុំជាវិញ្ញាណ ឯវិចារណញ្ញាណដើម្បីពិចារណាថា តើគេនិយាយហ្នឹងដើម្បីអី ខ្ញុំអត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងអាយុរបស់លោកនៅក្នុងឯកសារ E3/380 ដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់លោកហ្នឹង លោកបានបញ្ជាក់ថា លោកកើតនៅឆ្នាំ១៩៥៩។ ខ្ញុំចង់សួរថា តើនេះជាឆ្នាំកំណត់របស់លោកពិតប្រាកដ ឬក៏លោកមានបន្ថយ បន្ថែមអាយុអីដែរក្នុងការជាក់ស្តែងរបស់លោកនោះ?

[១៤:២០:៥១]

**ឆ៖** មែនទែននៅក្នុងសម័យបដិវត្តន៍ យើងអាចប្រើឈ្មោះពេលផ្លាស់ទីកន្លែង ហើយមានមួយចំនួនក៏អាចកែឈ្មោះកំណើតរបស់ខ្លួនហ្នឹងបានដែរ។ ប៉ុន្តែខ្ញុំ ខ្ញុំមិនកែទេ ខ្ញុំយក និងប្រើរហូត។ ពិសេសជាមួយ បងវង មកភាគខាងជើង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ទាក់ទងនឹងអាយុរបស់លោកកាលនោះ បើសិនជាលោកកើតឆ្នាំ៥៩ គឺរឿងនិទានដែលបងប្រុសរបស់លោកបាននិទានពីឆ្នាំ៦៧ ដល់៦៨ នោះ លោកអាចមានអាយុ ១១ ទៅ១២ ឆ្នាំហើយមែនទេ? អ៊ីចឹងមែនទេ? ត្រឹមត្រូវទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមលោកជួយឆ្លើយសាថ្មី ព្រោះអម្បាញ់មិញមីក្រូអត់បើក។

**ឆ៖** អាចនៅក្នុងចន្លោះហ្នឹងហើយ។

[១៤:២២:២០]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំបាទ ចង់សួរលោកទាក់ទងទៅនឹងលោក ខៀវ សំផន ដែលលោកបានជួបនៅរោងពុម្ពនៅក្នុងព្រៃ មុនឆ្នាំ១៩៧៥នោះណា។ ខ្ញុំចង់សួរលោកថា តើរយៈពេលប៉ុនណាដែរ ដែលលោកបាននៅក្នុងកន្លែងរោងពុម្ពហ្នឹង ហើយបានឃើញលោក ខៀវ សំផន ចេញចូលនៅទីនោះ ដែលលោកបានបញ្ជាក់ថា លោក ខៀវ សំផន ចេញចូលញឹកញាប់នៅកន្លែងរោងពុម្ពរបស់លោកនោះ?

**ឆ៖** នៅឆ្នាំ១៩៧១ តាមខ្ញុំចាំ គាត់មិនចេញចូលនៅកន្លែងខ្ញុំធ្វើការហ្នឹងញឹកញាប់ទេ ព្រោះឯកសារផ្សេងៗច្រើនតែយកមកតាមនីរសារ ហ្នឹងតាមខ្ញុំចាំ។ ប៉ុន្តែដល់ក្រោយមកឃើញថា ជួនកាលត្រូវការបង្កើតរោងពុម្ពហ្នឹងឲ្យកាន់តែរីក និងមានការងារផ្សេងទៀតជាការផ្សព្វផ្សាយវិទ្យុ។ អ៊ីចឹងឃើញថា កម្លាំងហ្នឹងកាន់តែរីកធំហើយ។ អ៊ីចឹងវត្តមានរបស់គាត់នៅពេលនោះ គឺថានៅជាមន្ទីររួមតែមួយ ហើយមានកម្មាភិបាល ដែលធ្វើការងាររណសិរ្សហ្នឹងច្រើននៅហ្នឹងដែរ។ ដូច្នេះបើនិយាយទៅនៅ

ជាមួយគ្នា មួយរយៈហ្នឹង។ ប៉ុន្តែខ្ញុំមិនចាំថា នៅក្នុងពេលដែលមានកម្មាភិបាលច្រើន មកធ្វើការងាររួមគ្នានៅកន្លែងនុំងមានចំនួនប៉ុន្មាននាក់អី ក៏ខ្ញុំមិនបានចងចាំដែរ។ ប៉ុន្តែក្នុងហ្នឹងក៏មានវត្តមានរបស់លោក ខៀវ សំផន នៅក្នុងមន្ទីរនោះដែរ។

[១៤:២៤:១៨]

**ស៖** បាទ សូមអរគុណ។ តើលោកអាចចាំពីរយៈពេលដែលលោកនៅក្នុងមន្ទីរជាមួយគ្នាជាមួយនឹងលោក ខៀវ សំផន ដែរនោះដែរឬទេ? រយៈពេលប៉ុន្មានដែរ? ប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ឆ្លើយ! ចាំក្បាលមីក្រូឲ្យភ្លើងសញ្ញាក្រហមសិន ចាំឆ្លើយ!

**លោក គីម វុន៖**

**ឆ៖** ខ្ញុំមិនចាំពេលថាយូរប៉ុនណាទេ ប៉ុន្តែខ្ញុំឃើញថាគាត់នៅមួយរយៈ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ តើលោកអាចចំណាំបានលោក ខៀវ សំផន ដូចម្តេចដែរ នៅពេលដែលលោកជួបលោក ខៀវ សំផន នៅក្នុងព្រៃដែលលោកថាពីឆ្នាំ៧១ រហូតមកហ្នឹង?

[១៤:២៥:២២]

**ឆ៖** មុនដំបូង ខ្ញុំមិនដឹងថា លោក ខៀវ សំផន ហ្នឹងមុខមាត់យ៉ាងម៉េចទេ។ ប៉ុន្តែតាមរយៈមេខ្ញុំ បងបាន គាត់ជាបញ្ញវន្តដែរ គាត់ជាសាស្ត្រាចារ្យ។ ចង់មិនចង់ អ្នកស្និទ្ធស្នាល គាត់ចេះតែប្រាប់ ព្រោះខ្ញុំអ្នកឆ្ងល់ដែរ។ ខ្ញុំថា "បងម្នាក់សៗដូចចិនហ្នឹងមកពីណា?" ព្រោះក្នុងហ្នឹងមានកម្មាភិបាលមកពីយួនខាងជើង មាននឹងអ្នកនៅស្រុកខ្មែរ។ ខ្ញុំមុនដំបូង ខ្ញុំស្មានតែគាត់មកពីហាណូយ មកពីអីទេ ព្រោះដូចបងវង មេខ្ញុំនេះគាត់មកពីហាណូយ។ ពួកបងលឹម, ពួកបងយឿង អីដូចមកពីហាណូយ។ អ៊ីចឹងអង្កាល់នោះ ខ្ញុំសន្និដ្ឋានថា លោក ខៀវ សំផន មកពីហាណូយដែរ។ អ៊ីចឹងក្រោយមក បានខ្ញុំចេះតែសួរ បងបានហ្នឹង បងបាន ប្រាប់ថា "ហ្នឹងហើយ ខៀវ សំផន ណ៎ះមើលអត្ថបទគាត់ ភាសាបារាំងអីហ្នឹង"។ ហើយអង្កាល់ហ្នឹង បងបាន វ៉ៃអង្គុលីលេខភាសាបារាំង។ ដល់អ៊ីចឹងទៅ ខ្ញុំចាំ ខ្ញុំស្គាល់គាត់តាំងពីពេលនោះ មិនមែនគាត់និយាយប្រាប់ថា "ខ្ញុំ ខៀវ សំផន អីទេ"។ គឺខ្ញុំចាំតាមមេខ្ញុំប្រាប់ ព្រោះខ្ញុំឆ្ងល់ ខ្ញុំចេះតែសួរថា "អ្នកមកពីភាគខាងជើង ឬក៏អ្នកនៅក្នុងស្រុក"។ ព្រោះគាត់ -- មែនទែនគាត់ជ្រះស ដល់អ៊ីចឹង

ហើយនិយាយកាលនោះ គាត់ចំណាស់ដែរហើយ។ អ៊ីចឹងខ្ញុំសន្និដ្ឋានថា មនុស្សមកពីភាគខាងជើង។

[១៤:២៦:៤៨]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកដឹងថា បុរសម្នាក់ដែលលោកជួបនោះ ជាលោក ខៀវ សំផន។ តើមានការកត់សម្គាល់អ្វីពីគាត់ដែរទេ?

**ឆ៖** កាលនៅជាមួយគ្នា ខ្ញុំតែងតែរៀនសូត្រអំពីអត្តចរិតរបស់គាត់ដែរ។ ហើយម្យ៉ាងដល់និយាយពីប្រវត្តិជាក់ស្តែងតាមបងបាន គាត់និយាយមក និយាយពីប្រវត្តិរបស់គាត់ លំបាកក្នុងការតស៊ូអីលះបង់។ ហើយចំណាស់គាត់ប៉ុណ្ណឹងគួរតែមានគ្រួសារអ៊ីចឹង។ អ៊ីចឹងខ្ញុំឃើញថា ធ្វើឲ្យខ្ញុំបានរៀនសូត្រពីគាត់ដែរ ព្រោះឃើញថាមានអ្នកចេះដឹងអ៊ីចឹង ហើយដល់មានរដ្ឋប្រហារអ៊ីចឹងទៅ គាត់ធ្វើការតស៊ូរួមជាមួយសម្តេចឪទៅ។ ព្រោះជា -- តាមពិតទៅ ខ្ញុំ ឥទ្ធិពលសម្តេចឪហ្នឹង វាគ្របដណ្តប់ច្រើនជាង។ ដែលខ្ញុំយល់មុនដំបូង យល់ចូលបដិវត្តន៍ដំបូង គឺដោយឥទ្ធិពលសម្តេចឪទេ។ ដល់អ៊ីចឹងកម្មាភិបាលក៏និយាយតែអ៊ីចឹង ដើម្បីឲ្យយើងធ្វើការ។ ដូច្នេះ ខ្ញុំឃើញថា ជាអត្តចរិត ជាធម្មជាតិរបស់គាត់គឺជាមនុស្សមួយមិនប្រកាន់ខ្លួនដែរ។ ហើយចេះលើកទឹកចិត្តក្មេងៗ ចេះនិយាយលេងសើចជាមួយក្មេងៗ។ បើគាត់អង្គុយធ្វើការងារក្នុងការិយាល័យ អផ្សុកអ៊ីចឹងទៅ គាត់ដើរចុះឡើងៗ។ ហើយខ្ញុំឃើញថាគំរូដែលគាត់ធ្វើហើយ ចំណាស់ប៉ុណ្ណឹងអត់ទាន់មានគ្រួសារអ៊ីចឹង។ ខ្ញុំថា “ពួកខ្ញុំក៏អាចធ្វើបានដូចគាត់ដែរ”។

[១៤:២៨:០១]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន សូមជាភាសាបារាំងនោះ យើងឮនៅក្នុងខាងដើមចម្លើយរបស់សាក្សីនេះ ឮនិយាយថា ខៀវ សំផន នោះជាមនុស្សឈ្លើយ។ ហើយអ៊ីចឹង ខ្ញុំសូមការបញ្ជាក់បន្តិចពីព្រោះថាប្រហែលជាអាចខុស។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ អ៊ីចឹងសូមរំខាន លោក គីម វុន ជួយបញ្ជាក់សាឡើងវិញ។ អានេះជាបញ្ហាបកប្រែទេ ការពិតលោកបានឆ្លើយជាភាសាខ្មែរ គឺបានច្បាស់លាស់ហើយ។

**លោក គីម វុន៖**

សំណួរយ៉ាងម៉េច?

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សំណួរនោះថា ជាភាសាបារាំង ឮថាលោកឆ្លើយថា “លោក ខៀវ សំផន ជាមនុស្សល្អើយ” តើលោកបានឆ្លើយអ៊ីចឹងមែនទេ? ឬមួយក៏លោកថាយ៉ាងម៉េចបាទ? សូមជួយកែសម្រួល។

[១៤:៣០:១២]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់និយាយ! ចាំមើលភ្លើងសិនណ៎ា ភ្លើងក្រហមសិន។

**លោក គីម វុន៖**

**ឆ៖** ចម្លើយរបស់ខ្ញុំមិនមាននិយាយថាគាត់ល្អើយទេ។ ខ្ញុំនិយាយថា ខ្ញុំអាចនឹងរៀនសូត្រពីគាត់ព្រោះគាត់ចំណាស់ប៉ុណ្ណឹងហើយ គាត់អត់ទាន់មានគ្រួសារ។ ដូច្នេះពួកខ្ញុំហ្នឹងអាចនឹងធ្វើតាមគាត់ដែរ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណចំពោះការឆ្លើយបញ្ជាក់។ ហើយខ្ញុំបាទនឹងសួរតទៅទៀត។ បាទ សូមអរគុណ ខ្ញុំសូមសួរត។ ទាក់ទង -- ខ្ញុំសូមសួរលោកទាក់ទងទៅនឹងលោក ខៀវ សំផន ជួយលើកទឹកចិត្តដល់លោកដែលកាលណោះ លោកនៅក្មេងៗនៅឡើយ ហើយជាមួយនឹងអ្នកដទៃទៀតដែលនៅធ្វើការនៅក្នុងរោងពុម្ព។ ខ្ញុំចង់សួរថា តើការលើកទឹកចិត្តរបស់លោក ខៀវ សំផន ហ្នឹង គាត់បាននិយាយពាក្យអ្វីពិតប្រាកដ ច្បាស់លាស់ដែលលោកបានចាំ អាចឆ្លើយបាន?

[១៤:៣២:០៧]

**ឆ៖** ជាធម្មតា យើងដឹងហើយ ធម្មជាតិក្មេងៗកាលណាបែកពីឪពុកម្ដាយនៅក្មេងពេក តែងតែយំនឹកផ្ទះ នឹកបង នឹងប្អូន ម៉ែឪអ៊ីចឹងទៅ។ ហើយគាត់តែងតែនិយាយលួងលោមថា “ម៉េចសង្គ្រាមអ៊ីចឹងយើងមិនចង់បែកណា”។ ដូច្នេះគាត់និយាយច្រើន បើខ្ញុំមិនចាំអស់ទេ ប៉ុន្តែក្នុងន័យហ្នឹង។ គាត់លើកពីសង្គ្រាម លន់ នល់ ធ្វើរដ្ឋប្រហារអ៊ីចឹង ហើយសម្ដេចអីធ្លាក់ពីអំណាចអីអ៊ីចឹង។ ភាគច្រើនគាត់និយាយភាសាជារណសិរ្ស។ ហើយឱ្យយើងហ្នឹងចេះទ្រាំទ្រ ចេះប្រុងប្រយ័ត្ន។ ព្រោះនៅសម័យនោះ ប្រុងប្រយ័ត្នយ៉ាងម៉េច? ឧបមាថាដាំបាយ យើងត្រូវរកកន្លែងធ្វើចង្ក្រាន មានដំបូកអ៊ីចឹងទៅ ហើយជីកប្រឡាយឱ្យវែងអ៊ីចឹងទៅ ដើម្បីឱ្យផ្សែងវាមកហ្នឹង ផ្សែងដែលយើងដុតទៅ ដល់ព្រៃស្រោងអ៊ីចឹងទៅ វាអត់មានផ្សែងទេ។ ផ្សែងហ្នឹងវានៅរាបតាមដីអ៊ីចឹង។ ដូច្នេះគាត់ណែនាំអ៊ីចឹង។ មែនទែន គឺយើងធ្វើចង្ក្រានរបៀបហ្នឹង។ ដល់ពេលយើងដាំបាយទៅ វាអត់មានផ្សែងទៅលើទេ។ ហើយបើមានផ្សែង គឺ

គ្រោះថ្នាក់ហើយ។ បើមិនបេ-៥២ ទេ ក៏អាអេស១០៥ ឬក៏ អេស១១១ វាទម្លាក់លើហើយ។

[១៤:៣៣:៤៣]

អ៊ីចឹងការលើកទឹកចិត្តរបស់គាត់ ម្យ៉ាងលើកទឹកចិត្តថាយើងទ្រាំទ្រអ៊ីចឹងទៅ។ នឹកឪពុកម្ដាយបងប្អូន ហ្នឹងមួយ។ ប៉ុន្តែឲ្យប្រុងប្រយ័ត្នក្នុងការរស់នៅប្រចាំថ្ងៃ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកបន្ថែមថា តើការលើកទឹកចិត្តរបស់លោក ខៀវ សំផន នៅពេលនោះ មានប្រើនូវពាក្យណាមួយដែលញុះញង់ឲ្យលោកប្រព្រឹត្តនូវអំពើហិង្សា ឬក៏ប្រើកម្លាំងឃោរឃៅដែរឬទេ?

**ឆ៖** ពាក្យដែលលោក ខៀវ សំផន ញុះញង់ ខ្ញុំដូចមិនដែលឮទេ។ បើអប់រំ ដំបូងគឺមានរៀនសីលធម៌១២ប្រការ។ ខ្លឹមសារ១២ប្រការ គឺមែនទែនទៅ ខ្ញុំធ្លាប់នៅក្មេងវត្ត ហើយវា -- បើគិតទៅបើថាអនុវត្ត១២ប្រការហ្នឹងបាន វាល្អហើយ ព្រោះគាត់ណែនាំអ៊ីចឹងដែរ ការអប់រំ។ កុំប៉ះពាល់ពាក្យសម្ដីអ្នកដទៃ នាំឲ្យគេឈឺចិត្តអីៗហ្នឹង គឺតែងតែមានក្នុងសីលធម៌ ១២ប្រការហ្នឹងឯង។ ឧបមាថា ខ មួយទៀតរឿងទ្រព្យសម្បត្តិយើងចង់បានរបស់អ្នកដទៃអីហ្នឹង គឺថាសូម្បីតែម្ទេសមួយផ្លែក៏ដោយ បើម្ចាស់គេមិនបានឲ្យ ក៏យុទ្ធជនរបស់រណសិរ្សហ្នឹងគឺមិនត្រូវការប៉ះពាល់ទេ។ នេះជាឧទាហរណ៍ ជាខ្លឹមសារខ្លះបន្ថែមទៅលើការលើកទឹកចិត្ត ក៏ដូចជាការអប់រំដែរ។

[១៤:៣៥:៥៨]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការចំណាំអក្សររបស់លោក ខៀវ សំផន មិនមែនតែត្រឹមចំណាំអក្សរទេ លោកចំណាំដល់ទៅសំណេររបស់លោក ខៀវ សំផន ដែលលោកសរសេរជាអត្ថបទជាដើម ហើយដែលអម្បាញ់មិញនេះ មុននេះលោកចៅក្រម ឡាវែន៍ គាត់បានសួរបញ្ជាក់ទៅលើលោកថា ដោយលោកអះអាងថា ឃ្លារបស់លោក ខៀវ សំផន ច្រើនសរសេរវែង គ្មានខណ្ឌ ហើយលោកបានសួរបញ្ជាក់ឲ្យលោកបន្ថែមទៅអ្វីដែលជាអំណះអំណាង ដែលអាចឲ្យលោកសម្គាល់បានថាជាអត្ថបទរបស់លោក ខៀវ សំផន សរសេរនោះបាទ។ ខ្ញុំសូមសួរលោកបន្ថែមថា ក្រៅពីឃ្លាវែង មានខណ្ឌរង្វើល ថាតើខ្លឹមសារនៅក្នុងអត្ថបទនុ៎ង លោកដែលបានចំណាំទៅលើខ្លឹមសារជាៗលក្ខណៈខុសប្លែកពីសំណេររបស់អ្នកដទៃដែរទេ?

[១៤:៣៧:១៤]

**ឆ៖** ក្នុងមេដឹកនាំ ក្នុងរណសិរ្ស ឃើញលោកប្លែកពីគេ បើដូចលោក ហ៊ូ នឹម, ទីវ អុល ទៅ

គាត់សរសេរម្យ៉ាងទៅ ហ៊ូ យន់ សរសេរម្យ៉ាងទៀតទៅ។ ប៉ុក ដឺសកុមារ សរសេរម្យ៉ាងរបស់គាត់ទៅ ដូច្នេះ បើគិតទៅបញ្ញវន្តច្រើនមានទឹកដៃខុសៗគ្នា។

**ស៖** បាទ សូមអរគុណ។ អត្ថបទដែលលោកឃើញនោះ គឺជាអត្ថបទសរសេរដៃ ឬមួយក៏ជាអត្ថបទបោះពុម្ព?

**ឆ៖** កាលខ្ញុំនៅជាមួយគាត់ ខ្ញុំឃើញគាត់សរសេរដៃ ដូច្នេះឃើញសំណេររបស់គាត់មានឃ្លាវែងខុសពីគេ ហើយមិនសូវខណ្ឌទេ។ អ៊ីចឹងបានខ្ញុំឃើញលក្ខណៈពិសេសនៅក្នុងអត្ថបទផ្សេងៗ ខ្ញុំតែងចាប់អារម្មណ៍អត្ថបទក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យក៏ដោយ សេចក្តីថ្លែងការណ៍ផ្សេងៗក៏ដោយ។ អ៊ីចឹងបានជាខ្ញុំសន្និដ្ឋានថា មិនមែនគំនិត ខៀវ សំផន សរសេរដោយខ្លួនឯងទេ។ ព្រោះឃ្លាគាត់វែង ហើយឃើញក្នុងអត្ថបទខ្លះទៅជាឃ្លាខ្លីៗ កំបុតៗ។ អ៊ីចឹងនេះជាការពិនិត្យរបស់ខ្ញុំទេ ព្រោះខ្ញុំធ្លាប់ឃើញស្នាដៃរបស់គាត់។

[១៤:៣៩:១៤]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមសួរលោកទាក់ទងទៅនឹងក្រោយឆ្នាំ១៩៧៥ វិញ ថាមុនឆ្នាំ១៩៧៩ ប៉ុន្តែក្នុងចន្លោះក្រោយពីកម្ពុជាប្រជាធិបតេយ្យទទួលបានជ័យជម្នះនោះបាទ។ លោកបានឆ្លើយក្នុងពេលកន្លងមកថា លោកធ្លាប់បានឃើញលោក ខៀវ សំផន អមដំណើរសម្តេច នរោត្តម សីហនុ នៅតាមជនបទ ហើយចំណុចនេះលោកចៅក្រម ឡាវែន៍ ក៏បានសួរបញ្ជាក់រួចហើយដែរ ខ្ញុំ -- ហើយលោកបានឆ្លើយថា លោកបានជួបនៅពេលនោះ ជួបលោក ខៀវ សំផន ហ្នឹងគឺដោយចៃដន្យទេ។ ខ្ញុំចង់សួរថាតើលោកចំណាំលោក ខៀវ សំផន បានដោយរបៀបណានៅពេលនោះ?

**ឆ៖** ខ្ញុំចំណាំថា ខ្ញុំធ្លាប់នៅជាមួយគាត់ ខ្ញុំអាចចំណាំបាន។ អ្នកណាជា ខៀវ សំផន, អ្នកណាជាសម្តេចឪ ហើយនរណាជាកូនសម្តេចឪ អាហ្នឹងខ្ញុំអាចដឹងខ្លះ។ ដូច្នេះនៅពេលនោះអត់មាន -- ហើយមើលក៏មិនច្បាស់ផង ព្រោះឡានៗ ភាគច្រើនឡានបិទកញ្ចក់។ ខ្ញុំមិនចាំថាឡានអង្គាល់ហ្នឹងប្រើឡានអីទេ ប៉ុន្តែទៅក្រៅមិនដឹងជាប្រើអាហ្ស៊ីប ឬប្រើអីទេ ប៉ុន្តែច្បាស់ជាមានឡាន ព្រោះតែមានស្តេចអ៊ីចឹងមានឡានស្អាតដែរសម្រាប់ជូនព្រះអង្គទៅ។ ហើយខ្ញុំមិនបានជួបគាត់ផ្ទាល់ទេ ខ្ញុំគ្រាន់តែ ដូចខ្ញុំបាននិយាយពីខាងដើម មិនមែនជួបមុខគ្នាបាននិយាយគ្នាទេ គ្រាន់តែឃើញដំណើរងាកទៅដឹងតែលោក ខៀវ សំផន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី អរគុណសាក្សី។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាស

សម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលមកវិញដើម្បីកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដែលបានកំណត់អម្បាញ់មិញនេះ គឺម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បាទ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ អង្គជំនុំជម្រះអនុញ្ញាតសុំឲ្យលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីចង់មានមតិយោបល់អ្វី សូមអញ្ជើញ!

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់ឲ្យព័ត៌មានថ្មីៗ ពាក់ព័ន្ធទៅនឹងអ្វីដែលខ្ញុំលើកឡើងមុននេះ។ ឯកសារដើមដែលថាយើងកំពុងតែរកនោះ រកឃើញមកហើយ ឯកសារនោះ ជាឯកសារសម្ងាត់។ ដូច្នេះហើយខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ថាយើងខ្ញុំនឹងផ្តល់ឯកសារដែលមានលក្ខណៈសម្ងាត់នេះ ជូនទៅដល់លោកសាក្សី គឹម វុន នូវចុងរសៀលនេះ។

[១៥:០៣:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយសូមរំឭកដែរ សូមក្រុមមេធាវីមានការចាប់អារម្មណ៍ផងដែរអំពីការបែងចែកពេលវេលាជាមួយនឹងក្រុមមេធាវីពីរក្រុមទៀត ក្នុងការតាំងសំណួរ។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំបាទ សូមបន្តសំណួរ។ លោក គឹម វុន ពេលសម្រាក ខ្ញុំបានសួរលោកទាក់ទងទៅនឹងលោក ខៀវ សំផន ជូនដំណើរលោកសម្ដេចឪទៅទស្សនកិច្ចនៅតាមជនបទ។ ខ្ញុំចង់សួរបញ្ជាក់លោកថា តើនៅពេលដែលលោកបានឃើញលោក ខៀវ សំផន នៅពេលនោះ គឺលោក ខៀវ សំផន កំពុងតែធ្វើដំណើរ ឬក៏ស្ថិតនៅក្នុងកម្មវិធីណាមួយដែលលោកត្រូវទៅ ដែលជាគោលដៅនោះ? ហើយសូមលោកជួយរៀបរាប់ពីស្ថានភាពជុំវិញពេលវេលាដែលលោកបានជួបនោះបាទ។

[១៥:០៤:៥៧]

**លោក គឹម វុន៖**

**ឆ៖** ការចងចាំរបស់ខ្ញុំនៅពេលនោះ ដូចខ្ញុំបានលើកពីខាងដើម គឺជារឿងចៃដន្យទេ។ តាមពិតខ្ញុំមិនដែលបានរស់នៅជាមួយគាត់ និងបានជួបគាត់ នៅក្នុងរយៈពេល៣ឆ្នាំ។ ហើយដែលខ្ញុំបានឃើញដោយចៃដន្យនោះគឺ បានឃើញរថយន្តដែលខ្ញុំសម្គាល់ថា ខ្ញុំស្គាល់ច្បាស់ថា លោក ខៀវ សំផន និងសម្ដេចឪ។ ហើយមិត្តភក្តិដែលរួមដំណើរជាមួយក៏សន្និដ្ឋានហ្នឹងដែរ ព្រោះអង្កាល់នោះ ពួកខ្ញុំច្រើនតែទៅជាក្រុមថតរូបនៅជិតៗភ្នំពេញ។ ដូច្នេះ ខ្ញុំមិនដឹងថា តើលោក ខៀវ សំផន មានកម្មវិធីអីយ៉ាងណា ប៉ុន្តែខាងខ្ញុំគឺទៅរកថតរូបទេ ទៅយកព័ត៌មាននៅជិតៗ ខ្វះរូបអីមួយសន្លឹកអី ជួនកាលចុះទៅស្រែ ឬក៏ចុះទៅកន្លែងការដ្ឋានសាងសង់ផ្សេងៗ ឬក៏ទៅធ្វើការងារ យើងសុទ្ធតែជាប់រវល់ខាងផ្នែកព័ត៌មាន។

ដូច្នេះមិនមានថាដឹងថា ប្រផ្នូល ឬលោក ខៀវ សំផន អីចេញទៅណា មានអ្នកណាខ្លះអី គឺយើងអត់បានដឹងទេ។ ហើយក៏មិនបានជួបមុខលោកផ្ទាល់ដែរ ប្រហែលជាលោកក៏មិនដឹងថា យើងហ្នឹងដឹងថា លោកធ្វើដំណើរទៅណាអីដែរ។

[១៥:០៦:៣៤]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់សំណួរខ្ញុំឡើងវិញថា នៅពេលដែលលោកឃើញនោះគឺជាក្បួនរថយន្តដែលកំពុងធ្វើដំណើរ ឬមួយក៏លោកឃើញនៅក្នុងពេលដែលរថយន្តឈប់?

**ផ៖** នៅពេលនោះគឺឡានកំពុងតែបើកបរ ធម្មតាតែមានដំណើរអ្នកធំទៅណាហើយ ច្រើនតែមានកងការពារអីៗដែរអមទៅដែរ។ ប៉ុន្តែតាមឮមិនភក្តិនិយាយមិនដឹងជាមែន ឬមិនមែនទេ ជួនកាលក៏មានអីអ្នកណាជូនទៅ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ទីតាំងដែលលោកបានឃើញនេះបានទេ បើសិនជាលោកអាចចាំ នៅម្តុំត្រង់ណាដែរ?

**ផ៖** ដំណើរ ខ្ញុំធម្មតានៅពេលនោះ នៅជាយក្រុងភ្នំពេញខ្ញុំមិនដឹងថា កន្លែងណាច្បាស់លាស់ទេ ព្រោះខ្ញុំមកដល់ពេលនេះ ខ្ញុំភ្លេចអស់ហើយ។ ប៉ុន្តែដឹងថា នៅក្រៅពីភ្នំពេញចេញមកជនបទ ប៉ុន្តែមិនដឹងថាជាទីតាំងជាក់លាក់នៅកន្លែងណា ព្រោះយូរឆ្នាំហើយ បើគិតទៅវាតាំងពីនុង់មកដូចជាប់២០ឆ្នាំជាង។ ដូច្នេះ ឲ្យចងចាំទាំងអស់ខ្ញុំភ្លេចដែរ។

**ស៖** បាទអរគុណ។ អ៊ីចឹងបានន័យថា លោកឃើញនៅជាយក្រុងភ្នំពេញបាទ។ អ៊ីចឹងទេ? សូមលោកឆ្លើយម្តងទៀត។

[១៥:០៨:៤១]

**ផ៖** បាទ នៅជាយក្រុងភ្នំពេញ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសម្តេចឪវិញ តើលោកដឹងថា ព្រះអង្គមានឋានៈជាអ្វីដែរទេនៅពេលនោះ?

**ផ៖** បើចូលភ្នំពេញដំបូង ខ្ញុំថាព្រះអង្គជាប្រធានគណៈប្រធានរដ្ឋ កម្ពុជាប្រជាធិបតេយ្យ។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងអំណាចរបស់ព្រះអង្គ តើពេលនោះព្រះអង្គមានអំណាចអ្វីខ្លះ តាមដែលលោកបានដឹងនោះ?

**ផ៖** ខ្ញុំមិនបានគិត ហើយក៏មិនបានវិភាគ ដោយខ្លួនឯងថាឲ្យច្បាស់ថា លោកមានអំណាច ឬអត់ ប៉ុន្តែខ្ញុំវាយតម្លៃថា មិនខុសអីពីលោក ខៀវ សំផន ដែរ។

**ស៖** មិនខុសក្នុងលក្ខខណ្ឌអី លោកអាចជម្រាបបន្ថែមជូនក្រុមប្រឹក្សាជំនុំជម្រះបន្តិចបាទ?

**ផ៖** ខ្ញុំចង់និយាយនេះ គឺចង់និយាយលើខ្លឹមសារអំណាច មានអំណាចឬអត់ គឺលោក ខៀវ

សំផន ដែរ។ ប៉ុន្តែចំពោះព្រះអង្គថាលោកមានអំណាច ក៏មិនដឹង។ ប៉ុន្តែតាមការវាយតម្លៃរបស់ខ្ញុំ គឺមិនខុសអីពីលោក ខៀវ សំផន ទេ។

[១៥:១០:៤២]

**ស៖** បាទ សូមអរគុណ។ ចុះម៉េចបានលោកដឹងថា ខៀវ សំផន ជំនួសតំណែងរបស់ព្រះអង្គ? លោកដឹងនៅពេលណាដែរ?

**ឆ៖** ខ្ញុំមែនទែន ខ្ញុំដឹងដោយចៃដន្យទេ។ មែនទែនខ្ញុំ កាលដែលខ្ញុំដឹង ខ្ញុំនៅធ្វើការនៅមន្ទីរ២៧។ ឃើញឯកសារបោះពុម្ពជាភាសាបរទេស។ ដល់អ៊ីចឹងទៅ បើឲ្យគេប្រាប់ថា អូ៎!ម្ដេចឪអី ឈប់អីៗ ក៏អត់មានអ្នកណាប្រាប់ដែរ។ ប៉ុន្តែខ្ញុំឃើញ ឃើញដោយចៃដន្យដូចត្រាក់បោះនៅ២៥ អ៊ីចឹង ខ្ញុំដឹងដោយចៃដន្យ។ យ៉ាងណាមិញ ឯកសារជាភាសាបរទេសដែលខ្ញុំឃើញបោះពុម្ពនៅ២៧ហ្នឹង សុទ្ធតែមិនមែនអ្នកណាគេប្រាប់ថា នេះឯកសារនេះ សម្ដេចឪ លោកឈប់ហើយនេះ ឬក៏មានគេឃោសនាប្រាប់អីអត់ទេ។ ខ្ញុំដឹងដោយខ្ញុំធ្វើការនៅជាប់នឹងរោងពុម្ពហ្នឹងម្ដង។ ដូច្នេះ ដឹងហ្នឹង បានន័យថាដឹងដោយខ្លួនឯងទេ។ ហើយវាយតម្លៃនៅពេលនោះថា ព្រះអង្គនឹងឈប់មែន ហើយអាចលោក ខៀវ សំផន ហ្នឹងឡើងជំនួស។

[១៥:១២:១៤]

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងការឡើងជំនួសរបស់លោក ខៀវ សំផន នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោក ខៀវ សំផន គាត់ធ្លាប់ -- តាមដែលលោកដឹង មានធ្លាប់តែងតាំងបុគ្គលិកណា ឬក៏បុគ្គលណា កម្មាភិបាលណាដែរឬទេក្នុងសម័យនោះ?

**ឆ៖** ព័ត៌មានផ្សេងៗពីលោក ខៀវ សំផន ខ្ញុំអត់បានទទួល។ អត់បានទទួលដំណឹងអីទាំងអស់។ រឿងដែលខ្ញុំជួប សុទ្ធតែរឿងចៃដន្យដែលខ្ញុំជួបនៅក្នុងការងាររបស់ខ្ញុំ។ ព្រោះមិនដឹងថា លោក ខៀវ សំផន នៅកន្លែងណា។

**ស៖** បាទ សូមអរគុណ។ ចុះលោកដែលបានដឹងថា លោក ខៀវ សំផន បានចេញបញ្ជាឲ្យកម្មាភិបាល ឬក៏មន្ត្រីនៅក្នុងសម័យនោះធ្វើអ្វី? ឬក៏មិនឲ្យធ្វើអ្វីដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងការពិត ហើយក៏មិនដឹងការជាក់លាក់យ៉ាងម៉េចដែរ។ ប៉ុន្តែខ្ញុំប៉ាន់ស្មានលើអត្តចរិតរបស់ ខៀវ សំផន។ ជារួមកាលដែលខ្ញុំធ្លាប់នៅជាមួយគាត់ គាត់មិនដែលបញ្ជាអ្វីដែល ជ្រុងណាដែលអសីលធម៌ ឬក៏ការចាត់តាំងណាដែលនាំឲ្យមានការប៉ះពាល់ដល់កម្លាំងទេ។ គាត់គិតគូរវែងឆ្ងាយណាស់។

ប៉ុន្តែមិនដឹងថា សម័យនោះគាត់គិតយ៉ាងម៉េចទេ ខ្ញុំមិនដឹងទេ? ប៉ុន្តែជាការសន្និដ្ឋានរបស់ខ្ញុំទេមិនមែនជាការពិតទេ។ ខ្ញុំជឿថា លោក ខៀវ សំផន មិនអាចធ្វើអំពើអាក្រក់ណាមួយ។

[១៥:១៤:២៨]

**សៈ** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងការដកតំណែង ឬក៏ការដាក់វិន័យដល់កម្មាភិបាល ឬក៏បុគ្គលណាម្នាក់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ តើលោកដែលបានដឹង បានឮទាក់ទងទៅនឹងសេចក្ដីសម្រេចណាមួយរបស់លោក ខៀវ សំផន ដែរទេ?

**ផះ** អាចមានខ្លះ ដែលនិយាយដោយផ្ទាល់មាត់ពីបុគ្គលម្នាក់ ប៉ុន្តែឥឡូវគាត់ស្លាប់ហើយ បង ធុច រិន។ គាត់ជារដ្ឋលេខាធិការក្រសួងព័ត៌មានកម្ពុជាប្រជាធិបតេយ្យ។ គាត់និយាយរំឭករឿងជំនាន់ ៣ឆ្នាំដោយជួបប្រទះ និងរឿងដែលពាក់ព័ន្ធនឹងរឿងចោទប្រកាន់គាត់។ គាត់បាននិយាយច្បាស់ថា នៅពេលនោះ ដោយចៃដន្យលោក ខៀវ សំផន បានដឹង ហើយក៏ដូចជាខិតខំប្រឹងប្រែងជួយគាត់ដែរ។ អង្កាល់នោះគាត់នៅកំពង់សោម។ ហ្នឹងជារឿងនិទានរបស់គាត់ទេ និយាយប្រវត្តិគាត់ប្រាប់ខ្ញុំ។

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ឡើងវិញអម្បាញ់មិញ លោកមានប្រសាសន៍ថា “លោក ឈូក រិន បាននិទានរឿងប្រាប់លោកអំពីដំណើរជីវិតរបស់គាត់”។ លោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ ព្រោះអានេះវាទាក់ទងទៅនឹងសំណួររបស់ខ្ញុំមុនអំមិញ យ៉ាងម៉េចដែរទាក់ទងនឹងថាលោក ខៀវ សំផន មានអំណាចដាក់វិន័យ ឬក៏ដកតំណែងមន្ត្រីណាម្នាក់នៅក្នុងសម័យដែលលោកធ្វើជាគណៈប្រធានរដ្ឋនោះ?

[១៥:១៦:៣៨]

**ផះ** ឧទាហរណ៍មួយទេ។ អ៊ីចឹងបានថាមានអំណាច ឬអត់អំណាចហ្នឹង ខ្ញុំបានវាយតម្លៃថា អត់រួចទៅហើយ។ ប៉ុន្តែរឿងមិត្តភក្តិគាត់ ដូចបង ធុច រិន មិនមែន ឈូក រិន ទេ។ ធុច រិន ហ្នឹងគាត់ជាបញ្ញវន្តមួយដែល គាត់មានមុខតំណែងនៅក្នុងពេល១ជំនាន់៣ឆ្នាំ គាត់ដូចនៅធ្វើការនៅកំពង់សោម។ ដូច្នេះក៏មានការចោទប្រកាន់ ប៉ុន្តែនៅពេលនោះថា ដូចជាចៃដន្យអីមិនដឹង ក៏ដឹងបញ្ហាហ្នឹង ក៏ឃើញថា គាត់ថាមានលោក ខៀវ សំផន ជួយគាត់។ អ៊ីចឹងរឿងមានអំណាច មានឥទ្ធិពលយ៉ាងម៉េច ខ្ញុំគ្រាន់តែឆ្លុះបញ្ចាំងប៉ុណ្ណឹងទេ។ ឃើញថា ខៀវ សំផន មិនមែនមិនជួយអ្នកដទៃទេ។ បើមានកំហុសអាចជួយបាន និងអាចមិនជួយបានទេ ព្រោះអំណាចគាត់ -- ព្រោះខ្ញុំបានវាយតម្លៃថាអត់មានអំណាចហើយ។ ដូច្នេះ បើយើងថាមានអំណាចដោះលែងអ្នកផ្សេង វាដូចជាផ្ទុយគ្នា។ ប៉ុន្តែអានេះជារឿងដែលគាត់បាននិយាយផ្ទាល់មាត់ប្រាប់ខ្ញុំ។ និយាយទៅធ្លាក់រឿង៣ឆ្នាំហ្នឹង។

[១៥:១៨:០០]

**ស៖** បាទ សូមអរគុណចំពោះការកែតម្រូវ។ ខ្ញុំចង់សួរបញ្ជាក់ថា នៅពេលដែលលោក ធុច រិន បានជម្រាបប្រាប់លោកពីថាលោក ខៀវ សំផន ជួយហ្នឹង តើលោក ធុច រិន បានបញ្ជាក់ថាជួយទាក់ទងនឹងរឿងអ្វីដែរទេ?

**ធ៖** តាមមើលទៅ អ្នកនៅកំពង់សោមក៏មានបញ្ហា គេចោទប្រកាន់ដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមត្រឡប់ទៅសួរលោកទាក់ទងទៅនឹងចំណុចដែលថាលោកជាអ្នកកាសែត ហើយលោកចេញធ្វើការថតរូប ឬក៏យកព័ត៌មាននៅតាមជនបទ ហើយបានប្រទះឃើញថាមានខ្មែរស ឬក៏ពួកអ្នកប្រឆាំងដែលបង្កឲ្យបញ្ហានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ ហើយដែលលោកបានលើកឧទាហរណ៍ជាក់ស្តែងមួយចំនួនជាពិសេសទាក់ទងទៅនឹងតំបន់មូលដ្ឋានចាស់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលលោកបានបង្ហាញថានៅទីនោះត្រូវបានលោក កែ ពក មិនអនុញ្ញាតលោកធ្វើការយកព័ត៌មានទេ ដោយថាមានខ្មែរសអីនៅកន្លែងនោះ ដែលអាចទៅគ្រោះថ្នាក់បាទ។ ហើយនៅពេលដែលលោកកំពុងតែឆ្លើយនូវចំណុចនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានកាត់លោកមិនឲ្យលោកធ្វើការឆ្លើយបន្ថែមទៅលើអ្វីដែលលោកចង់និយាយទេ។ នៅពេលនេះ ខ្ញុំសូមផ្តល់ឱកាសឲ្យលោក សូមលោកបង្ហាញជូនក្រុមប្រឹក្សាជំនុំជម្រះថា តើមានបញ្ហាអ្វីខ្លះដែលលោកបានជួប ដែលជាបញ្ហាចលាចល ឬក៏បញ្ហាដែលមានក្រុមបះបោរដូចជា ក្រុមខ្មែរស ដែលលោកបានលើកឡើងនេះ? សូមលោកអញ្ជើញមានប្រសាសន៍។

[១៥:២០:២៩]

**ធ៖** ខ្ញុំចែកជាពីរ។ ហើយជំនាន់សង្គ្រាម៥ឆ្នាំ ខ្ញុំនៅប-២០ គឺសំឡេងកាំភ្លើងហ្នឹងគឺវាឮនឹងត្រចៀកតែម្តង ហើយដឹងថាកន្លែងណា កើតនៅតាប្រាប់ ឬកើតនៅកន្លែងណា គឺវាមានអីចឹងតែម្តង។ មានស្នូរកាំភ្លើងបាញ់អីចឹងតែម្តង។ ហើយជំនាន់៣ឆ្នាំនេះ ខ្ញុំទទួលព័ត៌មានប្រយោលមិនបានឮផ្ទាល់ទេ។ ប៉ុន្តែគ្រាន់ខាងមូលដ្ឋានគេហាមឃាត់មិនឲ្យយើងទៅកន្លែងមូលដ្ឋានចាស់ទេ ព្រោះមូលដ្ឋានចាស់បើគិតទៅវានៅផ្នែកឃុំបឹងល្វា ស្ទឹងជីនិត ហើយនិងឆ្លងស្ទឹងជីនិតតាម គគីរទៅលើទឹកដីខេត្តកំពង់ចាមវិញ។ ហើយជំនាន់នោះ ខ្ញុំចង់ដឹងថា មូលដ្ឋានប្រជាជននៅកន្លែងនោះ តើគាត់នៅមកកន្លែងហ្នឹងដដែល ឬក៏យ៉ាងម៉េចព្រោះមានអ្នកស្គាល់ច្រើន ព្រោះនៅជិតមន្ទីរដូចនៅបឹងល្វា ដូចត្រពាំងទឹម សំរោងខាងកំពង់ចាមអីហ្នឹង តាប្រាប់អីហ្នឹង សុទ្ធតែកន្លែងខ្ញុំធ្លាប់រស់នៅដែរ។ ដល់អីចឹងអីចឹងចង់ដឹង។ ដល់អីចឹង

បានសុំអនុញ្ញាតទៅខាងភូមិភាគ គណៈភូមិភាគឧត្តរហ្នឹង តើគាត់អាចអនុញ្ញាតឲ្យខ្ញុំទៅបានដែរអត់? អ៊ីចឹងគាត់ហាមថា ទៅមិនបានទេ ព្រោះមានខ្មែរស។ អ៊ីចឹងបានខ្ញុំជាប់បញ្ហានេះជាពីរកង់។ កងទី១ សង្គ្រាម៥ឆ្នាំ។ កងទី២ គឺរយៈពេល ៣ឆ្នាំហ្នឹងឯង។

[១៥:២២:១១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក គីម វុន។ ខ្ញុំអត់មានសំណួរអីបន្ថែមទៅលោកទៀតទេ ហើយខ្ញុំបាទសូមអនុញ្ញាតឲ្យសហភាតារបស់ខ្ញុំមានសំណួរបន្តិចបន្តួចបន្ថែមទៀតបាទ។ សូមអរគុណ លោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក គីម វុន។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ខ្ញុំសូមសួរសំណួរបំភ្លឺមួយចំនួនបន្ទាប់ពីសហភាតាខ្ញុំនេះ។ ខ្ញុំសូមរំឭកថា ជាការសំខាន់ណាស់ដែលលោកឆ្លើយបន្ទាប់ពីមានពន្លឺក្រហមនៅមុខលោកនេះហើយសិនចាំឆ្លើយ។ សំណួរទី១របស់ខ្ញុំ នៅពេលដែលអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតបានសួរសំណួរលោកនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩។ ឯកសារ 303/380 លេខ ERN 00 --, ERN ជាភាសាខ្មែរ 00357196 ERN ជាភាសាអង់គ្លេស 00365641។ សំណួរទៅមួយអ្នកស៊ើបអង្កេតសួរលោកនៅក្នុងឯកសារនេះ គឺចង់ដឹងថា "តើលោកចូលក្នុងបដិវត្តនៅក្នុងពេលណា?" លោកបានឆ្លើយថា "ឪពុករបស់លោកជាអ្នកខាងខ្មែរឥស្សរៈ ខាងសម្តេច សីហនុ"។ សំណួរខ្ញុំចង់ដឹងថា តើការដែលឪពុករបស់លោកជាមន្ត្រីផ្នែកខាងឥស្សរៈខាង សីហនុ នេះជាកត្តាដែលជំរុញឲ្យលោកចូលក្នុងរណសិរ្សដែរឬទេ?

[១៥:២៤:៥៤]

**លោក គីម វុន៖**

**ឆ៖** និយាយជាកត្តានាំឲ្យចូលមានច្រើនដែរ ព្រោះកាលៈទេសៈនៅពេលនោះគឺស្រុកខ្មែរយើង

ពិបាក។ ប្រជាជនៗខ្មែរពិបាកមែនទែន ងាកមើលទៅលើមេឃសុទ្ធតែយន្តហោះ ងាកមកថ្មើរជើងវិញ មានទាំងទ័ពអ្នកតស៊ូ មានទាំងទ័ព លន់ នល់។ ហើយបើនិយាយមែនទែន យន្តហោះហ្នឹងមកគ្រប់ធន់អស់ហើយ ពួកអាធីវគី ក៏មាន អាមេរិកាំងក៏មាន ហើយម៉ែ្វៗស្រុកភូមិ បើនិយាយជាធំខ្ញុំគឺអស់ទាំងពូជតែម្តង មួយត្រង់សេ។ ដូច្នេះកត្តាវាច្រើន កត្តាសម្ពាធក្នុងសង្គម ក្នុងសង្គ្រាមហ្នឹងវាច្រើនដែរ។ ហើយម៉្យាងទំនោររបស់ខ្ញុំគឺសម្តេចឪ បើនរណាគាំទ្រសម្តេចឪ គឺក្រុមគ្រួសារខ្ញុំក៏ដូចជាអ្នកភូមិគេមិនចង់បានសង្គ្រាម ហើយក៏មិនចង់ឲ្យអ្នកណាធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គដែរ។ ដល់អ៊ីចឹងមានតែសេចក្តីថ្លែងការណ៍ខ្ញុំមិនចាំ ប៉ុន្តែពីដើមវិទ្យុផ្សាយសំឡេងរបស់យើងមានតិចណាស់ ហើយជានិន្នាការរបស់យើងក្រោយរដ្ឋប្រហារមក យើងស្តាប់តែវិទ្យុប៉េកាំងនិងវិទ្យុហាណូយ ហើយអាចស្តាប់វិទ្យុអាមេរិកខ្លះ ប៉ុន្តែជាមូលដ្ឋានវិទ្យុពីរនេះដែលយើងត្រូវស្តាប់។ ហើយខ្ញុំសម័យហ្នឹង ខ្ញុំចេះស្តាប់ ហើយខ្ញុំចេះស្រឡាញ់សម្តេចឪដែរ។ ដល់អ៊ីចឹងឃើញថាមានការអំពាវនាវចូលព្រៃម៉ាគីអីហ្នឹង ក្រោយបាតុកម្ម តាមព្រឹត្តិមានអីគេធ្វើបាបបាតុកម្ម អ្នកបាតុកម្មអីនៅ -- គេចេះផ្សាយព័ត៌មាន ព្រោះវាមានព័ត៌មានដែរ។ ដូចនៅស្គាយជ្រោយចង្វាបាញ់ស្លាប់មនុស្សមិនតិច នៅខាងកំពង់ធំ នៅខាងតាកែវ កំពត។ ដូច្នេះបាតុកម្មហ្នឹងវាធំណាស់។ ដល់អ៊ីចឹងឃើញមនុស្សមួយចំនួនដែលក្រោយបាតុកម្មឃើញរត់មក។ ហើយអ្នកខ្លះមិនទាន់ចូលជាមួយខ្មែរទេ ព្រោះយួនមកមុន។ ដូច្នេះ ចូលជាមួយយួន យួនមកពីហាណូយ។ ដើម្បីរួចពីបាតុកម្ម។

[១៥:២៧:២៥]

ដូច្នេះ ខ្ញុំលើកកត្តាជាច្រើននេះ ដើម្បីឆ្លុះបញ្ចាំងមើលឃើញថា តើនិន្នាការខ្ញុំនៅពេលនោះយ៉ាងណា គឺខ្ញុំនិយាយខាងដើមគឺទំនោរប្រជាជនទូទៅគឺនៅតែគាំទ្រ នៅតែស្រឡាញ់សម្តេចឪ។ ដល់អ៊ីចឹងដល់មានការអំពាវនាវអ៊ីចឹងបងៗចេះតែបំផុសនាំគ្នាអ៊ីចឹង។ ដណ្តើមអំណាចឲ្យសម្តេចឪវិញ។ ដល់បងៗមកពីភាគខាងជើងក៏អ៊ីចឹងដែរ ក៏និយាយរឿងហ្នឹងហើយគេតែងតែភ្ជាប់លោក ខៀវ សំផន ទៅហ្នឹងតែម្តង។ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់។ ហ្នឹងខាងខ្មែរយើងមកពីភាគខាងជើង។ ប៉ុន្តែខ្ញុំជាក្មេងកំព្រាខ្ញុំមិនងាយនឹងចេញចោលម្តាយទេ។

**ស៖** ខ្ញុំសោកស្តាយដែលរំឭកអនុស្សាវរីយ៍ឈឺចាប់ដល់លោក ប៉ុន្តែនេះក្នុងគោលបំណងបំភ្លឺតុលាការ។ អ៊ីចឹងសូមលោកជម្រាបមកខ្ញុំវិញថា នៅពេលណាដែលលោកអាចនឹងឆ្លើយសំណួរបន្តទៀតបាន? អ៊ីចឹងលោកតាមដំណើរចុះ។ លោកសាក្សី តើលោកអាចបន្តឆ្លើយបានហើយឬនៅ?

[១៥:២៩:៣៧]

**ប្រធានអង្គជំនុំ៖**

លោក គឹម វុន អាចបន្តស្តាប់សំណួរ អាចឆ្លើយបានទេតទៅនេះ?

**លោក គឹម វុន៖**

បាទ បងខ្ញុំបន្ត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញលោកមេធាវី -- លោកស្រីមេធាវី!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** បាទ សូមអរគុណលោកសាក្សី។ អម្បាញ់មិញ នៅពេលដែលលោកឆ្លើយទៅសហភាតារបស់ខ្ញុំ លោកបានប្រាប់ថា ក្នុងពេលរយៈដែលលោកបានជួបលោក ខៀវ សំផន នៅក្នុងព្រៃម៉ាគី គឺនៅក្នុងឆ្នាំ១៩៧១ ហើយលោកបានបញ្ជាក់ នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួរសហព្រះរាជអាជ្ញា លោកបានបញ្ជាក់ថា នៅសម័យនុ៎ង លោកបានឃើញលោក ខៀវ សំផន យកចំណីអាហារទៅរោងពុម្ព ដែលលោកធ្វើការ។ សំណួររបស់ខ្ញុំទី១ គឺថាតើលោកដឹងថា លោក ខៀវ សំផន មានមុខងារអ្វីដែរឬទេនៅក្នុងរណសិរ្ស? លោកសាក្សីមិនអី ឬក៏យ៉ាងម៉េច?

[១៥:៣១:១៨]

**លោក គឹម វុន៖**

**ឆ៖** បាទ ខ្ញុំអាចបន្តបាន។

**ស៖** តើលោកចង់ឲ្យខ្ញុំចោទសំណួរនេះឡើងវិញ ឬក៏លោកចាំសំណួរនេះហើយ? ឥឡូវ ខ្ញុំចោទសំណួរឡើងវិញ។ ខ្ញុំអម្បាញ់មិញនេះ ខ្ញុំសួរលោកថានៅឆ្នាំ១៩៧១ នៅពេលដែលលោកបានឃើញលោក ខៀវ សំផន នៅក្នុងព្រៃម៉ាគី។ ខ្ញុំសួរលោកថា តើលោកដឹងថា លោក ខៀវ សំផន នេះមានតួនាទី មុខងារអ្វីដែរនៅក្នុងរណសិរ្ស?

**ឆ៖** កាលហ្នឹង ខ្ញុំយល់ថា លោកអាចបន្ទាប់ពីសម្តេចព្រះ នរោត្តម សីហនុ មក អាចលោកមានតួនាទីក្នុងការដឹកនាំប្រជាជនក្នុងការតស៊ូ។ នេះការយល់របស់ខ្ញុំក្នុងសម័យនោះ។

**ស៖** តើលោកនៅពេលដែលលោកនៅក្នុងព្រៃម៉ាគី តើលោកធ្លាប់ឃើញអ្នកដឹកនាំខ្ពស់នៅក្នុងរណសិរ្សយកចំណីអាហារទៅកន្លែងលោកធ្វើការដែរឬទេ?

[១៥:៣៣:០៩]

**ឆ៖** ដូចចម្លើយខ្ញុំពីចម្លើយអស់លោកមួយចំនួនបានសួរ គឺមាន។ ហើយបើមិនផ្ទាល់ទេ ក៏មាននីរសារយកម្ហូបអាហារបន្លែផ្សេងៗទៅឲ្យកន្លែងមន្ទីរខ្ញុំ។

**ស៖** ប្រហែលមានបញ្ហាបកប្រែហើយ។ ឥឡូវខ្ញុំចោទសំណួរឡើងវិញ។ លោកឆ្លើយថា មាននីរសារបានយកចំណីអាហារនិងស្បៀងទៅកន្លែងលោក ហើយលោក ពេលដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញា លោកឆ្លើយថា លោក ខៀវ សំផន បានយកចំណីអាហារមកឲ្យលោកនៅរោងពុម្ព ដែលកន្លែងដែលលោកធ្វើការនោះ។ លោក ខៀវ សំផន គាត់មិនមែនជានីរសារនោះទេ អ៊ីចឹង តើលោកអាចជម្រាបបានទេ ថាតើក្រៅពីនីរសារនោះ មានគេអ្នកផ្សេងនោះមកយកចំណីអាហារមកកន្លែងរោងពុម្ពហ្នឹង ញឹកញាប់ដែរឬទេ?

[១៥:៣៤:៣៣]

**ឆ៖** ដូចខ្ញុំឆ្លើយពីលើកមុន គឺថ្នាក់ដឹកនាំតែងតែលើកទឹកចិត្ត និងយកជាចំណីអាហារ ឬក៏របស់អី ដែលគាត់អាចធ្វើបាន។ មានជាម្ហូប មានជាចំណីអាហារ មានជាបង្អែមអីខ្លះ បង្អែមក្នុងនោះ គ្មានអ្វីក្រៅពីផ្លែចេក ឬក៏ផ្លែឈើនៅ ប-២០ ឬអីហ្នឹងទេ។ ជួនកាលគាត់មានទៅជាមួយអ៊ីចឹង គាត់មានកាន់យកទៅ។ ប៉ុន្តែជារួមគឺមាននីរសារ ដូច្នេះវាមានពីរ។ ទី១ លោក ខៀវ សំផន ក៏លោកអាចទៅបានដែរ ប៉ុន្តែទៅហ្នឹងមិនមែនទៅតែឯងទេក្នុងសម័យសង្គ្រាម គឺមាននីរសាររបស់គាត់តាម។ មាន សំ ដើរតាមគាត់តាមគាត់អ៊ីចឹងទៅ។ ហើយយើងមិនដែលហៅគ្នាថា -- មែនទែនទៅ ដូចហៅគ្នាជាបងជាប្អូន យុទ្ធជន យុទ្ធនារី ហៅកម្មាភិបាលថា បងអ៊ីចឹងទៅ។ ដូច្នេះ គាត់មានយកទៅ ហើយក្រៅពីនោះក៏មាននីរសារយកទៅឲ្យដែរ។

[១៥:៣៦:០៥]

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ ដោយហេតុថា យើងកំពុងតែនិយាយអំពីនីរសារ ហើយអម្បាញ់មិញនេះ លោកបានឆ្លើយជូនតុលាការថា “ជាទូទៅ គឺថាតាមរយៈនីរសារ ដែលលោកទទួលសេចក្ដីថ្លែងការណ៍ ឬក៏អត្ថបទរបស់ថ្នាក់ដឹកនាំមកបោះពុម្ព យកមកបោះពុម្ព”។ តើលោកមានចាំឈ្មោះនីរសារណាខ្លះដែរឬទេ? នីរសារដែលយកអត្ថបទមកឲ្យលោកបោះពុម្ព?

**ឆ៖** មានច្រើនដែរ ជាបងប្អូនជនជាតិ។ ជួនកាលមាន សំ, មាន ស៊ិន, មាន ទឿង, មាន ផាត មានអ្នកណាខ្លះទេ ព្រោះជនជាតិជានីរសារនេះ មានច្រើន ខ្ញុំរាប់មិនអស់។

**ស៖** តើលោកដឹងថា មាននីរសារ ដែលគេប្រើសម្រាប់តែនាំអត្ថបទ ឬក៏សេចក្ដីថ្លែងការណ៍ហ្នឹងមករោងពុម្ពលោកដែរទេ?

**ឆ៖** នីរសារមុខគេ មែនទែនជាអ្នកនាំសារ ជួនកាលគេនាំសំបុត្រមកឲ្យមេខ្ញុំ។ ជួនកាលគេយកអត្ថបទផ្សេងៗយកមកឲ្យ ហើយជួនកាលក៏គេមិនមកដែទទេដែរ គេមានអីធ្វើយើង ជារបស់ហូប ព្រោះកន្លែងខ្ញុំមិនអាចចេញចូលទៅណាបានឆ្ងាយទេ វាជាប់រវល់ធ្វើការងារច្រើន។ ដល់អ៊ីចឹងមានតែការផ្គត់ផ្គង់។

[១៥:៣៨:៣២]

**ស៖** អម្បាញ់មិញនេះ នៅពេលដែលលោកឆ្លើយតបទៅនឹងសហភាតារបស់ខ្ញុំ លោកបានឆ្លើយថា លោកអាចស្គាល់សំណេររបស់លោក ខៀវ សំផន របៀបសរសេររបស់លោក ខៀវ សំផន ហើយលោកបានបញ្ជាក់ត្រង់ចំណុចនេះ។ ខ្ញុំចង់ដឹង ទាក់ទងនឹងចំណុចមួយទៀត ដែលលោកបានលើកឡើងជាមួយនឹងសហព្រះរាជអាជ្ញា គឺទាក់ទងនឹងសេចក្ដីប្រកាសដែលលោកបានទទួល នៅក្នុងក្របខ័ណ្ឌនៃការងាររបស់លោក។ ខ្ញុំសូមការបំភ្លឺលើចំណុចនេះ។ លោកបាននិយាយប្រាប់សហព្រះរាជអាជ្ញាថាឥឡូវខ្ញុំនិយាយពីក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកបានប្រាប់សហព្រះរាជអាជ្ញាថា លោកធ្វើការទាក់ទងទៅនឹងទស្សនាវដ្ដីទង់បដិវត្ត ហើយនៅពេលដែលលោកឆ្លើយទៅនឹងសំណួរសហព្រះរាជអាជ្ញានេះលោកបានពន្យល់ថា លោកអាចស្គាល់ចំណាររបស់ ប៉ុល ពត លើឯកសារដែលគេត្រូវប្រើ ដើម្បីបោះពុម្ពផ្សាយក្នុងទង់បដិវត្តនេះ។ សំណួរខ្ញុំដូចតទៅនេះ ខ្ញុំចង់ដឹងថាតើលោកអាចស្គាល់ចំណាររបស់ ប៉ុល ពត នេះតាមរបៀបណា? តើលោកស្គាល់អក្សរ ប៉ុល ពត ឬក៏យ៉ាងម៉េច?

[១៥:៤០:១០]

**ឆ៖** បាទ ស្គាល់ច្បាស់។

**ស៖** នៅពេលដែលលោកនិយាយថា លោកស្គាល់អក្សរនោះ អ៊ីចឹងបានន័យថា លោកធ្លាប់ឃើញច្បាប់ដើម យ៉ាងហោចណាស់ក៏មួយដងដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើនៅក្នុងកាលៈទេសៈណាដែលលោកស្គាល់អក្សរ ប៉ុល ពត នេះ?

**ឆ៖** ដូចខ្ញុំបញ្ជាក់អំពីការងាររបស់ខ្ញុំហើយ។ នៅរោងពុម្ពគឺវាមានបីផ្នែកសំខាន់។ ទី១ ខ្ញុំធ្វើការខាងទស្សនាវដ្ដីរណសិរ្ស។ ប៉ុន្តែនៅក្នុងរោងពុម្ពតែមួយហ្នឹង គឺបោះពុម្ពបោះពុម្ពរួមគ្នា គេមិនឲ្យដាច់ពីគ្នាទេ។ ទង់បដិវត្តនិងរណសិរ្ស គឺនៅជាមួយតែគ្នាទេ ប៉ុន្តែគ្រាន់តែអ្នកសរសេរហ្នឹងមានខ្ញុំខាងរណសិរ្ស។

ហើយដូច ជុំ ទទួលខាងទង់បដិវត្ត អ៊ីចឹងចុះ។ ហើយជាធម្មតានៅលើអត្ថបទនីមួយៗ វាមានលេខកូដរបស់វាដែរ។ បើឲ្យផ្សាយវិទ្យុ គឺវាមានលេខកូដចំណាំថា អាហ្នឹងជាថ្លែងការណ៍ ជាវិចារណកថា ជាដំណឹង ជាអត្ថាធិប្បាយអី គឺវាមានលេខកូដរបស់វា។ ហើយបើថ្នាក់ដឹកនាំ គាត់អត់មានលេខកូដអីគាត់ទេ។ ឧបមាថា ឯកសារត្រូវបោះពុម្ពផ្សាយ គាត់ថាគ្រាន់តែចារពីរបីម៉ាត់ថា បញ្ជាមករោងពុម្ពថាឲ្យបោះពុម្ពប្រញាប់អីហ្នឹង គឺមានចំណាររបស់គាត់ម្តង។ ហើយចំណារនេះ យើងអាចស្គាល់ ព្រោះមកញឹកញាប់ យើងតែងតែស្គួរគ្នា។ ដូច្នេះអាចស្គាល់ សម្គាល់ថា អក្សរហ្នឹងជាអក្សរ អ៊ំប៉ុល ឬអក្សរអ្នកណា។ បាទ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

[១៥:៤២:២០]

**ស៖** សូមអរគុណដែលឆ្លើយបំភ្លឺ។ ប្រធានមួយទៀត ដែលខ្ញុំចង់ចោទសួរលោក គឺថាទាក់ទងទៅនឹងការផ្លាស់ទីរបស់លោក គឺការធ្វើដំណើររបស់លោក។ លោកបាននិយាយពីការធ្វើដំណើររបស់លោកនេះជាមួយអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត។ ខ្ញុំសូមយោងទៅឯកសារ E3/380 ដដែល។ ប៉ុន្តែម្តងនេះ ថាជាភាសា -- ទំព័រជាភាសាបារាំង គឺទំព័រចុងក្រោយ។ ជាភាសាផ្សេងទៀតនោះ ប្រហែលជាទំព័រដូចគ្នាដែរ។ លេខ ERN ជាភាសាបារាំងគឺ 00485434, ហើយនិងជាភាសាខ្មែរគឺ 003571002 (ស៊ីក), ហើយទំព័រអង់គ្លេស 00365647។

ខ្ញុំសូមការបំភ្លឺមួយចំនួន ពីព្រោះថានៅពេលដែលលោកឆ្លើយទៅនឹងសហភាតារបស់ខ្ញុំអម្បាញ់មិញនេះ ហើយនិងលោកបានឆ្លើយទៅសហព្រះរាជអាជ្ញាផងដែរមុនហ្នឹងបន្តិច។ លោកបានឆ្លើយថា "លោកបានឃើញលោក ខៀវ សំផន តែម្តងទេ។ លោកឃើញគាត់ជាមួយនឹងសម្តេច សីហនុ"។ លោកបាននិយាយថា លោកបានឃើញគាត់តែម្តងទេ ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់លោកដែលខ្ញុំសូមដកស្រង់ដូចតទៅនេះ យ៉ាងហោចណាស់ក៏ថាជាអ្វីដែលមានកត់ត្រានៅក្នុងចម្លើយរបស់លោក ដែលលោកផ្តល់ទៅខាងអ្នកស៊ើបអង្កេត។ គឺថានៅខាងកថាខណ្ឌចុងក្រោយ៖ "ខ្ញុំបានឃើញ ខៀវ សំផន នៅពេលដែលគាត់អមសម្តេច សីហនុ នៅក្នុងការលំហែកាយនៅខេត្តកណ្តាល តាកែវ កំពង់ចាម នៅជុំវិញភ្នំពេញ"។ សំណួរខ្ញុំ គឺចង់ដឹងថា តើលោកបាន -- ពិតជាបាននិយាយយ៉ាងដូច្នេះមែនទៅអ្នកស៊ើបអង្កេត ឬយ៉ាងណា? ហើយបើសិនជាយ៉ាងដូច្នេះមែន សូមបំភ្លឺជូនតុលាការ ពីព្រោះអម្បាញ់មិញនេះលោកបាននិយាយថា លោកបានជួបលោក ខៀវ សំផន ជាមួយសម្តេច សីហនុ នោះតែមួយដងទេ?

[១៥:៤៥:២៧]

**ឆៈ** ខ្ញុំបំភ្លឺឡើងវិញ ច្រើនដងនេះ វាមានច្រើនដងដែរមែនទែន ប៉ុន្តែខ្ញុំឃើញច្បាស់តែម្តងទេ។ ប៉ុន្តែតាមមិត្តភក្តិដែលធ្វើការជាមួយគ្នាកន្លងមក គាត់តែងតែប្រាប់ ប៉ុន្តែខ្ញុំៗវាមិនច្បាស់ ប៉ុន្តែខ្ញុំច្បាស់មានតែម្តងហ្នឹងទេ។ ដូច្នេះ ច្រើនដង និងម្តងវាអ៊ីចឹង។ តាមពាក្យដែលគេប្រាប់ ព្រោះយើងមិនចាប់អារម្មណ៍ថ្នាក់ដឹកនាំចេញទៅណាទេ ជាមួយសម្តេចនោះ។ ព្រោះជារឿងៗសម្ងាត់។ ថ្នាក់ដឹកនាំចេញទៅណា សម័យនោះ គេអត់ដែលប្រាប់ឲ្យយើងថតទេ។ អ្នកកាសែតមិនដែលបានទៅជិតទេ។ ដូច្នេះន័យច្រើនដង ន័យម្តងគឺដែលខ្ញុំបានឃើញជាក់លាក់គឺតែម្តងហ្នឹងឯង។ វាអាចមានករណីច្រើនដងមែន។ ច្រើនដង ខ្ញុំចង់និយាយថា លោក ខៀវ សំផន អាចចេញទៅច្រើនដង ប៉ុន្តែដោយចៃដន្យហ្នឹង ដូចខ្ញុំបានបញ្ជាក់អ៊ីចឹងតែម្តងដែលខ្ញុំយល់ច្បាស់ថា អាចមានសម្តេចឪនៅក្នុងហ្នឹងដែរ។ បើចង់ដឹងជាក់ស្តែងមានតែលោកសួរបញ្ជាក់លោក ខៀវ សំផន ថាវាមានអ៊ីចឹងមែនអត់ ឬក៏ខ្ញុំថាទៅវាខុស ឬប៉ាន់ស្មានខុស។ ប៉ុន្តែខ្ញុំច្បាស់ខ្លួនខ្ញុំណាស់ ក្នុងចំណោមច្រើនដងហ្នឹង ដែលមិត្តភក្តិខ្ញុំដែលដំណើរជាមួយគ្នា វាអាចមានច្រើនដងមែន ប៉ុន្តែកាលដែលខ្ញុំបានដឹងច្បាស់ហ្នឹង គឺមានតែម្តងគត់ហ្នឹងឯង។ ដែលខ្ញុំសន្និដ្ឋានថាលោកធ្វើដំណើរតាមឡានជាមួយសម្តេច។ ព្រោះខ្ញុំមើលទៅ ខ្ញុំអាចស្គាល់ច្បាស់គាត់។ ហើយបើចង់ច្បាស់មែនទែនទាល់តែសួរសាមីខ្លួនគាត់ តើមែនឬអត់? ខ្ញុំគ្រាន់តែបញ្ជាក់ លោក ខៀវ សំផន ថាអត់អាហ្នឹងក៏មិនដឹងថាម៉េច ព្រោះខ្ញុំដូចបានឃើញ។

[១៥:៤៧:២៦]

ហើយករណីដែលថាច្រើនដងនេះ មិនមែនជូនសម្តេចទៅតែម្តងទេ នេះខ្ញុំបញ្ជាក់ហ្នឹងឡើងវិញ។ អាចនៅក្នុងកំណត់ហេតុហ្នឹងមិនយល់ពាក្យន័យដែលខ្ញុំនិយាយទេ។ ខ្ញុំបានប្រើពាក្យថាចៃដន្យ។ ចៃដន្យមានន័យថាមិនមែនខ្ញុំដឹងដំណើរគាត់ទៅណាទេ ព្រោះសម័យនោះ ខ្ញុំមិនដឹងគាត់នៅណាផង។ បាទយល់នៅ?

**សៈ** សូមអរគុណលោកសាក្សី។ តាមពិតទៅ គឺថាខ្ញុំគ្រាន់តែចង់បង្ហាញពីគោលបំណងរបស់ខ្ញុំគឺថាខ្ញុំចង់បំភ្លឺ ព្រោះថាមានឯកសារនៅក្នុងឯកសារមួយចំនួននោះ មានការអះអាងមួយចំនួន ដោយសារលោកជាលោកដែលថាយើងត្រូវចោទសំណួរ អ៊ីចឹងហើយបានជាខ្ញុំសូមការបំភ្លឺពីលោក។ អ៊ីចឹងខ្ញុំសូមអរគុណ ដែលបានបំភ្លឺចំណុចនេះ។

លោកបានពន្យល់ថា តាមរយៈមិត្តភក្តិ សហការីរបស់លោកនោះ គឺថាលោកបានដឹងថា លោក ខៀវ សំផន បានអមដំណើរសម្តេច សីហនុ នៅជុំវិញភ្នំពេញ។ សំណួរខ្ញុំដូចតទៅនេះ អម្បាញ់មិញនេះ

នៅពេលដែលលោកឆ្លើយទៅនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីលោកបានលើកឡើងថា ខ្ញុំសូមដកស្រង់នេះជាកំណត់ហេតុ -- សម្គាល់របស់ខ្ញុំ កំណត់ត្រារបស់ខ្ញុំ លោកនិយាយថា "មេដឹកនាំ" -- នេះនៅក្នុងក្របខ័ណ្ឌការយកព័ត៌មានរបស់លោក លោកនិយាយថា "អ្នកដឹកនាំបញ្ជូនយើងតែទៅក្នុងតំបន់ណាដែលមានអាហារហូបចុកគ្រប់គ្រាន់ទេ ហើយនៅពេលដែល -- សូមបញ្ជាក់ទី១ នៅពេលដែលលោកនិយាយថា "មេដឹកនាំ" នេះលោកសំដៅទៅលើអ្នកណា?

[១៥:៤៩:២១]

**ធ៖** មេដឹកនាំបើនិយាយជារួម គឺមានតាំងពីថ្នាក់លើដល់ថ្នាក់ក្រោម។ កម្មាភិបាលថ្នាក់ក្រោមក៏ជាមេដឹកនាំមួយដែរ។ យើងនិយាយពាក្យសាមញ្ញទេ មេដឹកនាំនោះ។ បើនិយាយមែនទែនថ្នាក់ដឹកនាំ។ ប៉ុន្តែពាក្យសាមញ្ញនិយាយ បានន័យថា មេគឺជាអ្នកដឹកនាំគេហើយ មិនមែនជាសមាជិកទេ។

**ស៖** និយាយឲ្យជាក់លាក់ទៅ ក្នុងករណីលោកនេះ នៅពេលដែលគេប្រាប់ឲ្យលោកទៅក្នុង អ៎! ទៅភូមិភាគណាមួយនោះ តើអ្នកណាជាអ្នកបញ្ជាលោកឲ្យទៅភូមិភាគទាំងអស់នុ៎ង?

**ធ៖** ជំនាន់៣ឆ្នាំ គឺមានតែលោកស្រី យុន យ៉ាត ម្នាក់គាត់។

**ស៖** ដោយជាក់លាក់តែម្តង តើលោកដឹងដែរឬ -- ដឹងថាតើការចេញបញ្ជានេះចេញ -- គាត់ចេញបញ្ជាដោយខ្លួនឯង ឬក៏មានអ្នកណាបញ្ជាពីលើគាត់ទៀត?

**ធ៖** ធម្មតាការដើរហើរសម័យនោះ គឺត្រូវមានមន្ទីរមួយដែលគេអនុញ្ញាតឲ្យដើរ។ មិនមែនក្រសួងខ្ញុំធ្វើទេ។ បើតាមខ្សែបណ្ដោយពីមន្ទីរមួយទៅមន្ទីរមួយ អាហ្នឹងអាចប្រធានមន្ទីរក៏អាចសម្រេចបានដែរ មិនបាច់រដ្ឋមន្ត្រីទេ។ ប៉ុន្តែបើឆ្លងទៅភូមិភាគ ទាល់តែឆ្លងទៅថ្នាក់លើ ពីក្រសួងទៅថ្នាក់លើ ។ ដូច្នេះ ខ្ញុំមានតែទៅសុំពីរដ្ឋមន្ត្រីបានទៅបាន។ សូមពីប្រធានមន្ទីរ អង្គភាពអីអត់បានទេ។ ហើយដល់ខ្ញុំធ្វើការជាមួយគាត់ទៅ ព្រោះខ្ញុំដូចក្រុមវា ដោយឡែកចុះ។ ខ្ញុំនិយាយថា ក្រុមដោយឡែក ក្រុមនិពន្ធគឺក្រុមដោយឡែក ដែលមានសិទ្ធិប្រើប្រាស់ឡាន ម៉ូតូ ឬសម្ភារៈអីច្រើនជាងគេ។ ប៉ុន្តែនិយាយជីវភាពវិញ ជាអង្គភាពមួយដោយឡែក គ្រប់គ្រងដោយស្វ័យភាពខ្លួនឯង។ ប៉ុន្តែជីវភាពការហូបចុករស់នៅ នៅក្នុងមន្ទីរក-២៥ ជិតរដ្ឋមន្ត្រី។ អ៊ីចឹងការសុំអីគឺមិនមែនសុំមន្ទីរទេ គឺយើងសុំផ្ទាល់ពីរដ្ឋមន្ត្រី។ ព្រោះមន្ទីរគេការងារច្រើន យើងមិនអាចសុំ -- ប៉ុន្តែគេក៏ដឹងដែរ ដឹងថាយើងទៅណាដែរ។

[១៥:៥២:៣២]

**ស៖** សូមអរគុណដែលបានបំភ្លឺ ក៏ប៉ុន្តែសំណួរខ្ញុំអម្បាញ់មិញ គឺចង់ដឹងថា លោកទទួលបញ្ជាពី

អ្នកស្រី យុន យ៉ាត ប៉ុន្តែដោយជាក់លាក់តែម្តងនោះ តើអ្នកស្រី យុន យ៉ាត នោះទទួលបញ្ជាពីអ្នកណាដែរ? នេះជាក្នុងករណីដែលលោកដឹង ប្រសិនបើលោកមិនដឹងទេ មិនបញ្ហាអ្វីទេ។

**ឆ៖** ខ្ញុំដឹងថា មានមន្ទីរខាងលើហ្នឹងទៀត ប៉ុន្តែខ្ញុំមិនដឹងរចនាសម្ព័ន្ធសម័យនោះយ៉ាងម៉េច។ ព្រោះខ្ញុំដឹងតែត្រឹមក្រសួងខ្ញុំ ខ្ញុំដឹង ដូចខ្ញុំបានរៀបរាប់ក្នុងក្រសួងអ៊ីចឹង ខ្ញុំដឹងចំនួនច្រើន។ ឯពាក់ព័ន្ធនឹងការដឹកនាំផ្សេងទៀត ខ្ញុំអត់ដឹង។

**ស៖** សូមអរគុណដែលបានឆ្លើយបញ្ជាក់។ ដើម្បីឲ្យច្បាស់លាស់ទាក់ទងទៅនឹងផ្នែកនៃចម្លើយរបស់លោកដែលខ្ញុំបានដកស្រង់អម្បាញ់មិញនេះ ពាក់ព័ន្ធទៅនឹងការធ្វើដំណើររបស់លោក ខៀវ សំផន ជាមួយនិងសម្តេច សីហនុ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ចាម។ តើខេត្តទាំងអស់នេះជាខេត្តដែលគេអនុញ្ញាតឲ្យលោកៗទៅយកព័ត៌មាន ឬក៏យ៉ាងម៉េច?

[១៥:៥៤:១៦]

**ឆ៖** មែនទែន ខ្ញុំអាចមានសិទ្ធិដើរទៅយកព័ត៌មានបាន ជាអង្គភាព។ អង្គភាពពីរ មានក្រសួងឃោសនាការ និងក្រសួងឃោសនាអប់រំ អាចទៅចុះយកព័ត៌មានបាន។ ប៉ុន្តែទាល់តែមានការអនុញ្ញាតដូចខ្ញុំជម្រាបខាងលើ។

**ស៖** លោកសាក្សី សំណួរខ្ញុំអម្បាញ់មិញនេះ ដែលឆ្លើយតបទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកាលពីព្រឹកមិញ។ កាលនោះ គឺថាលោកឆ្លើយថា “មេដឹកនាំបញ្ជូនលោកតែទៅកន្លែងណាដែលមានអាហារហូបចុកគ្រប់គ្រាន់ទេ”។ អ៊ីចឹងសំណួរខ្ញុំចង់ថា តើខេត្តកណ្តាល ខេត្តតាកែវ កំពង់ចាម នេះជាខេត្តដែលមានចំណីអាហារហូបចុកគ្រប់គ្រាន់ ឬយ៉ាងម៉េច?

[១៥:៥៥:៣២]

**ឆ៖** ខ្ញុំនិយាយ អារម្មណ៍ខ្ញុំសម័យនោះ គឺខ្ញុំរស់នៅភ្នំពេញ ខ្ញុំគិតថា ខេត្តណាក៏ដោយនៅទូទាំងប្រទេសអាចមានការហូបចុកគ្រប់គ្រាន់ដូចខ្ញុំដែរ។ នេះជាអារម្មណ៍ខ្ញុំនៅពេលនោះ ព្រោះខ្ញុំកម្រជួបប្រទះនឹងការអត់ឃ្លានណាស់។ ហើយតាមខ្ញុំប៉ាន់ស្មានទៅ នៅមូលដ្ឋានបើដូចបច្ចុប្បន្ននេះ ច្រើននិយាយថា សម័យខ្មែរក្រហម គឺជាសម័យដែលអត់ឃ្លាន។ ខ្ញុំស្ទើរតែមិនជឿទេ ព្រោះនៅភ្នំពេញហ្នឹង ខ្ញុំមិនដែលហូបមិនគ្រប់គ្រាន់ទេ។ ដូចខ្ញុំបានឆ្លើយពីលើកមុនហើយ។ ប៉ុន្តែមកសម័យក្រោយនេះ គឺច្រើនលើកអំពីបញ្ហាធ្វើពលកម្មច្រើន ការហូបមិនគ្រប់គ្រាន់ ហើយមានការអត់ឃ្លាន។ ប៉ុន្តែដែលខ្ញុំទៅ គឺចំកន្លែងដែលមានបើកការដ្ឋានដូចនៅអន្លង់ចង្អៀង ទំនប់ស្ទឹងជីនិតអី ខ្ញុំឃើញចលនាសស្រាក់សស្រាំហ្នឹង ខ្ញុំ

មិនបាននឹកស្មានទេក្នុងសម័យនោះ។ មិនស្មានថា មានប្រជាជនអត់ឃ្លានទេ ហើយខ្ញុំទៅត្រង់ណា ក៏គេមិនដែលរៀបចំឲ្យយើងអត់ឃ្លាន អត្តខាត់អីអត់ទេ។ គឺគេមានបាយ មានទឹក មានម្ហូប មានសាច់គោ សាច់មាន់ សាច់ជ្រូកអី ដូចនៅភ្នំពេញដែរ។ ដល់អីចឹងអារម្មណ៍ខ្ញុំនៅពេលនោះ ខ្ញុំនឹកឃើញថាប្រហែលជាមិនមានការអត់ឃ្លានទេ ប៉ុន្តែក៏មិនអាចសម្បូរដែរ។

[១៥:៥៧:៣២]

**ស៖** នេះជាចំណុចចុងក្រោយរបស់ខ្ញុំ ទាក់ទងទៅនឹងការងាររបស់លោកជាអ្នកកាសែត។ នៅក្នុងចម្លើយរបស់លោក គឺថានៅទំព័រដដែល ហើយយោងដែលខ្ញុំឲ្យអម្បាញ់មិញនេះដដែលហ្នឹង គឺថា E3/380 ក៏ប៉ុន្តែនេះនៅដើមកថាខណ្ឌម្តង។ លោកបានឆ្លើយថា "នៅក្នុងរយៈពេល៣ឆ្នាំ ខៀវ សំផន កាន់ពីខាងដឹកស្បៀងជញ្ជូនទៅតំបន់ភូមិភាគផ្សេងៗ"។ អម្បាញ់មិញនេះ នៅពេលដែលលោកឆ្លើយសំណួរទៅលោកចៅក្រម ឡាវែន៍ ខ្ញុំហាក់ដូចជាយល់ឃើញថា នេះជាព័ត៌មានដែលលោកទទួលបានពីមនុស្សទី៣។ តើអ្នកណាមនុស្សទី៣នេះ ដែលនិយាយអំពីការងាររបស់លោក ខៀវ សំផន ទាក់ទងនឹងការដឹកស្បៀងជញ្ជូនទៅតំបន់ ភូមិភាគផ្សេងៗនេះ នរណាជាអ្នកប្រាប់លោកថា លោក ខៀវ សំផន ការងាររបស់គាត់ គឺដឹកស្បៀង ដឹកអីហ្នឹង?

[១៥:៥៨:៤៣]

**ឆ៖** មែនទែន ខ្ញុំមានក្មួយខ្ញុំធ្វើការ មិនដឹងជាមួយលោក ខៀវ សំផន ឬក៏អ្នកណាទេ ហើយមានមួយចំនួនធ្វើការខាងផ្នែកដឹកជញ្ជូនហ្នឹង។ ដូច្នេះ គេដឹងថាលោក ខៀវ សំផន បានរៀបចំអីខ្លះ។ ឧបមាថាខាង ភូមិភាគ តំបន់ គេស្នើអីខ្លះ? ស្នើកំណាត់ ស្នើខោអាវ ប៉ុន្តែនិយាយរួម គឺស្នើសម្ភារៈ។ ហើយខ្ញុំឮតាមគេ ខ្ញុំវាមិនដឹង ព្រោះខ្ញុំទទួលព័ត៌មានវាប្រយោលដែរ វាមិនដឹង ប៉ុន្តែថាលោកតែមានការស្នើ គឺរៀបចំឲ្យគេហើយ ឲ្យកម្លាំងរៀបចំឲ្យ។ ជាការពិត មិនពិត ខ្ញុំមិនដឹងដែរ ព្រោះការណ៍នេះខ្ញុំដឹងដោយប្រយោល។ ហើយដែលខ្ញុំនិយាយនេះ ខ្ញុំវាយតម្លៃថា នេះជាការពិត ប៉ុន្តែខ្ញុំមិនបានឃើញទេ ប៉ុន្តែមនុស្សដែលគួរឲ្យជឿទុកចិត្តបាន។ ព្រោះក្បួនដឹកម្តងៗក៏ខ្ញុំឃើញដែរ ឡានទៅម្តងទៅជាក្បួនតែម្តង ឡានចិន។ មានកំណាត់ មានអង្ករ មានរបស់របរប្រើប្រាស់ផ្សេងៗ ហើយហ្នឹងបានឃើញនឹងភ្នែកហើយ គឺទៅម្តងទាំងក្បួនៗតែម្តង។ ហើយខ្ញុំបានបកស្រាយហើយ។ ពាក់ព័ន្ធនឹងសម្ភារៈចេញពីភ្នំពេញ ខ្ញុំបានបកស្រាយពីមុនហើយចម្លើយ។ ខ្ញុំអាចថា ដល់ ឬមិនដល់។ ព្រោះធម្មតា ខ្ញុំជាអ្នកសរសេរកាសែត ខ្ញុំតែងតែសួរមហាជនហ្នឹង ថាដល់ ឬមិនដល់។ កន្លែងខ្លះដល់ កន្លែងខ្លះ អត់បានដល់ទេ។ អីចឹង វាមាន

មូលហេតុហើយ បានជាមិនដល់ហ្នឹង។ ព្រោះដឹកម្តងៗ បើគិតជាដុល្លារសម័យឥឡូវមិនតិចទេ។ ព្រោះទៅម្តងៗ ទាំងក្បួនទៅ ហើយតែកុងឡានរាប់ ច្រើនឡានដែរ ជាឡានក្បួនតែម្តង។ ទុកថាមិនដល់សម័យឥឡូវ ថាយើងមានឡានធំៗ អ៊ីចឹង ប៉ុន្តែសម័យនោះ ក៏ដឹកដូចគ្នា។

[១៦:០១:១៤]

**ស៖** លោកសាក្សី សំណួរចុងក្រោយរបស់ខ្ញុំ ព្រោះថាឥឡូវវាដល់ម៉ោងចប់សវនាការហើយ។ តើលោកអាចផ្តល់ឈ្មោះរបស់អ្នកដែលនិយាយអំពីសកម្មភាពដែរឬទេ? លោកអម្បាញ់មិញនេះ លោកនិយាយថា ក្មួយ។ អ៊ីចឹង លោកអាចឲ្យឈ្មោះក្មួយនុ៎ងបានទេ?

**ឆ៖** ក្មួយខ្ញុំឈ្មោះ អុល។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសាក្សី ខ្ញុំសូមអរគុណ ដែលអត់ធ្មត់ក្នុងការឆ្លើយសំណួរខ្ញុំនេះ ហើយខ្ញុំសូមបញ្ចប់ការចោទសំណួរទៅសាក្សីត្រឹមនេះ តែម្តងលោកសាក្សី។

សូមអរគុណ -- អ៎! លោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកស្រីមេធាវី។ អរគុណសាក្សី។ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការ សម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២៣ ខែសីហា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី គឹម វុន ដែលនឹងបន្តការតាំងសំណួរដេញដោល ដោយក្រុមមេធាវីការពារក្តី ពីរក្រុមទៀត គឺក្រុមការពារក្តី នួន ជា ហើយនិងក្រុមមេធាវីការពារក្តី អៀង សារី។ សូមភាគី និងសាធារណជន ជ្រាប។

[១៦:០២:៣៧]

លោក គឹម វុន ការស្តាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ។ សវនាការត្រូវធ្វើបន្តនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីនេះ វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់វិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*